សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ កក្កដា ឆ្នាំ ២០២០

# លីអាហូណា



## តើខ្ញុំអាចជួយបានយ៉ាងដូចម្តេច ?


ពេលមនុស្សជាទីស្រឡាញ់បានចាកចេញពីសាសនាចក្រ ទំព័រ ៣០

រៀនពីអ្នកដែលបានត្រឡប់មកវិញ ទំព័រ ២៦

របៀបដែលការយល់ពីប្រវត្តិសាស្ត្រសាសនាចក្ររបស់យើងជួយ ទំព័រ ១២

សាសនាចក្រ
នៅទីនេះ

# រដ្ឋធានីប៉ុនតាអារេណាស
# ប្រទេសឈីលី





រូបថតគឺ GETTY IMAGES

សាសនាចក្រគឺរឹងមាំនៅក្នុងប្រទេសឈីលី រាប់ចាប់ពីក្រុងតូចៗនៅវាលខ្សាច់នៃភាគខាងជើងរហូតដល់ទីក្រុងសាន់ទីអាហ្គោដ៏ធំនៅប៉ែកកណ្ដាល រហូតដល់ស្តេកប៉ុនតាអារេណាសនៅភាគខាងត្បូងដែលមានវួដចំនួនប្រាំពីរ និងសាខាចំនួនពីរ ។ នេះគឺជាសេចក្ដីពិតមួយចំនួនអំពីប្រទេសឈីលី និងសាសនាចក្រនៅទីនោះ ៖

សមាជិកសាសនាចក្រ — ៥៩៥៥២៦

៣.៣ — ភាគរយនៃប្រជាជនគឺជាសមាជិកនៃសាសនាចក្រ

៧៧ ស្តេក
៥៩០ ក្រុមជំនុំ
១០ បេសកកម្ម

១០០ — មជ្ឈមណ្ឌលពង្សប្រវត្តិ

៣ — ព្រះវិហារបរិសុទ្ធ ៖ សាន់ទីអាហ្គោ ( បានឧទ្ទិសឆ្លងនៅឆ្នាំ ១៩៨៣ ) ខន់សិបសីអន ( បានឧទ្ទិសឆ្លងនៅឆ្នាំ ២០១៨ ) អាន់តូហ្វាហ្គាស្តា ( បានប្រកាសនៅឆ្នាំ ២០១៩ )

៤២៧០ — គីឡូម៉ែត្រពីព្រំដែនភាគខាងជើងនៃប្រទេសឈីលីទៅកាន់ព្រំដែនភាគខាងត្បូង ទទឹង ៣៥០ គីឡូម៉ែត្រពីខាងកើតទៅខាងលិច

ឆ្នាំ ១៩៥៦ — ក្រុមជំនុំដំបូងបំផុតត្រូវបានរៀបចំ

ឆ្នាំ ១៩៧២ — ស្តេកដំបូងបំផុតត្រូវបានបង្កើតឡើង

ឆ្នាំ ១៩៨៨ — ប្រទេសទីបួននៅក្នុងពិភពលោកដែលឈានដល់ ៥០ ស្តេក

ឆ្នាំ ១៩៩៤–៩៦ — ស្តេកចំនួន ២៦ ត្រូវបានបង្កើតឡើង



## ចញ្ចពីលីអាហូណា

មាតិកានៅក្នុងច្បាប់នេះហានត្រូវបង្កើតឡើងពីមុនការរាតត្បាតនៃជំងឺកូវីដ ១៩ ។ សេចក្ដីលម្អិតមួយចំនួនប្រហែលជាមិនអនុវត្តនឹងស្ថានការបច្ចុប្បន្ននោះទេ ។ សូមបត់បនៃសំណើទាំងឡាយ យោងតាមសេចក្ដីត្រូវការរបស់សាសនាចក្រនាពេលបច្ចុប្បន្ន និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ។




ប្រវត្តិសាសនាចក្រ ៖ ប្រភពនៃកម្លាំង និងការបំផុសគំនិត
*អែលឌើរ ឃ្វីនថិន អិល យុក, ខេត ហូលប្រ៊ូក និង ម៉ាត ហ្គ្រូ*
១២





ខ្ញុំមានការទាក់ចិត្តនឹងភេទដូចគ្នា—តើសមាជិកសាសនាចក្រស្វាគមន៍ខ្ញុំវិញទេ ?
*ប៊ូយ «បប់» អេស. អេកូម៉ា វើសធេច*
៤០





ពេលខ្ញុំមានអារម្មណ៍ថាត្រូវបានបំភាន់អំពីសាសនាចក្រ
*ត្រាវីស អ៊ីវែល*
២៦


# របៀបដែលយើងពង្រឹងសេចក្ដីជំនឿយើង—ជាមួយគ្នា

នៅក្នុងការសិក្សារបស់យើងអំពីព្រះគម្ពីរមរមននៅខែនេះ យើងរៀនអំពីកូរីហូរ ជាអ្នកដែលបានធ្វើឲ្យសមាជិកសាសនាចក្រជាច្រើនជឿថាពួកគេត្រូវបានបោកបញ្ឆោតដោយពួកព្យាការី ប៉ុន្តែក្រោយមកបានទទួលស្គាល់ថា គាត់ខ្លួនឯងផ្ទាល់ត្រូវបានបោកបញ្ឆោតដោយសាតាំង ហើយបានបោកបញ្ឆោតអ្នកដទៃទៀត ។ យើងរៀនអំពីពួកសាសន៍សូរ៉ាំ ជាមនុស្សមួយក្រុមដែលបានបំបែកខ្លួនពួកគេចេញពីសាសនាចក្រ ។ ហើយយើងឃើញអាលម៉ាជាកូន ដែលជាអ្នកធ្លាប់ប្រឆាំងទាស់នឹងសាសនាចក្រយ៉ាងសកម្ម ព្យាយាមពង្រឹងកូនៗមជ្ឈិមវ័យរបស់លោកផ្ទាល់ទាស់នឹងជម្រើសទាំងឡាយដែលនឹងដឹកនាំពួកគេចេញពីព្រះអម្ចាស់ និងសាសនាចក្ររបស់ទ្រង់ ។

ពួកយើងមួយចំនួនមានសមាជិកគ្រួសារ ឬមិត្តភក្តិដែលជ្រើសរើសឈប់ចូលរួមនឹងសាសនាចក្រដែលបានស្ដារឡើងវិញរបស់ព្រះអម្ចាស់ទៀត ។ ការណ៍នេះអាចជាការឈឺចាប់សម្រាប់ពួកយើងទាំងឡាយដែលមានសេចក្ដីជំនឿយ៉ាងខ្លាំង ។ យើងចង់ជួយ ប៉ុន្តែពួកយើងជាច្រើនពុំដឹងជួយដោយរបៀបណា ។

ទស្សនាវដ្ដីមួយច្បាប់ពុំអាចគ្របដណ្ដប់លើគ្រប់មូលហេតុទាំងអស់ដែលសេចក្ដីជំនឿចុះអន់ថយ ឬពន្យល់ឲ្យប្រាកដពីរបៀបដើម្បីឆ្លើយតបនោះទេប្រសិនបើវាចុះអន់ថយនោះ ។ ដំណើរនៃសេចក្ដីជំនឿរបស់មនុស្សម្នាក់ៗគឺខុសៗគ្នា ។ ប៉ុន្តែយើងសង្ឃឹមថាវាអាចផ្ដល់ជំនួយខ្លះៗជាមួយនឹងច្បាប់នេះដូចជា ៖

- បទពិសោធន៍របស់បុរសម្នាក់ដែលត្រឡប់មកព្រះវិហារវិញ និងអ្វីដែលគាត់បានរៀនពីវា ( សូមមើលទំព័រ ២៦ ) ។
- សារសំខាន់នៃការស្វាគមន៍មនុស្សគ្រប់គ្នា ( សូមមើលទំព័រ ៤០ ) ។
- យោបល់សម្រាប់ឪពុកម្ដាយពីរបៀបដើម្បីស្វែងរកវិធីរក្សាចំណងទាក់ទងរបស់ពួកគេជាមួយនឹងកូនៗមជ្ឈិមវ័យដែលបានជ្រើសរើសផ្លូវផ្សេង ( សូមមើលទំព័រ ៣០ ) ។
- ទស្សនវិស័យដ៏មានប្រយោជន៍នានាអំពីប្រវត្តិសាស្ត្រសាសនាចក្រ និងរបៀបដែលវាអាចពង្រឹងសេចក្ដីជំនឿរបស់យើង ( សូមមើលទំព័រ ១២ ) ។

យើងសង្ឃឹមថា អត្ថបទទាំងនេះផ្ដល់នូវចំណុចចាប់ផ្ដើមមួយសម្រាប់បងប្អូន ដើម្បីស្វែងរកការណែនាំដ៏ទេវភាពសម្រាប់កាលៈទេសៈផ្ទាល់ខ្លួនរបស់បងប្អូន ។

ដោយស្មោះស្ម័គ្រ
អ័ដាម ស៊ី អូលសុន
អ្នកគ្រប់គ្រងផ្នែកកែសម្រួល



# មាតិកា


៥ **ការអញ្ជើញដល់វិចិត្រករទូទាំងពិភពលោក**

៦ **ការបង្ហាញអំពីសេចក្ដីជំនឿ**
អ៊ិកណាជើស និង អាដែលលេដ ប៉ៃឌូ
គ្រួសារប៉ៃឌូបានឃើញដោយផ្ទាល់នូវពរជ័យនៃកម្មវិធីអក្ខរកម្មដំណឹងល្អនៅក្នុងស្ដេក និងគ្រួសាររបស់ពួកគាត់ ។

៨ **គោលការណ៍នៃការងារបម្រើ**
ការងារបម្រើតាមរយៈសកម្មភាពសាសនាចក្រ
សកម្មភាពទាំងឡាយរបស់សាសនាចក្រផ្ដល់នូវឱកាសនានាដើម្បីសាងមិត្តភាព ឈោងជួយ និងផ្ដល់ការងារបម្រើដល់មនុស្សដទៃទៀត ។

១២ **ប្រវត្តិសាស្ត្រសាសនាចក្រ ៖ ប្រភពនៃកម្លាំង និងការបំផុសគំនិត**
*ដោយអែលឌើរ ឃ្វីនថិន អិល យុក, ខេត ហូលប្រ៊ូក និង ម៉ាត ហ្គ្រូ*
តើការសិក្សាប្រវត្តិសាស្ត្រសាសនាចក្រអាចពង្រឹងសេចក្ដីជំនឿ និងបំណងប្រាថ្នាប្អូនៗដើម្បីរស់នៅតាមដំណឹងល្អកាន់តែពេញលេញយ៉ាងដូចម្ដេច ?

២០ **គិតពីពួកអ្នកត្រួសត្រាយផ្លូវនៅប្រទេសឥណ្ឌា**
*ដោយ ថៅណាលីន រូស័រហ្វ័ត*
ពួកបរិសុទ្ធដ៏ស្មោះត្រង់ទាំងនេះធ្វើជាគំរូថាវាមានន័យយ៉ាងណាក្នុងការធ្វើជាសសរនៃសាសនាចក្រ ។

២៦ **ពេលខ្ញុំមានអារម្មណ៍ថាត្រូវបានបំភាន់អំពីសាសនាចក្រ**
*ដោយ ត្រាវីស អ៊ីវែល*
បន្ទាប់ពីបងប្រុសអ៊ីវែលបានរៀនពីការណ៍ទាំងឡាយដែលបានធ្វើឲ្យសៅហ្មងដល់ជំនឿរបស់គាត់ ហើយបានបណ្ដាលឲ្យគាត់ចាកចេញពីព្រះវិហារអស់មួយរយៈ នោះគាត់បានដឹងពីអ្វីដែលគាត់បានខកខាន ។

៣០ **អ្នកស្រឡាញ់ ទ្រង់សង្គ្រោះ**
*ដោយ គ្រីស្ដា រ៉ូជ័រ ម៉ជើនសិន*
ម្ដាយម្នាក់ដឹងថា មិនថាកូនៗមជ្ឈិមវ័យរបស់គាត់ជ្រើសរើសយ៉ាងណានោះទេ គាត់គ្រាន់តែត្រូវស្រឡាញ់ពួកគេ ។

៣២ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**
គ្រួសារមួយទុកការលំបាករបស់ពួកគេផ្ទាល់មួយឡែកសិនដើម្បីផ្ដល់ការងារបម្រើ ។ ពលទ័ពអាកាសដ៏ក្លាហានម្នាក់ឈរការពារជំនឿរបស់គាត់ ហើយបានបំផុសដល់អ្នកដទៃទៀត ។ ម្ដាយម្នាក់រក្សាការសន្យាមួយ ។ ការអត់ទោសកើតឡើងនៅគ្រាដ៏មិនរំពឹងទុកមួយ ។

៣៦ **ចូរមកតាមខ្ញុំ ៖ ព្រះគម្ពីរមរមន**
អត្ថបទប្រចាំសប្ដាហ៍ទាំងនេះអាចគាំទ្រដល់ការសិក្សាព្រះគម្ពីរមរមនរបស់បងប្អូននៅខែនេះ ។

៤០ **ខ្ញុំមានការទាក់ចិត្តនឹងភេទដូចគ្នា—តើសមាជិកសាសនាចក្រស្វាគមន៍ខ្ញុំវិញទេ ?**
*ប៊ូយ «បប់ » អេស. អេកូម៉ា រើសធេច*
ពេលបងប្រុសរើសធេចបានទទួលអារម្មណ៍ឲ្យត្រឡប់មកព្រះវិហារវិញ គាត់បានព្រួយបារម្ភថាតើសមាជិកផ្សេងទៀតទទួលគាត់ឬទេ ។


ការអានខ្លីៗ

ការគាំទ្រចូរមកតាមខ្ញុំ



**នៅលើក្របមុខ**
រូបភាពមកពី
stock.adobe.com និង
unsplash.com

## វគ្គ


យុវមជ្ឈិមវ័យ
៤៤
អនាគតអាចជារឿងគួរឲ្យភ័យខ្លាច ។ ប៉ុន្តែជាមួយនឹងជំនួយពីព្រះវរបិតាសួគ៌ យើងទាំងអស់គ្នាអាច**ឈានឆ្ពោះទៅមុខជាមួយសេចក្ដីជំនឿលើអនាគត** ។ ខែនេះ សូមអានរឿងរ៉ាវទាំងឡាយមកពីយុវមជ្ឈិមវ័យដែលបានរៀនពី**គន្លឹះមួយចំនួនក្នុងការរៀបចំ**សម្រាប់ពេលអនាគត ។





យុវវ័យ
៥២
រៀនអំពីរបៀបដែល**ដំណឹងល្អអាចផ្លាស់ប្ដូរគ្រួសាររបស់អ្នក** និងមូលហេតុដែល**ជម្រើសដ៏សាមញ្ញ**របស់អ្នកនៅក្នុងជីវិតគឺសំខាន់ ។







កុមារ
*ប្រិយមិត្ត*
ប្អូនអាចក្លាយជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ដូចជាអាលម៉ា !




## អត្ថបទមានតែឌីជីថលប៉ុណ្ណោះសម្រាប់ខែកក្កដា



### តើអ្នកមានសំណួរពីដំណឹងល្អដែរឬទេ ? នេះជារបៀបប្រាំយ៉ាងដើម្បីស្វែងរកចម្លើយ

*ដោយ ឆាខែល រួដលែញ*

យុវមជ្ឈិមវ័យម្នាក់ចែកចាយពីរបៀបដែលសំណួរទាំងឡាយអាចពង្រឹងសេចក្ដីជំនឿ បើយើងអនុញ្ញាត ។



### របៀបដែលខ្ញុំរៀបចំខ្លួនសម្រាប់ព្រះវិហារបរិសុទ្ធនៅក្នុងប្រទេសឥណ្ឌា

*ដោយ យេសវ៉ាន់ស៍ យូស៊ីរេដឌី*

យុវមជ្ឈិមវ័យម្នាក់មកពីប្រទេសឥណ្ឌា ចែកចាយពីរបៀបដែលគាត់កំពុងរៀបចំខ្លួនសម្រាប់ឱកាសដំបូងរបស់គាត់ដើម្បីទៅព្រះវិហារបរិសុទ្ធ ។



### អ្វីដែលត្រូវធ្វើដើម្បីទទួលបានបំណងប្រាថ្នាដ៏សុចរិតរបស់យើង

*ដោយ ម៉ាក ដេអូ ដេឡា ឃ្រូស*

យុវមជ្ឈិមវ័យម្នាក់មកពីប្រទេសហ្វីលីពីន ចែកចាយពីរបៀបដែលគាត់បានរកឃើញសេចក្ដីជំនឿ ពេលផែនការសម្រាប់អនាគតរបស់គាត់បានផ្លាស់ប្ដូរ ។

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី Gospel Library និងនៅគេហទំព័រ liahona.ChurchofJesusChrist.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- មើលមាតិកាដែលមានតែឌីជីថលប៉ុណ្ណោះ ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬជាវដើម្បីផ្ដល់ជាអំណោយ ។
- ពង្រីកការសិក្សាជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក ឬបោះពុម្ពអត្ថបទ ។
- ស្ដាប់អត្ថបទដែលអ្នកចូលចិត្ត ។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

សូមផ្ញើសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ChurchofJesusChrist.org

សូមដាក់បញ្ជូនរឿងរបស់អ្នកនៅគេហទំព័រ liahona.ChurchofJesusChrist.org ឬផ្ញើសំបុត្រទៅកាន់ ៖
*Liahona*,flr. 23
50 E. North Temple Street
Salt Lake City, UT 84150-0023, USA

**ខែ កក្កដា ឆ្នាំ ២០២០ វ៉ុល ៤៤ លេខ ៧**
**លីអាហូណា ១៦៧២២ ២៥៨**

ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**ក្វ៉ូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌេល ជី រេនឡាន់, ជើរិត ដបុលយូ ហ្គង, អ៊ូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** រ៉ាន់ឌី ឌី ហ្វាំង

**អ្នកប្រឹក្សា ៖** ប៊ែកឃី ក្រាវិន, ស្សារ៉ុន អ៊ូបែង, គ្រីស្ទីណា ប៊ី ហ្វ្រានកូ, វ៉លធើរ ហ្វេស. ហ្គន់ហ្សាលេស, ឡារី អេស ខាឈើរ, ចេន អ៊ី ញូវមែន, អែគ្រាន អូធៅ, ម៉ែឃើល ធី រីងវូដ, ជីន ភី ស្ទេនហ្វីល

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន

**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយប៊ិហ្គ

**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន

**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ពផ្សាយ ៖** កាមីឡា ខាស្រ្ទីលលុន

**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ឌែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ្លីតុន, ហ្គារែត អេច ហ្គាហ្វ, អើរ៉ុន ចនស្តុន, ចន រ៉ាយអិន ជិនសិន, ឆាលឡូត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ដុក, យ៉ូស្វេ ជេ ភឹគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឡូរី ហ្វូលើរ សូសា, ឆាកខែល រួដឡេ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដស៊ិន

**នាយកផ្នែកសិល្បៈ ៖** ថៃដ អ័រ ភីធើរសុន

**រចនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនឆ្លី, ស៊ី ឃីមបឹល បុត, ថូម៉ាស ឆាល, ចូស្វ័រ ដេននីស ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្គ្រីន, ស្កត អិម ម៉ូយ, អេលេនី រេហ្គើរ, ម៉ាក ដ័បុលយូ រ៉ូប៊ីសុន, យេ នីកូល វ៉កឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នៃបេឃើ អាននី

**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍

**ផលិតកម្ម ៖** អ៊ីវ៉ា ហ្វ្លែន អាឌៀ, ជូលី បឺដេត, ហូសេ ឆាវេហ្ស, ថូម៉ាស ជី ខ្រូនីន, ប្រាយអែន ដ័បុលយូ ហ្គីជី, ជីននី ជេ នីលសុន, ម៉ារីសា អិម ស្មីធ

**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស

**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាឃើរ

សូមផ្ញើអត្ថបទ និង សំណួរនានាតាមអិនធឺរណែតនៅគេហទំព័រ liahona.ChurchofJesusChrist.org តាមអ៊ីម៉ែលទៅកាន់ liahona@ChurchofJesusChrist.org ឬ តាមសំបុត្រទៅកាន់ *Liahona,* flr.23, 50 E. North Temple St., Salt Lake City, UT 84150–0023, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និងវៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។

© 2020 by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។

**For Readers in the United States and Canada:** July 2020 Vol. 19 No. 4. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.50 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.ChurchofJesusChrist.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



# ការអញ្ជើញដល់វិចិត្រករទូទាំងពិភពលោក



អ្នកត្រូវបានអញ្ជើញឲ្យបង្កើតស្នាដៃសិល្បៈថ្មីៗសម្រាប់ការប្រកួតកិច្ចការសិល្បៈអន្តរជាតិលើកទី ១២ ដែលឧបត្ថម្ភដោយសារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រនៅទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ។

រាល់ប្រព័ន្ធផ្សព្វផ្សាយ រចនាបទ និងបែបបទតាមវប្បធម៌ខាងគំនូរទាំងអស់ត្រូវបានស្វាគមន៍ ។ ស្នាដៃសិល្បៈដែលត្រូវបានជ្រើសរើសនឹងត្រូវដាក់បង្ហាញនៅឯសារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ និងនៅលើអ៊ិនធើរណែត ។

ការប្រកួតដោយមានគណៈវិនិច្ឆ័យនេះទទួលវិចិត្រករពីជុំវិញពិភពលោក ជាកិច្ចប្រឹងប្រែងមួយដើម្បីលើកទឹកចិត្តដល់ការបង្កើតស្នាដៃសិល្បៈដ៏មានគុណភាពដោយពួកបរិសុទ្ធថ្ងៃចុងក្រោយ ដើម្បីបង្ហាញពីទំហំ និងភាពចម្រុះនៃស្នាដៃខាងវប្បធម៌ពួកបរិសុទ្ធថ្ងៃចុងក្រោយ និងដើម្បីពង្រីកការប្រមូលផ្ដុំរបស់សារៈមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ ។

- ប្រធានបទ ៖ « មនុស្សទាំងអស់គឺមានតម្លៃស្មើគ្នានៅចំពោះព្រះ » នីហ្វៃទី ២ ២៦:៣៣ ។
- កាលបរិច្ឆេទដាក់បញ្ជូន ៖ ថ្ងៃទី ១ ខែ កុម្ភៈ – ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០២១
- អាយុ ៖ វិចិត្រករត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ
- រង្វាន់ ៖ វិចិត្រករដែលកិច្ចការរបស់គាត់ត្រូវបានជ្រើសរើសសម្រាប់ការតាំងពិពណ៌នឹងត្រូវបានជូនដំណឹងនៅក្នុងខែ តុលា ឆ្នាំ ២០២១
- កាលបរិច្ឆេទការតាំងពិពណ៌ ៖ ខែ មីនា ឆ្នាំ ២០២២ ដល់ខែ តុលា ឆ្នាំ ២០២២

សូមចូលទៅកាន់គេហទំព័រ **ChurchofJesusChrist.org/artcompetition** សម្រាប់ច្បាប់ពិស្ដារ តម្រូវការដើម្បីទទួលបានសិទ្ធិចូលរួមការចុះឈ្មោះតាមអិនធើរណិត និងដើម្បីមើលស្នាដៃដ៏បំផុសគំនិតពីការប្រកួតពីមុន ។ ■

« [ ព្រះអម្ចាស់ ] មិនធ្វើការណ៍ឡើយ លើកលែងតែការណ៍នោះច្បាស់លាស់ដល់កូនចៅមនុស្ស ហើយទ្រង់អញ្ជើញពួកគេទាំងអស់គ្នាឲ្យមករកទ្រង់ ហើយទទួលទាននូវសេចក្ដីល្អសប្បុរសរបស់ទ្រង់ ហើយទ្រង់ពុំបដិសេធអ្នកណាម្នាក់ដែលមករកទ្រង់ឡើយ គឺទាំងខ្មៅ និងស ទាំងបាវគេ និងសេរី ទាំងប្រុស និងស្រី ហើយទ្រង់នឹកចាំដល់ពួកអ្នកឥតសាសនា ហើយមនុស្សទាំងអស់ ទាំងពួកសាសន៍យូដា និងពួកសាសន៍ដទៃ ក៏ដូចគ្នានៅចំពោះព្រះដែរ » ។

—នីហ្វៃទី២ ២៦:៣៣

## មនុស្សទាំងអស់គ្នាគឺដូចគ្នានៅចំពោះព្រះ





តាមទ្រនិចនាឡិកាពីឆ្វេងខាងលើទៅ ៖ *ព្រះគ្រីស្ទជាមួយនឹងម្កុដបន្លា* ដោយ អ័ដាម លី ស័រវ៉ូដ *បំណែកបញ្ចូលគ្នា* ដោយ ផេច ខ្រូសលេនដ៍ អែនឌើរសុន *ទឹករស់* ដោយ រ៉ូស ឌេថកស៍ ឌេល *ព្រះគ្រីស្ទព្យាបាល* ដោយ លេវ៉យ គ្លិន គ្រេនស៍ហៀល *ផែនការណ៍នៃសេចក្ដីសង្គ្រោះ* ដោយ ជូលី យូអ៊ិន យិម

# អ៊ិកណាធើស និង អាដែលលេដ ប៉ែឌូ

*រដ្ឋធានីអាក្រា ប្រទេសហ្គាណា*



*អ៊ិកណាធើស និងអាដែលលេដ បានឃើញពីរបៀបដែលកម្មវិធីអក្ខរកម្មរបស់សាសនាចក្រ និងការសង្កត់ធ្ងន់លើការរៀនសូត្រដំណឹងល្អដែលផ្ដោតក្នុងគេហដ្ឋានបានផ្ដល់ពរដល់សមាជិកនៃស្ដេក និងគ្រួសាររបស់ពួកគាត់ ។*

គ្រីស្ទីណា ស្មីធ ជាងថតរូប



**អ៊ិកណាធើស ៖**

ខ្ញុំបានចូលរួមក្នុងកម្មវិធីអក្ខរកម្មដំណឹងល្អក្នុងនាមជាសមាជិកម្នាក់នៃគណៈប្រធានស្ដេក ។ ខ្ញុំបានទៅមើលថ្នាក់មួយ ហើយបានដឹងថា វាមិនត្រឹមតែសម្រាប់ពួកអ្នកដែលមិនចេះអាន និងសរសេរនោះទេ ។ វាគឺសម្រាប់យើងទាំងអស់គ្នា ដើម្បីយល់ពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទឲ្យកាន់តែប្រសើរឡើង ។

*ចូរមកតាមខ្ញុំ* និងការរៀនសូត្រដំណឹងល្អដែលផ្ដោតក្នុងគេហដ្ឋាននឹងជួយក្រុមគ្រួសារទាំងឡាយឲ្យអានព្រះគម្ពីរជាមួយគ្នា ហើយរៀនពីគ្នាទៅវិញទៅមក ។

**អាដែលលេដ ៖**

នៅក្នុងគ្រួសាររបស់យើង យើងព្យាយាម ហើយធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន ។ គ្រប់គ្នាចូលរួម ។ ខ្ញុំសប្បាយចិត្តណាស់ចំពោះរបៀបដែលកូនៗរបស់ខ្ញុំជួយគ្នាទៅវិញទៅមកកាលដែលយើងអានព្រះគម្ពីរមរមនជាមួយគ្នា ។ ពួកគេស្រឡាញ់ព្រះគម្ពីរមរមន ។ យើងមានពេលវេលាដ៏ល្អអាន និងចែកចាយទីបន្ទាល់របស់យើងជាមួយគ្នា ។

**អ៊ិកណាធើស ៖**

ប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍ថា « ការលើកតម្កើងគឺជាបញ្ហាមួយរបស់គ្រួសារ » ។[១] ខ្ញុំស្រឡាញ់ភរិយា និងកូនៗខ្ញុំ ។ ខ្ញុំចង់នៅជាមួយនឹងពួកគេ និងព្រះវរបិតាសួគ៌របស់យើងជារៀងរហូត ដូច្នេះយើងត្រូវជួយគ្នាទៅវិញទៅមក ។

**ស្វែងរកបន្ថែម**

សូមមើលបន្ថែមទៀតអំពីដំណើរនៃសេចក្ដីជំនឿរបស់គ្រួសារប៉ែឌូ រួមទាំងរូបថតជាច្រើនបន្ថែមទៀត នៅក្នុងកំណែនៃអត្ថបទនេះនៅលើអ៊ិនធើណែត ឬ Gospel Library នៅគេហទំព័រ **ChurchofJesusChrist.org/go/7620 ។**

រៀនពីប្រធាន ហិនរី ប៊ី អាវរិង ពីរបៀបដែលកិច្ចប្រឹងប្រែងរបស់យើងដើម្បីធ្វើឲ្យគេហដ្ឋានរបស់យើងជាកន្លែងមួយនៃសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់អាចនាំមកនូវអំណរដ៏យូរអង្វែងដល់គ្រួសារយើង នៅគេហទំព័រ **ChurchofJesusChrist.org/go/7720 ។**

**កំណត់ចំណាំ**

១. រ័សុល អិម ណិលសុន « Come, Follow Me » *Liahona* ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ៨៩ ។



គោលការណ៍នៃការងារបម្រើ

# ការងារបម្រើ
## តាមរយៈសកម្មសកម្មភាព
## សាសនាចក្រ







របៀបមួយដែលយើងអាចផ្តល់ការងារបម្រើដល់សមាជិកវួដ អ្នកជិតខាង និងមិត្តភក្តិរបស់យើង គឺតាមរយៈសកម្មភាពសាសនាចក្រ ។ មិនថាអ្នករៀបចំផែនការតាមតម្រូវការ ឬចំណាប់អារម្មណ៍របស់មនុស្សដែលអ្នកផ្តល់ការងារបម្រើ ឬអ្នកអញ្ជើញពួកគេឲ្យចូលរួមនៅក្នុងសកម្មភាព ឬឱកាសបម្រើនានាសម្រាប់អ្នកដទៃទៀត សកម្មភាពទាំងឡាយក្នុងកម្រិតវួដ ស្តេក ឬសូម្បីតែពហុស្តេក គឺអាចផ្តល់នូវមធ្យោបាយដ៏មានន័យ និងកម្សាន្តដើម្បីបីបាច់ដល់សាមគ្គីភាព និងពង្រឹងសមាជិក ។

សកម្មភាពទាំងឡាយរបស់សាសនាចក្រអាចបើកច្រកដល់ឱកាសជាច្រើនដើម្បីផ្តល់ការងារបម្រើផងដែរ ។ ឧទាហរណ៍ សកម្មភាពទាំងឡាយរបស់សាសនាចក្រអាចផ្តល់ជាឱកាសដើម្បីចូលរួមក្នុងគម្រោងបម្រើនានាដែលផ្តល់ពរជ័យដល់មនុស្សដទៃទៀត ហើយស្ថាបនានូវចំណងទាក់ទងវិជ្ជមាននៅក្នុងសហគមន៍ ។ សកម្មភាពទាំងឡាយរបស់សាសនាចក្រក៏អាចជាឱកាសមួយដើម្បីឈោងទៅសមាជិកសាសនាចក្រដែលមិនសូវសកម្ម និងមិត្តភក្តិដែលនៅព្រះវិហារផ្សេងទៀត ឬមិត្តភក្តិដែលមិនមានទំនាក់ទំនងនឹងសាសនាផងដែរ ។

ការរាប់បញ្ចូលមនុស្សជាច្រើននៅក្នុងសកម្មភាពសាសនាចក្រ បង្កើតជាឱកាសមួយដល់ព្រះអម្ចាស់ដើម្បីប្រទានពរជ័យ និងពង្រឹងវួដ និងសាខារបស់យើង ភូមិផងរបស់យើង និងសហគមន៍របស់យើង ។

រូបថតស្ម័គ្រចិត្តបម្រើ ដោយ ឡារីន អានីតា ហ្គីឌី រូបថតការ៉េម និងរណារអារឈើចេញពី GETTY IMAGES ។



**ស្ថាបនាចំណងទាក់ទងវិជ្ជមាន**

រដូវរងាជិតឈានចូលមកដល់ហើយ ដេវីឌ ឌីកសុន ពុំដឹងថាត្រូវធ្វើយ៉ាងណាដើម្បីរក្សាគ្រួសារគាត់ឲ្យមានភាពកក់ក្តៅនោះទេ ។

ដេវីឌ ភរិយាគាត់ និងកូនស្រីពីរនាក់ ទើបតែបានប្តូរមកនៅទីក្រុងជនបទហ្វ្រេដូនៀ រដ្ឋអារីហ្សូណា ស.រ.អា. ជាទីវាលខ្សាចខ្ពស់ដែលហ៊ុំព័ទ្ធដោយចំណោតថ្មក្រហមដ៏អស្ចារ្យ គុម្ពោតសេចប្រាស់ និងដើមឈើដែលមានពណ៌បៃតងអស់ពេញមួយឆ្នាំ ។

ផ្ទះដែលគ្រួសារឌីកសុនបានជួលពឹងទៅលើចង្ក្រានដុតឱសជាប្រភពកម្តៅចម្បង ។ ដេវីឌបានដឹងភ្លាមៗថា ការប្រមូលឱសគឺជាជំនាញដ៏ចាំបាច់ដោយសាររដូវរងានៅទីក្រុងហ្វ្រេដូនៀគឺពោរពេញទៅដោយព្រិល និងទឹកកក ។

« ខ្ញុំពុំមានឱស ឬម៉ាស៊ីនអារឈើទេ ហើយមិនចេះទាំងប្រើវាផង ! » ដេវីឌបាននិយាយ ។ « ខ្ញុំមិនដឹងថា ត្រូវធ្វើអ្វីនោះទេ » ។

សមាជិកវួដមួយចំនួនបានសួរដេវីឌ ថាបើគ្រួសារគាត់មានឱសគ្រប់គ្រាន់ដើម្បីប្រើពេញមួយរដូវរងានោះ ។ ដេវីឌបាននិយាយថា « មិនយូរទេពួកគេបានដឹងថា ខ្ញុំពុំមានឱសគ្រប់គ្រាន់ទេ » ។ « ភ្លាមៗនោះ កូរ៉ុមអែលឌើរបានសូមជួយខ្ញុំប្រមូលឱស ។ ខ្ញុំបានទទួលជំនួយរបស់ពួកគេ ដោយអំណរគុណយ៉ាងក្រៃលែង » ។

មិនយូរប៉ុន្មាន ដេវីឌបានដឹងថា ការធ្វើដំណើរទៅប្រមូលឱសនេះជាធម្មតាគឺជាសកម្មភាពវួដដែលត្រូវដាក់ផែនការយ៉ាងល្អ រៀបចំយ៉ាងល្អ និងមានការចូលរួមយ៉ាងច្រើន ។ នៅព្រឹកថ្ងៃសៅរ៍មួយ ដេវីឌ កូរ៉ុមអែលឌើរ និងសមាជិកវួដផ្សេងទៀតបានទៅភ្នំដោយជិះក្នុងក្បួនឡានត្រាក់ និងឡានសណ្តោងរទេះ ។

ដេវីឌនិយាយថា « សូមអរគុណដល់ឧបករណ៍ និងចំណេះដឹងរបស់ពួកគេ តែក្នុងមួយរសៀលប៉ុណ្ណោះ សមាជិកវួដបានផ្តល់ឱសមួយគំនរដល់គ្រួសារខ្ញុំ ដែលអាចប្រើបានស្ទើរតែពីររដូវរងា » ។ « សំខាន់ជាងនោះទៀត ខ្ញុំត្រូវបានបង្រៀននូវអ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការដឹងអំពីការប្រមូលឱសដោយខ្លួនឯង ។ មកទល់នឹងពេលដែលខ្ញុំបានចាកចេញពីទីក្រុងហ្វ្រេដូនៀ ខ្ញុំបានចេះរបៀបប្រើម៉ាស៊ីនអារឈើ ហើយបានជួយក្នុងសកម្មភាពប្រមូលឱសប្រចាំវួដច្រើនរាប់មិនអស់ » ។

សកម្មភាពវួដបែបនេះមិនត្រឹមតែស្ថាបនានូវចំណងទាក់ទងវិជ្ជមានក្នុងចំណោមសមាជិកសាសនាចក្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្ថាបនាចំណងទាក់ទងវិជ្ជមានជាមួយមនុស្សគ្រប់គ្នានៅក្នុងសហគមន៍ផងដែរ ។

ដេវីឌនិយាយថា « ខ្ញុំចាំស្ត្រីម្នាក់ មិនមែនជាសមាជិកសាសនាចក្រទេ ដែលជាអ្នកចំណូលថ្មីនៅក្នុងតំបន់ » ។ « គាត់ត្រូវតែដុតបន្ទះក្តារពីផ្ទះគាត់ដើម្បីឲ្យបានកក់ក្តៅ ។ ពេលយើងបានដឹងអំពីស្ថានភាពរបស់គាត់ យើងបានធ្វើឲ្យប្រាកដថាគាត់មានឱសគ្រប់គ្រាន់ដើម្បីប្រើពេញមួយរដូវរងានោះ ។ គាត់មានអំណរគុណខ្លាំងណាស់ស្ទើរតែនិយាយមិនចេញ » ។

កិច្ចប្រឹងប្រែងក្នុងការផ្តល់ការងារបម្រើនៅក្នុងទីក្រុងហ្វ្រេដូនៀ គឺធ្វើឲ្យប្រាកដថា គ្រប់គ្នាមានសុវត្ថិភាព ហើយកក់ក្តៅក្នុងរដូវរងា ។



**ឈោងទៅជួយដល់អ្នកដទៃ**

ខណៈកំពុងបម្រើបេសកកម្មនៅក្នុងប្រទេសរូម៉ានី មេគ យ៉ូសថ៍ និងដៃគូរបស់នាងតែងតែទៅសួរសុខទុក្ខគ្រួសារមួយដែលមិនបានមកព្រះវិហារជាយូរមកហើយ ។ មេគនិយាយថា « គ្រួសារស្ទេនីកាជាសមាជិកដំបូងៗនៃសាសនាចក្រនៅក្នុងប្រទេសរូម៉ានី ហើយយើងស្រឡាញ់ពួកគាត់ » ។

ពេលដែលត្រូវដាក់ផែនការ និងរៀបចំសកម្មភាពរបស់សាខា ថ្នាក់ដឹកនាំបានសម្រេចចិត្តថា សាខានឹងមានកម្មវិធី « រាត្រីអ្នកត្រួសត្រាយផ្លូវ » មួយ ។ នេះជារាត្រីមួយដើម្បីអបអរសាទរពួកអ្នកត្រួសត្រាយផ្លូវដ៏ក្លាហានដែលបានដើរឆ្លងកាត់សហរដ្ឋដើម្បីទៅកាន់ជ្រលងសលត៍លេក ។ វាក៏ជាឱកាសមួយដើម្បីគោរពដល់ពួកអ្នកត្រួសត្រាយផ្លូវនៃសាសនាចក្រនៅក្នុងប្រទេសរូម៉ានីផងដែរ ។

មេគនិយាយថា « យើងបានគិតថា វាជារបៀបដ៏អស្ចារ្យមួយដើម្បីឲ្យសមាជិកមួយចំនួនថ្លែងទីបន្ទាល់អំពីការប្រែចិត្តជឿរបស់ពួកគេ និងរបៀបដែលពួកគេបានឃើញសាសនាចក្ររីកចម្រើននៅក្នុងប្រទេសរូម៉ានី » ។ « យើងបានគិតភ្លាមថា គ្រួសារស្ទេនីកាគួរតែចូលរួម ។ យើងបានអញ្ជើញពួកគេឲ្យចូលរួម ហើយពួកគេរំភើបណាស់ ! »

នៅរាត្រីនៃសកម្មភាពនោះ គ្រួសារស្ទេនីកានៅតែមិនទាន់មកដល់ ពេលដែលកម្មវិធីត្រូវចាប់ផ្តើម ។

មេគរំឭកថា « យើងព្រួយបារម្ភថាពួកគេនឹងមិនមកទេ » ។ « ប៉ុន្តែពួកគេបានដើរចូលមកទាន់ពេលល្មម ។ គ្រួសារស្ទេនីកាបានថ្លែងទីបន្ទាល់ដ៏ល្អមួយអំពីដំណឹងល្អ និងសាសនាចក្រ ។ ពួកគេក៏បាននៅជជែកលេងជាមួយសមាជិកផ្សេងទៀតដែលពួកគេមិនបានជួបជាយូរមកហើយផងដែរ » ។

សមាជិកសាខាបានលាដៃស្វាគមន៍គ្រួសារស្ទេនីកា ។ ថ្ងៃអាទិត្យបន្ទាប់ មេគបានភ្ញាក់ផ្អើលតែរីករាយដែលឃើញបងស្រីស្ទេនីកានៅព្រះវិហារ ។

« ពេលខ្ញុំបានទៅលេងសាខានោះពីរបីខែក្រោយមក គាត់នៅតែមកព្រះវិហារ ! » មេគនិយាយ ។ « ខ្ញុំគិតថា ឱកាសដើម្បីថ្លែងទីបន្ទាល់របស់គាត់ និងដើម្បីមានអារម្មណ៍ថាត្រូវបានរាប់បញ្ចូល និងត្រូវការនៅក្នុងសាខាពិតជាបានជួយគាត់ » ។

**គំនិត ៤ យ៉ាងសម្រាប់ការផ្ដល់ការងារបម្រើតាមរយៈសកម្មភាពសាសនាចក្រ**

- **ដាក់ផែនការសកម្មភាពដែលបំពេញតម្រូវការ ៖** សកម្មភាពទាំងឡាយគឺជារបៀបដ៏អស្ចារ្យមួយដើម្បីបំពេញតម្រូវការជាច្រើនផ្សេងៗគ្នា ។ សកម្មភាពទាំងនោះអាចត្រូវបានគ្រោងដើម្បីបំពេញតម្រូវការជាក់លាក់របស់បុគ្គលម្នាក់ ឬក្រុមមួយ ។ សកម្មភាពទាំងនោះគួរតែបំពេញតម្រូវការអ្នកដែលចូលរួមផងដែរ មិនថាតម្រូវការនោះជាការស្គាល់គ្នាទៅវិញទៅមកឲ្យកាន់តែច្បាស់ រៀនបន្ថែមទៀតអំពីដំណឹងល្អ ឬទទួលព្រះវិញ្ញាណក៏ដោយ ។
- **អញ្ជើញមនុស្សគ្រប់គ្នា ៖** ពេលអ្នកដាក់ផែនការសកម្មភាព សូមធ្វើកិច្ចប្រឹងប្រែងពិសេសមួយដើម្បីអញ្ជើញអ្នកដែលនឹងទទួលបានប្រយោជន៍ពីការចូលរួមនោះ ។ សូមគិតពីសមាជិកថ្មី សមាជិកមិនសូវសកម្ម យុវវ័យ យុវមជ្ឈិមវ័យ មនុស្សដែលមានពិការភាព និងមនុស្សដែលមកពីព្រះវិហារផ្សេងទៀត ។ សូមផ្ដល់ការអញ្ជើញដោយគិតពីចំណាប់អារម្មណ៍ខ្លាំងបំផុតរបស់ពួកគេនៅក្នុងគំនិត ហើយបង្ហាញថាអ្នកពិតជាចង់ឲ្យពួកគេមកចូលរួមយ៉ាងខ្លាំង ។
- **លើកទឹកចិត្តឲ្យមានការចូលរួម ៖** អ្នកទាំងឡាយដែលអ្នកអញ្ជើញ នឹងទទួលប្រយោជន៍បានកាន់តែច្រើនពីសកម្មភាព ប្រសិនបើពួកគេមានឱកាសចូលរួម ។ វិធីមួយដើម្បីលើកទឹកចិត្តឲ្យមានការចូលរួម គឺត្រូវឲ្យបុគ្គលម្នាក់ៗប្រើអំណោយទាន ជំនាញ និងទេពកោសល្យរបស់ពួកគេនៅក្នុងសកម្មភាពនោះ ។
- **ស្វាគមន៍មនុស្សគ្រប់គ្នា ៖** មិត្តភក្តិរបស់អ្នកចូលរួមសកម្មភាពមួយ សូមធ្វើឲ្យអស់ពីសមត្ថភាពដើម្បីធ្វើឲ្យពួកគេមានអារម្មណ៍ស្វាគមន៍ ។ ដូចគ្នានោះដែរ ប្រសិនបើអ្នកឃើញមនុស្សដែលអ្នកមិនស្គាល់ សូមរាក់ទាក់ ហើយស្វាគមន៍ពួកគេផងដែរ ! ■

**ស្វែងរកបន្ថែម**

នៅគេហទំព័រ ChurchofJesusChrist.org អ្នកអាចមើលវីដេអូ « Inviting Others to 'Come and Help' » ដើម្បីឃើញថាតើវាងាយស្រួលយ៉ាងណាដើម្បីអញ្ជើញអ្នកដទៃទៀតឲ្យបម្រើជាមួយយើង ។



រូបថតរបស់ស៊ីស៊ី និងបាល់ទាត់ពី GETTY IMAGES; រូបថតយុវជនកំពុងដំឡើងតង់ ដោយបិត ខូឃើរ រូបថតក្មេងស្រីកំពុងដំឡើងតង់ ដោយវែលើ ព្រាយ ម៉ាក់ហ្វាឡែន









**បើកដួងចិត្តរបស់អ្នក**

« យើងគួរតែយកចិត្តទុកដាក់ ហើយរកមើលមនុស្សថ្មីៗជានិច្ច នៅពេលចូលរួមសកម្មភាព និងការប្រជុំនៅព្រះវិហារ ។ . . . យើងអាចធ្វើកិច្ចការសាមញ្ញៗដើម្បីជួយមិត្តភក្តិថ្មីទាំងនេះ ឲ្យទទួលអារម្មណ៍នៃការឱបក្រសោប និងការស្វាគមន៍ . . . ដូចជាការស្វាគមន៍យ៉ាងកក់ក្តៅ ស្នាមញញឹមដោយស្មោះសរចំពោះពួកគេ . . . ណែនាំពួកគេឲ្យសមាជិកផ្សេងទៀតស្គាល់ជាដើម ។ នៅពេលយើងបើកដួងចិត្តរបស់យើងចំពោះមិត្តភក្តិថ្មីរបស់យើង . . . នោះយើងកំពុងអនុវត្តស្មារតីនៃការងារបម្រើ » ។

**អែលឌើរ អូលីសេស សូរ៉េស ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « One in Christ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៣៨ ។**

**ការងារបម្រើដោយការអញ្ជើញ**

សូមពិនិត្យមើលសកម្មភាពវួដ ឬសាខាដែលនឹងមានក្នុងពេលខាងមុខ ។ គិតអំពីមនុស្សដែលអ្នកផ្តល់ការងារបម្រើដល់ ហើយពិចារណាពីការអញ្ជើញពួកគេឲ្យចូលរួមសកម្មភាពទាំងនោះ ។



**សូមចែកចាយបទពិសោធន៍របស់អ្នក**

សូមផ្ញើមកកាន់យើងនូវបទពិសោធន៍របស់អ្នក នៅពេលអ្នកបានផ្តល់ការងារបម្រើដល់មនុស្សដទៃ ឬទទួលបានការងារបម្រើ ។ សូមចូលទៅ liahona.ChurchofJesusChrist.org ហើយចុចលើ « Submit an Article or Feedback » ។




**ដោយអែលឌើរ ឃ្វីនធិន អិល យ៉ុក**

ក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់

អត្ថបទបន្ថែមដោយ ខេត ហូលប្រ៊ូក និង ម៉ាត គ្រូ ជាប្រវត្តិវិទូ ប្រចាំសាសនាចក្រ


# ប្រវត្តិសាសនាចក្រ

## ប្រភពនៃកម្លាំង និងការបំផុសគំនិត

*នៅក្នុងអត្ថបទនេះ ដែលដកស្រង់ចេញពីការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកធ្វើឡើងនៅទីក្រុងណៅវូ រដ្ឋអិលលីណោយ នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៨ អែលឌើរ ឃ្វីនថិន អិល យ៉ុក និងប្រវត្តិវិទូប្រចាំសាសនាចក្រ ខេត ហូលប្រ៊ូក និង ម៉ាត គ្រូ ឆ្លើយនូវសំណួរទាំងឡាយអំពីប្រវត្តិសាសនាចក្រដែលត្រូវបានសួរដោយយុវមជ្ឈិមវ័យពីទូទាំងពិភពលោក ។*

**អែលឌើរ យ៉ុក ៖** ប្រវត្តិសាស្ត្រសាសនាចក្រអាចជាប្រភពដ៏សំខាន់នៃសេចក្ដីជំនឿ ប៉ុន្តែសម្រាប់មនុស្សមួយចំនួន វាត្រូវបានយល់ខុស ឬមើលរំលង ។ មនុស្សខ្លះថែមទាំងបាននិយាយរឿងពីអតីតកាលទាំងខុសឆ្គងដោយចេតនា ដើម្បីបង្កឲ្យមានការសង្ស័យ ។

ដោយការរៀនសូត្រប្រវត្តិសាស្ត្រសាសនាចក្រ*ដែលអាចជឿទុកចិត្តបាន* នោះយើងនឹងចងភ្ជាប់ដួងចិត្តរបស់យើងរួមគ្នាជាមួយនឹងពួកបរិសុទ្ធជំនាន់មុន និងសម័យបច្ចុប្បន្ន ។ យើងនឹងរកឃើញគំរូនៃមនុស្សដែលមិនល្អឥតខ្ចោះដូចជាបងប្អូន និងខ្ញុំ ដែលបានដើរឆ្ពោះទៅមុខដោយសេចក្ដីជំនឿ ហើយបានអនុញ្ញាតឲ្យព្រះធ្វើការតាមរយៈពួកគេ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ។ ខ្ញុំសូមសន្យាថា ការសិក្សាប្រវត្តិ



ខាងស្ដាំ ៖ រូបថតផ្ដិតយកពី GETTY IMAGES ខាងស្ដាំឆ្ងាយ ៖ អាឌីសុន ប្រាត និងកំហាត់បេតរបស់លោក ប្រែន ប៉ូលីនេស៊ា ឆ្នាំ ១៨៤៤

*កាលយើងរៀនបន្ថែមទៀតពីពួកបរិសុទ្ធពីមុន យើងនឹងទទួលបានកម្លាំងក្នុងការបំពេញបេសកកម្មរបស់យើងផ្ទាល់ក្នុងនាមជាបុត្រា ឬបុត្រីមួយរូបរបស់ព្រះ ។*

សាស្ត្រសាសនាចក្រអាចពង្រឹងសេចក្ដីជំនឿ និងបំណងប្រាថ្នាបងប្អូនដើម្បីរស់នៅតាមដំណឹងល្អកាន់តែពេញលេញ ។

ដំណើររឿងនៃការស្ដារឡើងវិញគឺជាដំណើររឿងមួយនៃការលះបង់ ការប្ដេជ្ញាចិត្ត និងសេចក្ដីជំនឿ ។ យើងទាំងអស់គ្នាគឺជាផ្នែកនៃការស្ដារឡើងវិញ និងនៃប្រវត្តិសាស្ត្រសាសនាចក្រ ។ យើងម្នាក់ៗមានបេសកកម្មមួយដើម្បីសម្រេចនៅក្នុងជីវិតនេះ ដែលនឹងជួយដំណឹងល្អឲ្យបំពេញផែនដីនេះ ។ កាលយើងរៀនបន្ថែមទៀតពីពួកបរិសុទ្ធពីអតីតកាល យើងនឹងទទួលបានកម្លាំងក្នុងការបំពេញបេសកកម្មរបស់យើងផ្ទាល់ ក្នុងនាមជាបុត្រា ឬបុត្រីមួយរូបរបស់ព្រះ ។

ក្នុងរយៈពេលជាង ២៤ ឆ្នាំនេះដែលខ្ញុំបានបម្រើជាពួកអ្នកមានសិទ្ធិអំណាចទូទៅមួយរូប ថាបំណងប្រាថ្នារបស់ពួកបងប្អូនប្រុសគឺធ្វើឲ្យមានតម្លាភាពតាមដែលអាចធ្វើទៅបាន ទាំងខាងប្រវត្តិសាស្ត្រសាសនាចក្រ និងខាងគោលលទ្ធិ ។ យើងទទួលអារម្មណ៍ថា ការខិតខំបង្កើតធនធានថ្មីទាំងនេះ—ជាពិសេស *អត្ថបទរបស់យ៉ូសែប ស្ម៊ីធ* សំណេរអំពីប្រធានបទដំណឹងល្អ ប្រធានបទប្រវត្តិសាស្ត្រសាសនាចក្រ ហើយឥឡូវនេះគឺ សៀវភៅ *ពួកបរិសុទ្ធ*[១] ដែលមានច្រើនវ៉ុល—គឺជាវិធីដ៏ល្អមួយ ដោយឲ្យមនុស្សសិក្សារឿងរ៉ាវនៅក្នុងបរិបទដែលត្រឹមត្រូវ ហើយនឹងជួយពួកគេឲ្យយល់ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទតាមរបៀបដែលអាចជឿទុកចិត្តបាន ។

ដំណើររឿងមួយដែលខ្ញុំចូលចិត្តនៅក្នុង *ពួកបរិសុទ្ធ* គឺជាដំណើររឿងរបស់ អាឌីសុន ប្រាត ធ្វើដំណើរទៅតំបន់ប៉ាស៊ីភិចខាងត្បូង ។ លោកមានពិធីបុណ្យជ្រមុជទឹកប្រហែលជា ៦០ ។ ភរិយារបស់ខ្ញុំ ម៉ារី និងខ្ញុំបានមានឱកាសទៅបណ្ដុំកោះអូស្ត្រាលី ហ្រ្វែន ប៉ូលីនេស្យា ជាកន្លែងដែល អាឌីសុន ប្រាត បានបង្រៀន ។

បទពិសោធន៍ដ៏អស្ចារ្យមួយដែលខ្ញុំធ្លាប់មានគឺការឮស្រ្តីវ័យក្មេងម្នាក់និយាយនៅទីនោះថា « ខ្ញុំគឺជាសមាជិកសាសនាចក្រជំនាន់ទីប្រាំពីរ » ។ អាឌីសុន ប្រាត បានជ្រមុជទឹកជីដូនជីតារបស់នាង ពីមុនពួកបរិសុទ្ធចេញទៅរដ្ឋយូថាហ៍ ។

មិនថាបងប្អូននៅទីណាទេ មិនថាតំណពូជពង្សរបស់បងប្អូនមកពីណាទេ បងប្អូនគឺជាមនុស្សសំខាន់ បងប្អូនគឺជាផ្នែកនៃប្រវត្តិសាស្ត្រសាសនាចក្រ ។ យើងត្រូវការបងប្អូន ហើយចង់បានបងប្អូនខ្លាំងណាស់ ។ បងប្អូននឹងផ្ដល់ពរជ័យដល់ជីវិតមនុស្ស ។



## យ៉ូសែប ស្ម៊ីធ និងព្រះគម្ពីរមរមន

កាលខ្ញុំនៅជាយុវវ័យ យើងបានគិតថា បងប្រុសខ្ញុំនឹងមិនបានបម្រើបេសកកម្មទេ ដោយសារវួដត្រូវបានអនុញ្ញាតឲ្យបញ្ជូនយុវជនតែម្នាក់ម្ដងៗប៉ុណ្ណោះដើម្បីទៅបម្រើបេសកកម្មមួយ ។ អ្នកផ្សេងទៀតត្រូវតែត្រៀមជាស្រេចសម្រាប់កំណែនទ័ព ។ ប៉ុន្តែប៊ីស្សព និងប្រធានស្តេករបស់យើងបានដឹងថា ពួកគាត់អាចបញ្ជូនម្នាក់ទៀត ។ ដូច្នេះពួកគាត់បាននិយាយជាមួយបងប្រុសខ្ញុំអំពីវា ហើយគាត់បានត្រឡប់មកផ្ទះប្រាប់ឪពុកម្ដាយខ្ញុំ ។

ឪពុករបស់ខ្ញុំជាបុរសដ៏ល្អម្នាក់ ប៉ុន្តែគាត់មិនបានសកម្មនៅក្នុងព្រះវិហារទេ ។ ការឆ្លើយតបរបស់គាត់គឺអវិជ្ជមាន—ប៉ុន្តែដោយសារមូលហេតុដ៏មិនធម្មតាមួយ ។ គាត់ពុំបានរិះគន់សាសនាចក្រ ឬបេសកកម្មទេ ប៉ុន្តែបងប្រុសខ្ញុំកំពុងរៀបចំខ្លួនចូលរៀនសាលាពេទ្យ ។ ឪពុកខ្ញុំបានពោលថា « កូនបានរៀបចំខ្លួនចូលរៀនសាលាពេទ្យ ។ កូនបានចូលរៀនថ្នាក់ទាំងឡាយ ។ កូនអាចធ្វើកិច្ចការល្អៗបានច្រើនជាងកូនទៅបេសកកម្ម បើកូនចូលរៀននៅសាលាពេទ្យ » ។



## ហេតុអ្វីសាសនាចក្រពុំបើកចំហរកាន់តែខ្លាំងអំពីរឿងរ៉ាវចម្រូងចម្រាស់មួយចំនួននៅក្នុងប្រវត្តិសាស្ត្ររបស់សាសនាចក្រ ?

ដោយ ខេត ហូលប្រ៊ូក

កាលខ្ញុំអាយុបួនឆ្នាំ ម្ដាយខ្ញុំ និងយាយខ្ញុំបានធ្វើការនៅផ្ទះប៊ីហៃ ជាផ្ទះចាស់របស់ព្រិកហាំ យ៉ង់ នៅក្នុងទីក្រុងសលត៍លេក រដ្ឋយូថា ។ គាត់បានបង្រៀនខ្ញុំអ្វីៗទាំងអស់អំពីព្រិកហាំ យ៉ង់ ហើយថាលោកមានភរិយាច្រើន ។ ប្រហែល ១០ ឆ្នាំក្រោយមក ខ្ញុំបានរៀនថា យ៉ូសែប ស្ម៊ីធ មានភរិយាច្រើនផងដែរ ។ ខ្ញុំពុំបានរៀនពីត្បូងអ្នកមើលធុត ដែលយ៉ូសែប ស្ម៊ីធ ប្រើដើម្បីជួយបកប្រែព្រះគម្ពីរមរមនទេ រហូតដល់ខ្ញុំជាមជ្ឈិមវ័យ ។ សាសនាចក្រពុំបានបិទបាំងព័ត៌មានពីខ្ញុំទេ ប៉ុន្តែព័ត៌មានប្រវត្តិសាស្ត្រនោះពុំត្រូវបានសង្កត់ធ្ងន់ខ្លាំងទេ ពេលខ្ញុំនៅក្មេងនោះ ។

អ្វីដែលខ្ញុំបានរៀននៅក្នុងការប្រជុំថ្ងៃអាទិត្យរបស់ខ្ញុំ និងក្នុងថ្នាក់សិក្ខាសាលារបស់ខ្ញុំគឺជាកិច្ចការចម្បងរបស់សាសនាចក្រ ។ ខ្ញុំបានរៀនប្រែចិត្ត ។ ខ្ញុំបានរៀនធ្វើឲ្យជីវិតខ្ញុំស្របតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំបានរៀនពីរបៀបបង្កើតទំនាក់ទំនងមួយជាមួយនឹងព្រះវរបិតាសួគ៌ខ្ញុំ ។ ហើយទាំងនេះគឺជារឿងដែលខ្ញុំផ្ដល់តម្លៃបំផុតក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំដឹងថា ចំពោះមនុស្សខ្លះ វាអាចជារឿងដ៏ឈឺចាប់ដើម្បីរៀនពីអ្វីមួយដែលប្អូនបានគិតថា ប្អូនគួរតែបានដឹង ប៉ុន្តែប្អូនពុំបានដឹង ។ នោះជាហេតុផលដែល ម៉ាត និងខ្ញុំធ្វើកិច្ចការដែលយើងធ្វើនេះ ។ យើងសង្ឃឹមថា បទពិសោធន៍សម្រាប់មនុស្សនោះនឹងក្លាយជាផ្នែកមួយនៃអតីតកាល ដោយសារយើងមានសៀវភៅ*ពួកបរិសុទ្ធ* ដែលបង្ហាញពីដំណើររឿងពេញលេញមួយសម្រាប់មនុស្សទូទៅ ។



ខាងឆ្វេងឆ្ងាយ ៖ វីឡៅ ឃើមបល ខាងឆ្វេង ៖ រចនាប្រភពដោយ ជើរ៉ៃ ប្រ៊ីន





ព្រះគ្រីស្ទនៅក្នុងសួនច្បារ គែតសេម៉ានី ដោយ យ៉ូសែប ប្រ៊ិកឃើ ។ ព្រះគម្ពីរមរមនឆ្នាំ ១៨៣០ បានទទួលការអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ យ៉ូសែប ស៊្មីធ ដោយ អើវីន ល៉ឺទរស៊ី

## តើយើងដឹងថាបើប្រភពមួយអំពីប្រវត្តិសាស្ត្រសាសនាចក្រអាចជឿជាក់បានដោយរបៀបណា ?

ដោយ ម៉ាត ហ្គ្រូ

ខ្ញុំបានធ្វើការឲ្យសាសនាចក្រអស់ប្រាំបួនឆ្នាំហើយ ដោយសរសេរអំពីប្រវត្តិសាស្ត្រ ។ ខ្ញុំបានឃើញពីឥរិយាបថរបស់ពួកអ្នកមានសិទ្ធិអំណាចទូទៅរបស់យើងចំពោះប្រវត្តិសាស្ត្ររបស់យើង ។ ការសន្ទនាទាំងឡាយគឺមិនមែនអំពី « តើយើងលាក់កំបាំង ឬពិនិត្យដកចេញនូវអ្វីដែលមិនល្អពីប្រវត្តិសាស្ត្រដោយរបៀបណា ? » នោះទេ ។ ផ្ទុយទៅវិញ ការសន្ទនាទាំងឡាយគឺអំពី « តើយើងអាចធ្វើឲ្យប្រវត្តិសាស្ត្រអាចចូលទៅប្រើប្រាស់បាន អាចរកបាន និងអាចយល់បានដោយរបៀបណា ? »

យើងទាំងអស់គ្នាដឹងថា ការប្រឈមនៅក្នុងជំនាន់ព័ត៌មានវិទ្យានោះ គឺពុំមែនជាការស្វែងរកចម្លើយនោះទេ—យើងហ៊ុមព័ទ្ធដោយចម្លើយ—ប៉ុន្តែការប្រឈមនោះគឺជាការញែកដឹងរវាងចម្លើយល្អ និងចម្លើយអាក្រក់ ព័ត៌មានល្អ និងព័ត៌មានអាក្រក់ ។ មានការពិភាក្សាជាច្រើនអំពីប្រវត្តិសាស្ត្ររបស់យើងនៅលើអ៊ិនធើណេត ហើយភាគច្រើនការពិភាក្សាទាំងនេះបង្កើតឲ្យមានជាកំហឹងជាជាងពន្លឺ ។

ចូរប្រុងប្រយ័ត្នអំពីប្រភពព័ត៌មានដែលកេតែបន្ទុះបង្អាប់ដល់មនុស្ស ។ ជំនួសមកវិញ សូមរកមើលប្រភពព័ត៌មានដែលពឹងផ្អែកទៅលើកំណត់ត្រាដែលបន្សល់ទុកដោយមនុស្សផ្ទាល់ ហើយដែលខិតខំដើម្បីមានភាពយុត្តិធម៌ចំពោះពួកគេ ។ វាងាយស្រួលដើម្បីរកឃើញកំហុសរបស់មនុស្សជំនាន់មុនដោយវិនិច្ឆ័យពួកគេដោយប្រើបទដ្ឋានបច្ចុប្បន្ននេះ វាងាយស្រួលដើម្បីទាញយកការដកស្រង់មួយ ឬឧប្បត្តិហេតុមួយចេញពីបរិបទរបស់វា ហើយធ្វើឱ្យវាមើលទៅគួរឱ្យភ័យខ្លាច ។

ក្នុងនាមជាអ្នកប្រវត្តិវិទូមួយរូប ខ្ញុំព្យាយាមធ្វើតាមពាក្យទូន្មានរបស់កវីប្រលោមលោកជនជាតិអង់គ្លេសម្នាក់ ។ គាត់ពោលថា « អតីតកាលគឺជាប្រទេសក្រៅមួយ ពួកគេធ្វើរឿងផ្សេងនៅទីនោះ » ( L. P. Hartley, *The Go-Between* [ ១៩៥៣ ], បុព្វកថា ) ។ វាមានន័យថា នៅពេលយើងមើលទៅអតីតកាល យើងពុំចង់ធ្វើជា « អ្នកទេសចរណ៍ដ៏អាក្រក់ » ម្នាក់នោះទេ ។ យើងចង់ព្យាយាមយល់ពីមនុស្សនៅក្នុងបរិបទ និងវប្បធម៌របស់ពួកគេផ្ទាល់ ។ យើងចង់មានចិត្តអត់ធ្មត់ជាមួយនឹងអ្វីដែលយើងយល់ថាជាកំហុសរបស់ពួកគេនោះ ។ យើងចង់មានចិត្តរាបទាបចំពោះដែនកំណត់នៃដំណេះដឹងរបស់យើងផ្ទាល់ ។ ហើយយើងចង់មានវិញ្ញាណនៃសេចក្តីសប្បុរសមួយអំពីអតីតកាល ។

នៅរាត្រីនោះ បងប្រុសដ៏ល្អ ដ៏ស្មោះត្រង់របស់ខ្ញុំបានអង្គុយជាមួយនឹងខ្ញុំ ហើយយើងពីរនាក់បានពិភាក្សាគ្នា ។ យើងបានសន្និដ្ឋានថា ពិតជាមានសំណួរបីយ៉ាងដែលនឹងកំណត់ពីចម្លើយរបស់គាត់ទៅកាន់ឪពុករបស់យើង ។ ទីមួយគឺ « តើព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះនៃពិភពលោកមែនទេ ? » ទីពីរគឺ « តើព្រះគម្ពីរមរមនជាបន្ទូលរបស់ព្រះមែនទេ ? » និងទីបីគឺ « តើយ៉ូសែប ស៊្មីធគឺជាព្យាការីមែនទេ ? » ខ្ញុំបានដឹងថា ចម្លើយចំពោះសំណួរទាំងបីនោះនឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការសម្រេចចិត្តស្ទើរតែទាំងអស់ ដែលខ្ញុំនឹងធ្វើពេញមួយជីវិតខ្ញុំ ។

ខ្ញុំស្រឡាញ់ព្រះអង្គសង្គ្រោះជានិច្ច ហើយខ្ញុំបានអានព្រះគម្ពីរមរមន ប៉ុន្តែដោយដឹងថាចម្លើយទាំងនោះមានសារសំខាន់យ៉ាងណា នោះខ្ញុំបានអធិស្ឋាននៅរាត្រីនោះ ហើយបានទទួលចម្លើយតាមរយៈព្រះវិញ្ញាណបរិសុទ្ធនូវចម្លើយដ៏ជ្រាលជ្រៅមួយចំពោះសំណួរទាំងនោះ ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ ព្រះគម្ពីរមរមនជាបន្ទូលរបស់ព្រះ ហើយយ៉ូសែប ស៊្មីធ គឺជាព្យាការី ។ ខ្ញុំថ្លែងទីបន្ទាល់ថា រឿងទាំងនេះពិត ។

### អាពាហ៍ពិពាហ៍ពហុពន្ធភាព

ខ្ញុំចង់លើកឡើងបីចំណុច អំពីអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ ទីមួយ វាច្បាស់ថា មានការលះបង់ជាច្រើននៅក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ មាននូវសេចក្តីស្រឡាញ់ និងសាមគ្គីភាពជាច្រើន ប៉ុន្តែក៏មានការលះបង់ផងដែរ ហើយឪពុកម្តាយនៅក្នុងជីវិតអាពាហ៍ពិពាហ៍ទាំងនោះបានបង្រៀនកូនៗរបស់ពួកគេឲ្យលះបង់ ។ កូនៗជាច្រើននៃអាពាហ៍ពិពាហ៍ពហុពន្ធភាពទាំងនោះបានយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទៅជុំវិញពិភពលោក ហើយបានផ្តល់ពរជ័យដល់ជីវិតជាច្រើន ។

ទីពីរ មានមនុស្សមួយចំនួន ដូចជា វ៉ៃឡេត ឃិមបល ដែលបានទទួលវិវរណៈផ្ទាល់ខ្លួន—សូម្បីតែពីមុនពួកគេបានដឹងយ៉ាងពេញលេញអំពីអ្វីដែលនឹងកើតឡើងទៅទៀត—ថាគោលលទ្ធិនេះគឺមកពីព្រះ ។[២]

ហើយទីបី នៅក្នុងការប្រជុំក្រុមប្រឹក្សាជាន់ខ្ពស់នៃសាសនាចក្រ មានអារម្មណ៍មួយថា អាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានអនុវត្តដើម្បីបម្រើគោលបំណងមួយ ។ យើងគួរតែគោរពដល់ពួកបិសុទ្ធទាំងនោះ ប៉ុន្តែគោលបំណងនោះត្រូវបានបំពេញរួចហើយ ។

ឥឡូវ មាននូវសំណួរដែលមិនត្រូវបានឆ្លើយទាំងឡាយ ។ ប៉ុន្តែខ្ញុំចង់ឲ្យបងប្អូនដឹងថា យើងមានព្រះវរបិតាសួគ៌ជាទីស្រឡាញ់មួយអង្គ ដែលមានផែនការមួយដ៏ល្អឥតខ្ចោះ ថាផែនការរបស់ទ្រង់គឺជាផែនការនៃសុភមង្គល ថាយើងមានព្រះអង្គសង្គ្រោះមួយអង្គដែលបានធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់យើង ។ យើងអាចទុកចិត្តពួកទ្រង់បាន ។

**ហេតុអ្វីដំណើររឿងអំពីការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ មានភាពខុសគ្នាបន្តិចបន្តួច ?**

ដោយ ម៉ាត គ្រូ

យ៉ូសែប ស្ម៊ីធ បានកត់ត្រា ឬបានសុំឲ្យអ្នកសរសេរកំណត់ត្រារបស់លោកឲ្យកត់ត្រាដំណើររឿងបួនខុសៗគ្នាពីការនិមិត្តដំបូង ។ ដំណើររឿងទាំងអស់នោះប្រាប់ពីដំណើររឿងខ្ជាប់ខ្ជួន ប៉ុន្តែវាមានភាពខុសគ្នា ។ វាពុំគួរធ្វើឲ្យយើងភ្ញាក់ផ្អើលឡើយ ។ បើមានភាពឯកភាពពេញលេញក្នុងចំណោមដំណើររឿងទាំងនោះ នោះហើយជាពេលដែលខ្ញុំ ក្នុងនាមជាប្រវត្តិវិទូម្នាក់ នឹងមានការសង្ស័យ ព្រោះវាមិនមែនជាវិធីដែលការចងចាំដំណើរការនោះទេ ។ យើងមើលឃើញគំរូដូចគ្នានោះនៅក្នុងដំណើររឿងផ្សេងៗទៀតក្នុងប្រវត្តិសាស្ត្រ ឬក្នុងបទគម្ពីរ ( សូមមើល កិច្ចការ ៩:៧; ២២:៩ ) ។

សូមចងចាំផងដែរថា វាមានការលំបាកណាស់ដើម្បីរៀបរាប់ពីបទពិសោធន៍ពិសិដ្ឋមួយជាការនិយាយស្ដីនោះ ។ យ៉ូសែបបានហៅការនិយាយស្ដីថាជា « គុកដ៏តូចចង្អៀត » ( នៅក្នុង *ប្រវត្តិសាស្ត្រនៃសាសនាចក្រ* ១:២៩៩ ) ។ សូមគិតពីបទពិសោធន៍ដ៏ពិសិដ្ឋបំផុតរបស់អ្នក ។ តើវាងាយស្រួលដើម្បីរៀបរាប់ជាពាក្យសម្ដីដែរឬទេ ? យើងគួរតែអបអរដែលយើងមានដំណើររឿងច្រើន ដោយសារវាផ្ដល់ការយល់ដឹងថ្មី និងទស្សនវិស័យថ្មីដល់យើង ។ សូមទៅអានដំណើររឿងទាំងបួនអំពីការនិមិត្តដំបូងនៅក្នុងសំណេរប្រធានបទដំណឹងល្អ ( Gospel Topics essays ) ។ ការធ្វើដូច្នោះនឹងធ្វើឲ្យបងប្អូនកាន់តែមានអំណរគុណចំពោះអ្វីដែលបានកើតឡើងនៅថ្ងៃនោះ ។



**តើយូរីម និងធូមីមបានដើរតួអ្វីខ្លះនៅក្នុងការបកប្រែព្រះគម្ពីរមរមន ?**

ដោយ ខេត ហូលប្រ៊ូក

យ៉ូសែប ស្ម៊ីធ បានបកប្រែព្រះគម្ពីរមរមនដោយអំណោយទាន និងព្រះចេស្ដានៃព្រះ ។ យូរីម និងធូមីម ដែលបានលើកឡើងនៅក្នុងព្រះគម្ពីរមរមន ត្រូវបានកប់ទុកជាមួយនឹងផ្ទាំងចំណារទាំងនោះ ។ នៅពេលមរ៉ូណៃបានប្រគល់ផ្ទាំងចំណារមាសទៅយ៉ូសែប នោះលោកក៏បានប្រគល់យូរីម និងធូមីមផងដែរ ។ ត្បូងអ្នកមើលធុត ដែលយ៉ូសែបក៏បានប្រើប្រាស់ដើម្បីបកប្រែដែរនោះ ពុំត្រូវបានកប់ទុកជាមួយនឹងផ្ទាំងចំណារនោះទេ ។ វាគឺជាអ្វីមួយដែលយ៉ូសែបបានរកឃើញដោយខ្លួនឯងប៉ុន្មានឆ្នាំមុននោះដែលបានជួយលោកឲ្យងាយស្ដាប់តាមវិវរណៈខាងវិញ្ញាណ ។ ដូច្នេះលោកបានប្រើវាទាំងពីរ ។

អិមម៉ា ស្ម៊ីធ ជាអ្នកសរសេរម្នាក់របស់លោក ក្រោយមកបានចងចាំថា នៅពេលណាយ៉ូសែបបានអង្គុយចុះដើម្បីចាប់ផ្ដើមបកប្រែម្ដងទៀត លោកពុំដែលសួរថា « ឥឡូវខ្ញុំដល់ត្រង់ណាហើយ ? តើខ្ញុំបានឈប់នៅត្រង់ណា ? » នោះទេ ។ លោកបានចាប់ផ្ដើមត្រង់កន្លែងដែលពួកលោកបានបញ្ឈប់ ។ បើអ្នកមើលទៅទំព័រមួយនៃសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់យ៉ូសែប ស្ម៊ីធ ដែលលោកបានសរសេរបីឆ្នាំក្រោយពីការបកប្រែព្រះគម្ពីរមរមន វាមានសុទ្ធតែពាក្យដែលគូសចោល គំនិតមិនពេញលេញ ប្រយោគដែលខ្វះខាត ។ នៅពេលអ្នកមើលទៅទំព័រមួយនៃព្រះគម្ពីរមរមនដែលបានហៅឲ្យសរសេរនោះគ្មានរឿងទាំងនោះឡើយ ។ វាពេញលេញ មានពាក្យដ៏ពិរោះ—ប្រយោគពេញលេញ គ្មានការគូសចោលទេ ។

រឿងទាំងអស់នេះគួរឲ្យចាប់អារម្មណ៍ណាស់បើគិតទៅ ប៉ុន្តែអ្វីដែលសំខាន់ចំពោះខ្ញុំជាងនេះ គឺជាបរិបទរបស់ព្រះគម្ពីរមរមន ។ ព្រះគម្ពីរមរមនគឺជាកន្លែងដែលស្ដេចបេនយ៉ាមីនបានបង្រៀនខ្ញុំឲ្យផ្ដល់អាទិភាពលើចិត្តសប្បុរសមុនការវិនិច្ឆ័យ ជាកន្លែងដែលអាលម៉ាបានបង្រៀនខ្ញុំអំពីអត្ថន័យនៅពេលដែលខ្ញុំបានជ្រមុជទឹក អ្វីដែលខ្ញុំសន្យាធ្វើសម្រាប់ពួកបរិសុទ្ធដទៃទៀត ។ ហើយព្រះគម្ពីរមរមនគឺជាកន្លែងដែលមរមន និងមរ៉ូណៃបានបង្រៀនខ្ញុំអំពីសារៈសំខាន់នៃសេចក្ដីសប្បុរស និងអ្វីដែលត្រូវធ្វើដើម្បីទទួលបានវា ។ ព្រះគម្ពីរនេះបានជួយលត់ដំខ្ញុំ និងបានបង្រៀនពីរបៀបដែលខ្ញុំមើលពិភពលោកនេះ ។

ខាងឆ្វេង ៖ រូបភាពដោយ ជើង ប្រ៊ីន



## ហេតុអ្វីពួកគេអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅក្នុងជំនាន់ដំបូងៗនៃសាសនាចក្រ ?

ដោយ ខេត ហូលប្រ៊ូក

ការណែនាំក្នុងព្រះគម្ពីរមរមនអំពីអាពាហ៍ពិពាហ៍ពហុពន្ធភាពចែងថា អាពាហ៍ពិពាហ៍ឯកពន្ធគឺជាព្រះរាជបំណងរបស់ព្រះអម្ចាស់សម្រាប់រាស្ត្រទ្រង់ ប៉ុន្តែមាននូវការលើកលែងដ៏កម្រពេលទ្រង់បញ្ជាឲ្យមានការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពដើម្បីចិញ្ចឹមបីបាច់មនុស្សសុចរិត ( សូមមើល យ៉ាកុប ២:៣០ ) ។ នេះគឺជាករណីលើកលែងដ៏កម្រដែលយ៉ូសែប ស្ម៊ីធ ត្រូវបានបង្គាប់ឲ្យចាប់ផ្ដើម ។ យ៉ូសែបបានពន្យារពេលអស់រាប់ឆ្នាំក្នុងការអនុវត្តតាមការបញ្ជានេះ ប៉ុន្តែនៅទីបំផុត លោកបានអនុវត្តវា ដោយសារលោកចង់គោរពតាមបទបញ្ញត្តិរបស់ព្រះចំពោះលោក ។ លោកបានសាកល្បងអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពនៅពាក់កណ្ដាលទសវត្សរ៍ ១៨៣០ ប៉ុន្តែលុះដល់ឆ្នាំ ១៨៤១ ទើបលោកបានចាប់ផ្ដើមណែនាំបន្តិចម្ដងៗជាផ្លូវការអំពីការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាពដល់សហការីដែលលោកទុកចិត្ត ។ ពួកគេបានមានការតក់ស្លុត ។ ពួកគេបានទូលអង្វរក្នុងការអធិស្ឋានជាមួយនឹងព្រះវរបិតាសួគ៌សូមការយល់ដឹងអំពីគោលការណ៍នេះ ហើយពួកគេបានទទួលសាក្សីខាងវិញ្ញាណផ្ទាល់ខ្លួនថា វាគឺត្រឹមត្រូវសម្រាប់ពួកគេនៅពេលនោះ ។

អាពាហ៍ពិពាហ៍ពហុពន្ធភាពត្រូវបានអនុវត្តជាផ្លូវការអស់ប្រហែលជា ៥០ ឆ្នាំ នោះវាគឺជាអ្វីមួយដែលមនុស្សអាចជ្រើសរើស ។ ពួកអ្នកប្រាជ្ញនៅតែកំពុងព្យាយាមកំណត់ពីចំនួនថាតើមជ្ឈិមវ័យពួកបរិសុទ្ធថ្ងៃចុងក្រោយប៉ុន្មាននាក់ដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយពិតជាបានចូលរួមក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាព ប៉ុន្តែយើងដឹងជាទូទៅថា មានភាគតិចនៃពួកបរិសុទ្ធថ្ងៃចុងក្រោយប៉ុណ្ណោះ ។ ហើយយើងដឹងថា ពួកគេភាគច្រើនគឺជាសមាជិកដ៏ស្មោះត្រង់ រឹងមាំបំផុតរបស់សាសនាចក្រយើង ។ នៅឆ្នាំ ១៨៩០ ប្រធាន វិលហ្វ៊ូឌ វូឌ្រុព្វ ( ១៨០៧–៩៨ ) បានចេញផ្សាយសេចក្ដីថ្លែងការណ៍មួយដើម្បីបញ្ចប់ការអនុវត្តអាពាហ៍ពិពាហ៍ពហុពន្ធភាព ។ ហើយនៅពេលមនុស្សមួយចំនួនបានឮសេចក្ដីថ្លែងការណ៍នេះ ពួកគេបានធូរស្បើយក្នុងចិត្ត ។ អាពាហ៍ពិពាហ៍ពហុពន្ធភាពមានការលំបាកសម្រាប់ពួកគេ ។ នៅពេលមនុស្សផ្សេងទៀតបានឮសេចក្ដីថ្លែងការណ៍នេះ ពួកគេខ្វិចខ្វាំក្នុងចិត្ត ។ ពួកគេបានលះបង់យ៉ាងច្រើន ហើយពួកគេមានទីបន្ទាល់អំពីគោលការណ៍នេះ ។

សមាជិកសាសនាចក្រមួយចំនួនឆ្ងល់ថាតើការអនុវត្តពីអតីតកាលរបស់យើងទៅលើអាពាហ៍ពិពាហ៍ពហុពន្ធភាពមានន័យយ៉ាងណាសម្រាប់ជីវិតបន្ទាប់ពីនេះ ។ ថ្នាក់ដឹកនាំសាសនាចក្រយើងបានបង្រៀនយើងថា អាពាហ៍ពិពាហ៍ពហុពន្ធភាពពុំមែនជារឿងចាំបាច់សម្រាប់ភាពតម្កើងឡើង ឬសម្រាប់សិរីល្អដ៏អស់កល្បនោះទេ ។ ថ្វីបើខ្ញុំផ្ទាល់មានអំណរគុណដែលអាពាហ៍ពិពាហ៍ឯកពន្ធគឺជាច្បាប់ ហើយថាអាពាហ៍ពិពាហ៍ពហុពន្ធភាពជាការលើកលែង ក៏ខ្ញុំពុំបន្ទាបតម្លៃនៃទីបន្ទាល់ និងការប្រតិបត្តិដ៏គួរឲ្យគោរពរបស់បុព្វការីជនខាងវិញ្ញាណរបស់យើងដែលបានអនុវត្តគោលការណ៍នេះដែរ ។ ពួកគាត់គោរពប្រតិបត្តិ ហើយពួកគាត់មានទីបន្ទាល់មួយថាវាត្រឹមត្រូវ ។

## ព្រះវិហារបរិសុទ្ធ និងសេចក្ដីសញ្ញា

នៅខឺតឡង់ អូហៃអូ មានរឿងអស្ចារ្យមួយដែលបានកើតឡើងគឺព្រះវិហារបរិសុទ្ធខឺតឡង់ និងការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធខឺតឡង់ ។ ការអធិស្ឋានឧទ្ទិសឆ្លង ដែលយ៉ូសែប ស្ម៊ីធ បានទទួលដោយវិវរណៈ មាននៅក្នុងកណ្ឌ ១០៩ ក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ។ នៅក្នុងការអធិស្ឋាននោះ លោកបានទូលសូមព្រះអម្ចាស់ឲ្យទទួលយកស្នាដៃការងារ និងការលះបង់នៅក្នុងការសាងសង់ព្រះវិហារបរិសុទ្ធនោះ ។

មួយសប្ដាហ៍បន្ទាប់ពីការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធ យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី បានមានការនិមិត្តមួយទៀត ។ ការណ៍នេះបានកើតឡើងនៅបុណ្យអ៊ីស្ទើរ ដែលជាបុណ្យរំលងផងដែរ ។ ព្រះអម្ចាស់បានយាងមកនៅក្នុងការនិមិត្ត ហើយបានទទួលយកដំណាក់នោះ ។ ទ្រង់បានប្រាប់ពួកបរិសុទ្ធថា ពួកគេគួរតែរីករាយដែល « បានសង់ដំណាក់នេះថ្វាយដល់ព្រះនាមរបស់យើងដោយអស់ពីកម្លាំងរបស់ពួកគេ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:៦ ) ។ បន្ទាប់ពីការនិមិត្តបានបញ្ចប់ ព្យាការីពីបុរាណបានលេចមក ៖ ម៉ូសេ ដែលបានស្ដារឡើងវិញនូវកូនសោទាំងឡាយសម្រាប់ការប្រមូលផ្ដុំវង្សអ៊ីស្រាអែលពីផ្នែកទាំងបួននៃផែនដី អេលីយ៉ាស ដែលបានប្រគល់គ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អរបស់អ័ប្រាហាំ និង អេលីយ៉ា ដែលបានស្ដារឡើងវិញនូវកូនសោនៃអំណាចផ្សារភ្ជាប់ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១១០:១១–១៦ ) ។

ការស្ដារឡើងវិញនៃកូនសោទាំងនោះគឺពិតជាសំខាន់ដើម្បីសម្រេចបាននូវព្រះរាជបំណងរបស់ព្រះអម្ចាស់ ។ យើងមិនត្រឹមតែត្រូវការព្រះគម្ពីរមរមនប៉ុណ្ណោះទេ ប៉ុន្តែកូនសោ និងពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធផងដែរ ។ កូនសោទាំងនោះមានសារៈសំខាន់ខ្លាំងណាស់នៅពេលនេះ ជាងពេលណាៗទាំងអស់ ។

ខ្ញុំបានសង្កេតឃើញថា នៅពេលសាវកម្នាក់ក្នុងចំណោមសាវកដប់ពីរនាក់ត្រូវបានហៅជាព្យាការី នោះដួងចិត្តរបស់ពួកលោកបានងាកទៅរកពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធតាមរបៀបមួយដ៏អស្ចារ្យ ។ ខ្ញុំមានឯកសិទ្ធិបាននៅទីនេះអំឡុងពេលឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធណៅវូអិលលីណោយជាមួយនឹងប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) ។ ខ្ញុំអាចចងចាំថា វាបានរំជួលចិត្តលោកយ៉ាងខ្លាំង ក្នុងការ



ខាងលើ ៖ ព្រះវិហារបរិសុទ្ធខឺតឡង់ ដោយ អាល រ៉ោនស៍ ខាងស្ដាំ ៖ ម៉ូសេ, អេលីយ៉ាស និងអេលីយ៉ា ដោយ វ៉ល្ដឺ រ៉េនែស ស្មីធ

ធ្វើឲ្យព្រះវិហារបរិសុទ្ធនេះត្រូវបានសង់ឡើង ហើយថាវាសំខាន់ខ្លាំងយ៉ាងណាចំពោះលោក ដើម្បីនាំឲ្យមានព្រះវិហារបរិសុទ្ធទាំងឡាយ ដល់ពួកបរិសុទ្ធ ។ប្រធាន ថូម៉ាស អេស ម៉នសុ ( ១៩២៧–២០១៨ ) បានបន្តកិច្ចខិតខំនោះ ហើយបានទទួលការបំផុសគំនិតមកពីស្ថានសួគ៌ដូចគ្នានឹងប្រធានហ៊ិងគ្លីដែរ ។ ហើយយើងបានឃើញការបំផុសគំនិតនោះជាមួយនឹងប្រធានណិលសុន តាមរបៀបមួយដ៏អស្ចារ្យ ។ ការទទួលខុសត្រូវរបស់ព្យាការីបានធ្លាក់មកលើលោក ហើយលោកមានការយល់ដឹងកាន់តែច្រើនអំពីតម្លៃនៃពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធ ។

សារលិខិតដំបូងមួយរបស់លោកក្នុងនាមជាប្រធាននៃសាសនាចក្រ គឺដើម្បីលើកទឹកចិត្តដល់មនុស្សឲ្យទៅព្រះវិហារបរិសុទ្ធ ទទួលពិធីបរិសុទ្ធរបស់ពួកគេ និងបន្តនៅលើផ្លូវនៃសេចក្ដីសញ្ញា ។ ភ្លាមៗបន្ទាប់ពីនោះ លោកបានមានប្រសាសន៍ថា ប្រសិនបើមានមូលហេតុណាមួយដែលអ្នកធ្លាក់ចេញពីផ្លូវនៃសេចក្ដីសញ្ញា នោះចូរត្រឡប់មកលើផ្លូវនោះវិញ ។[៣]



**តើកិច្ចការព្រះវិហារបរិសុទ្ធផ្ដល់ពរដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយជំនាន់ដើមយ៉ាងដូចម្ដេច ?**

ដោយ ម៉ាត គ្រូ

ពេលយ៉ូសែប ស្ម៊ីធ បានទទួលមរណភាព ជញ្ជាំងរបស់ព្រះវិហារបរិសុទ្ធណៅវូទើបតែធ្វើបានតិចជាងពាក់កណ្ដាល ហើយមិនយូរប៉ុន្មាន ប្រធាន ព្រិកហាំ យ៉ង់ ( ១៨០១–៧៧ ) បានដឹងច្បាស់ថា ពួកបរិសុទ្ធនឹងត្រូវបានបណ្ដេញចេញម្ដងទៀត ។ ដូច្នេះលោកបានទូលសួរព្រះអម្ចាស់ ៖ « តើយើងគួរបន្តនៅបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធនោះ ដោយដឹងថា យើងនឹងត្រូវបោះបង់វាចោល នៅពេលវាសង់ជិតរួចរាល់ភ្លាមនោះ ឬយើងគួរចេញទៅនៅពេលនេះ ? » ចម្លើយគឺបានមកដោយច្បាស់លាស់ថា « បន្ត » ( សូមមើល កំណត់ហេតុរបស់ព្រិកហាំ យ៉ង់ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៨៤៥ បណ្ណាសាររបស់សាសនាចក្រ Ronald K. Esplin « Fire in His Bones » *Ensign* ខែ មីនា ឆ្នាំ ១៩៩៣ ទំព័រ ៤៦ ) ។ ពិធីបរិសុទ្ធនៃអំណោយទានពិសិដ្ឋ និងពិធីបរិសុទ្ធនៃការផ្សារភ្ជាប់គឺមានសារៈសំខាន់ណាស់រហូតដល់ពួកបរិសុទ្ធត្រូវបន្តស្នាក់នៅទីនោះ ។

ដូច្នេះនៅឆ្នាំបន្ទាប់នោះ ពួកគេបានផ្ដល់នូវអ្វីៗទាំងអស់ដែលពួកគេបានមានដើម្បីសាងសង់ព្រះវិហារបរិសុទ្ធ ។ ទម្រាំដល់ការបញ្ចប់ ផ្ទះរបស់ពួកគេត្រូវបានដុតបំផ្លាញនៅជុំវិញទីក្រុងណៅវូ ហើយពួកបរិសុទ្ធកំពុងរៀបចំធ្វើដំណើរទៅទិសខាងលិចកាលដែលពួកគេកំពុងបញ្ចប់ការសាងសង់ព្រះវិហារបរិសុទ្ធ ។ នៅខែធ្នូ ឆ្នាំ១៨៤៥ ព្រះវិហារបរិសុទ្ធត្រូវបានសង់ចប់ល្មមគ្រប់គ្រាន់ ពួកបរិសុទ្ធអាចឧទ្ទិសឆ្លងមួយផ្នែកនៃព្រះវិហារបរិសុទ្ធ ផ្ដល់អំណោយទានពិសិដ្ឋដល់ពួកអ្នកដែលសក្តិសម ហើយផ្សារភ្ជាប់ស្វាមី និងភរិយា ។

ពួកគេបានធ្វើការឥតស្រាកស្រាន្តពីរបីខែក្រោយនោះ ដើម្បីរៀបចំខ្លួនមនុស្សគ្រប់គ្នាខាងវិញ្ញាណសម្រាប់ដំណើរដ៏ធំទៅទិសខាងលិចនោះ ។ ចំពោះខ្ញុំ វាពិតជាអស្ចារ្យ ហើយពិតជាពិសិដ្ឋ ដោយសារខ្ញុំបានផ្សារភ្ជាប់ជាមួយនឹងភរិយា កូនៗ ឪពុកម្ដាយរបស់ខ្ញុំ និងជំនាន់ពីមុនខ្ញុំ និងជាមួយនឹងជំនាន់ដែលពុំកើតនៅឡើយ ដោយសារតែអំណាចដូចគ្នានោះ ។ នោះគឺជាអ្វីដែលការស្ដារឡើងវិញបានធ្វើឲ្យកើតមានឡើង ។

**តើអ្នកអាចចែកចាយព្រឹត្តិការណ៍មួយចេញពីការស្ដារឡើងវិញដែលបានពង្រឹងទីបន្ទាល់របស់អ្នកបានដែរឬទេ ?**

ដោយ ខេត ហូលប្រ៊ូក

ខ្ញុំចាំពីរឿងរបស់អិមម៉ា ស្ម៊ីធ ដែលព្យាយាមគេចពីការធ្វើទុក្ខបុកម្នេញនៅរដ្ឋមិសសួរី ។ ទន្លេមិស៊ីស៊ីពពីកកតែមួយផ្នែកប៉ុណ្ណោះ—មិនគ្រប់គ្រាន់ដើម្បីឲ្យរទេះជាមួយមនុស្ស និងរបស់របររបស់ពួកគេធ្វើដំណើរលើនោះទេ ។ វាជាទន្លេដ៏ធំមួយ ហើយវាគ្រោះថ្នាក់ដើម្បីឆ្លងកាត់ ។ អិមម៉ា និងកូនម្នាក់អាយុប្រាំមួយឆ្នាំកំពុងតោងសំពត់នាងនៅម្ខាង កូនអាយុប្រាំបីឆ្នាំតោងនៅម្ខាងទៀត បីកូនអាយុពីរឆ្នាំនៅដៃម្ខាងនេះ និងកូនតូចនៅដៃម្ខាងនោះ ។

បងថ្លៃស្រីរបស់អ្នកសរសេរម្នាក់របស់យ៉ូសែបបានដេរថង់ក្រណាត់កប្បាសដែលមានខ្សែរនៅជុំវិញចង្កេះ ។ អិមម៉ាបានស្ពាយការបកប្រែព្រះគម្ពីរប៊ីបរបស់យ៉ូសែបដែលមានតែមួយច្បាប់គត់នៅក្នុងថង់ក្រណាត់ទាំងនោះនៅខាងក្រោមសំពត់របស់គាត់ ដែលយ៉ូសែបបានបកប្រែអស់ជាច្រើនខែ ។ ដោយមានឯកសារ និងកូនៗរបស់គាត់ គាត់បានដើរម្ដងមួយជំហានម្ដងៗកាត់ទន្លេកកនោះ ដោយសង្ឃឹមថាគាត់នឹងពុំផុងចុះឡើយ ។

ចំពោះខ្ញុំ វាគឺជាសញ្ញាពេញលេញនៃភាពក្លាហាន និងសេចក្ដីជំនឿ—នោះហើយជាពេលដែលអ្នកត្រូវធ្វើអ្វីមួយសម្រាប់អ្វីដែលអ្នកជឿ អ្នកត្រូវដើរឆ្ពោះទៅមុខមួយជំហានម្ដងៗ ។

ខាងឆ្វេង ៖ ទេព្យកោសល្យដោយ ដើង ប្រ៊ីន









**« ចូរសង្ឃឹមឡើង »**

ប្អូនៗជាច្រើនមានការសោកល្បង និងទុក្ខវេទនា ។ ការលំបាកមួយចំនួនទាំងនោះកើតឡើងដោយសារតែការមានសិទ្ធិជ្រើសរើស ។ ការលំបាកខ្លះទៀតដោយសារមានមារសត្រូវ ។ ប៉ុន្តែអ្នកចាំបាច់ត្រូវដឹងថា យើងមានព្រះវរបិតាជាទីស្រឡាញ់មួយអង្គដែលគង់នៅស្ថានសួគ៌ ហើយដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអាចផ្តល់ពរដល់យើងតាមរបៀបដែលយើងប្រហែលជាពុំយល់ពេញលេញនោះទេ ។

ប្រវត្តិវិទូមួយចំនួននិយាយថា ចំនួននៃពួកបរិសុទ្ធដែលបានគេចខ្លួនពីរដ្ឋមិសសួរីទៅទីក្រុងណៅវូអំឡុងរដូវរងាឆ្នាំ ១៨៣៨–៣៩ គឺខ្ពស់ដល់ទៅ ៨០០០ នាក់ ។ វាជារដូវរងា ។ តើយ៉ូសែបនៅទីណា ? លោកនៅក្នុងគុកលីប៊ើធី ខូចចិត្តជាខ្លាំងដោយសារពួកបរិសុទ្ធកំពុងជួបហេតុការណ៍នេះ ។ លោកបានមានអារម្មណ៍ថាលោកត្រូវបានបោះបង់ចោល ។

នៅក្នុងកាលៈទេសៈដ៏គ្រោះថ្នាក់នេះ លោកបានទទួលបទគម្ពីរដ៏ល្អអស្ចារ្យបំផុតមួយចំនួន—កណ្ឌទី ១២១, ១២១ និង ១២៣ នៃគោលលទ្ធិ និងសេចក្តីសញ្ញា ។ បទគម្ពីរទាំងនោះគឺសំខាន់ ។ ខ្ញុំសង្ឃឹមថា បងប្អូននឹងអានវា ។ *ពួកបរិសុទ្ធ*មាននូវដំណើររឿងខ្លីមួយអំពីព្រឹត្តិការណ៍នេះ ៖

« យ៉ូសែបបានស្រែកយំជំនួសឲ្យពួកបរិសុទ្ធដែលគ្មានទោសកំហុស ។ លោកបានទូលអង្វរថា ‹ ឱព្រះអម្ចាស់អើយ តើពួកគេត្រូវរងទុក្ខចំពោះកំហុស និងការសង្កត់សង្កិនដ៏ខុសច្បាប់ទាំងនេះដល់ណាទៅ មុនព្រះហឫទ័យរបស់ទ្រង់នឹងបានទន់ទៅរកពួកគេ ? ›

« ព្រះអម្ចាស់បានមានបន្ទូលតបថា ‹ បុត្រយើងអើយ ចូរមានសេចក្តីសុខសាន្តដល់ព្រលឹងបុត្រចុះ › ។ ‹ សេចក្តីទំនាស់ និងសេចក្តីទុក្ខលំបាករបស់អ្នក នោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ ហើយខណៈនោះ បើសិនជាអ្នកស៊ូទ្រាំការណ៍នោះដោយហ្មត់ចត់ នោះព្រះទ្រង់នឹងតម្កើងអ្នកឡើងនៅស្ថានខ្ពស់ អ្នកនឹងបានជ័យជម្នះលើពួកខ្មាំងសត្រូវរបស់អ្នកទាំងអស់ › ។

« ព្រះអម្ចាស់បានអះអាងនឹងយ៉ូសែបថា លោកពុំត្រូវបានបំភ្លេចចោលឡើយ ។ ព្រះអម្ចាស់បានមានបន្ទូលប្រាប់យ៉ូសែបថា ‹ បើសិនជាចង្កាមាត់នៃស្ថាននរកនឹងហារត្របាក់អ្នកក្តី បុត្រយើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះ នឹងផ្តល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ › ។

« ព្រះអង្គសង្គ្រោះបានរំឭកយ៉ូសែបថា ពួកបរិសុទ្ធពុំអាចរងទុក្ខច្រើនជាងទ្រង់ទេ ។ ទ្រង់ស្រឡាញ់ពួកគេ ហើយអាចបញ្ចប់ការឈឺចាប់របស់ពួកគេបាន ប៉ុន្តែផ្ទុយទៅវិញ ទ្រង់បានជ្រើសរងទុក្ខលំបាកជាមួយនឹងពួកគេ ដោយយកការឈឺចាប់ និងភាពសោកសៅរបស់ពួកគេជាផ្នែកមួយនៃពលិកម្មធួនរបស់ទ្រង់ ។ ការរងទុក្ខបែបនេះបានបំពេញទ្រង់ដោយសេចក្តីមេត្តាករុណា ដោយប្រទានអំណាចចំពោះទ្រង់ដើម្បីជួយ ហើយសម្រាំងមនុស្សទាំងអស់ដែលបានងាកមករកទ្រង់នៅក្នុងការសោកល្បងរបស់ពួកគេ ។ ទ្រង់បានលើកទឹកចិត្តយ៉ូសែបឲ្យស៊ូទ្រាំ ហើយបានសន្យាថា ទ្រង់នឹងពុំភ្លេចលោកឡើយ » ។

អែលឌើរ ហ៊ីប៊ើរ ស៊ី ឃិមបឹល ( ១៨០១–៦៨ ) ធ្លាប់គិតថា ពួកចៅក្រមនៃតុលាការកំពូលមិសសួរីនឹងដោះលែងយ៉ូសែប ប៉ុន្តែពួកគេបានសម្រេចចិត្តមិនដោះលែងវិញ ។ ហ៊ីប៊ើរបានត្រឡប់ទៅគុកលីប៊ើធីវិញ ហើយដោយមិនត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងគុកងងឹតនោះ បានស្រែកប្រាប់យ៉ូសែបនូវដំណឹងអាក្រក់នោះ ។

យ៉ូសែបផ្តល់ភាពកក់ក្តៅ ហើយរាក់ទាក់ទៅកាន់គាត់ ។ លោកបានមានប្រសាសន៍ថា « ចូរសង្ឃឹមឡើង » ។ បន្ទាប់មកលោកបានណែនាំហ៊ីប៊ើរឲ្យ « ប្រមូលពួកបរិសុទ្ធទាំងអស់ឲ្យចាកចេញទៅឆ្ងាយឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន » ។[៤]

មានមេរៀនមួយសម្រាប់បងប្អូននៅក្នុងរឿងនេះ ៖ ចូរសង្ឃឹមឡើងមិនថាបងប្អូនមានឧបសគ្គអ្វីនោះទេ ។ បើបងប្អូនមានរឿងដែលកំពុងល្បងបងប្អូន ចូរចេញឆ្ងាយពីវា ។ ពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ ។ គំរូរបស់យ៉ូសែបនៅក្នុងគុកលីប៊ើធី និងពួកបរិសុទ្ធភៀសខ្លួនមកពីរដ្ឋមិសសួរីទៅទីក្រុងណៅវូ គឺជាគំរូមួយដ៏អស្ចារ្យអំពីភាពរឹងមាំ និងសេចក្តីជំនឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។

ក្នុងនាមជាសាវកមួយរូប ខ្ញុំសូមថ្លែងជាសាក្សីពីព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំជាសាក្សីដ៏ពិតមួយអំពីភាពជាព្រះរបស់ទ្រង់ ។ ខ្ញុំចង់ឲ្យបងប្អូនដឹងថា ទ្រង់ដឹកនាំ ហើយណែនាំសាសនាចក្រនេះតាមរបៀបមួយដែលនឹងប្រទានពរដល់យើងគ្រប់គ្នា ។ ខ្ញុំសូមថ្លែងទីបន្ទាល់ដល់បងប្អូនថា ទ្រង់មានព្រះជន្មរស់ ។ ■

*ដើម្បីមើលការប្រជុំធម្មនិដ្ឋាននេះទាំងមូល សូមទៅកាន់គេហទំព័រ devotionals .ChurchofJesusChrist.org ។*

**កំណត់ចំណាំ**

១. ប្រភពទាំងនេះអាចរកបាននៅ history.ChurchofJesusChrist.org ។
២. សូមមើល Orson F. Whitney *Life of Heber C. Kimball* ( ១៩៤៥ ) ទំព័រ ៣២៧ ។
៣. សូមមើល រ័សុល អិម ណិលសុន « As We Go Forward Together » *Liahona* ខែ មេសា ឆ្នាំ ២០១៨ ទំព័រ ៧ ។
៤. សូមមើល *ពួកបរិសុទ្ធ ៖ រឿងអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ វ៉ុល ១ បទដ្ឋាននៃសេចក្តីជំនឿ ១៨១៥–១៨៤៦* ( ឆ្នាំ ២០១៨ ) ទំព័រ ៣៨៩–៩០ saints .ChurchofJesusChrist.org ។

ខាងលើ ៖ រូបភាពដោយ ដាន់ ប៊ឺ *អគ្គីហេតុនៅឃើនស៊ី* ដោយ ជូលី រ៉ូជើរ *យ៉ូសែប ស្ម៊ីធ នៅក្នុងគុកលីប៊ើធី* ដោយ ហ្គ្រេក ខេ អុលសិន

# គិតពីពួកអ្នកត្រួសត្រាយផ្លូវនៅប្រទេសឥណ្ឌា

**ដោយ ថៅណាលីន រូស័រហ្វ៊ត**
ជំនួយសាស្ត្រាចារ្យ ការអប់រំខាងសាសនា សាកលវិទ្យាល័យព្រិកហាំ យ៉ង់

ការជួបជាមួយនឹងសមាជិកសាសនាចក្រដែលជាអ្នកត្រួសត្រាយផ្លូវនៅក្នុងប្រទេសឥណ្ឌា បានផ្លាស់ប្ដូររបៀបដែលខ្ញុំគិតអំពីពួកអ្នកត្រួសត្រាយផ្លូវ ។

ដូចដែលចម្រៀងកុមារច្រៀងថា « ពេលដែលខ្ញុំគិតពីពួកអ្នកត្រួសត្រាយផ្លូវ ខ្ញុំគិតពីបុរសស្ត្រីក្លាហាន » ។[១] រឿងរ៉ាវទាំងឡាយរបស់ពួកអ្នកត្រួសត្រាយផ្លូវបរិសុទ្ធថ្ងៃចុងក្រោយដែលបានធ្វើការណ៍ទាំងឡាយដោយស្មោះត្រង់ដែលអ្នកដទៃទៀតមិនអាចធ្វើ តែងតែបំផុសដល់ខ្ញុំ ។ ក្នុងនាមជាម្ដាយវ័យក្មេង រឿងរ៉ាវរបស់ស្ត្រីត្រួសត្រាយផ្លូវរំឭកខ្ញុំពីពរជ័យថ្ងៃចុងក្រោយរបស់ខ្ញុំ ។ ខ្ញុំអាចសម្រាលកូននៅក្នុងមន្ទីរពេទ្យជំនួសឲ្យនៅក្នុងរទេះរុញ !

និយមន័យនៃអ្នកត្រួសត្រាយផ្លូវម្នាក់គឺជា « មនុស្សម្នាក់ដែលបានទៅពីមុនដើម្បីរៀបចំ ឬបើកផ្លូវសម្រាប់អ្នកផ្សេងទៀតឲ្យដើរតាម »[២] ពិពណ៌នាអំពីពួកអ្នកត្រួសត្រាយផ្លូវបរិសុទ្ធថ្ងៃចុងក្រោយនៅលើផ្លូវរទេះ ប្រមូលផ្ដុំទៅកាន់ទីក្រុងស៊ីយ៉ូន ។ ប៉ុន្តែវាក៏ពិពណ៌នាអំពីពួកអ្នកត្រួសត្រាយផ្លូវសម័យទំនើប និងផ្លូវនៃសេចក្ដីជំនឿដែលពួកគេនាំទៅកាន់ទូទាំងពិភពលោក ។

ពេលដែលកូនទាំងប្រាំរបស់ខ្ញុំចុះឈ្មោះចូលរៀននៅសាលា ខ្ញុំបានចាប់ផ្ដើមឧត្ដមសិក្សាផ្នែកប្រវត្តិសាស្ត្រសាសនា ។ ខ្ញុំបានជ្រើសរើសដើម្បីស្រាវជ្រាវលើសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនៅក្នុងប្រទេសឥណ្ឌា ជាប្រធានបទសម្រាប់បរិមាធិប្បាយថ្នាក់បណ្ឌិតរបស់ខ្ញុំ ។ ការស្រាវជ្រាវរបស់ខ្ញុំនៅក្នុងប្រទេសឥណ្ឌាបានផ្លាស់ប្ដូររបៀបដែលខ្ញុំគិតអំពីពួកអ្នកត្រួសត្រាយផ្លូវ ។



*បេសកកម្មមួយត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងបាងហ្គាឡូនៅក្នុងឆ្នាំ ១៩៩៣ ហើយព្រះវិហារបរិសុទ្ធមួយនឹងត្រូវបានសាងសង់នៅក្នុងពេលឆាប់ៗនេះ ។*



*បងប្អូន ស៊ូវ៉ារណា និងសារ៉ាឡា កាទូកា បានចូលព្រះវិហារនៅក្នុងឆ្នាំ ១៩៨៤ ហើយក្រោយមកបានបម្រើបេសកកម្ម ។*

## សសរនៃសាសនាចក្រ

ជាច្រើនឆ្នាំមុន ជានិស្សិតមហាវិទ្យាល័យម្នាក់នៅក្នុងឆ្នាំ ១៩៨៦ ខ្ញុំបានធ្វើដំណើរទៅទ្វីបអាស៊ីភាគខាងត្បូងជាមួយឯកអគ្គរដ្ឋទូតនៃសាកលវិទ្យាល័យព្រិកហាំយ៉ង់ ។ វាជាបទពិសោធន៍ដ៏ផ្លាស់ប្ដូរជីវិតមួយដែលរួមមានទាំងការចំណាយពេលមួយថ្ងៃនៅក្នុងទីក្រុងកាលកូតតា ( ឥឡូវនេះហៅថា កុលកាតា ) ជាមួយអ្នកម្ដាយថេរ៉េសា ។ វាជាការរំភើបដូចគ្នាដែរដែលបានជួបនឹងពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលជាពួកអ្នកត្រួសត្រាយផ្លូវសម័យទំនើបនៅក្នុងប្រទេសឥណ្ឌា និងប្រទេសស្រីលង្កា ។

សមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងនេះគឺ រ៉ា យូម៉ា ដែលបានរកឃើញសាសនាចក្រពេលគាត់បានចូលរួមមើលការសម្ដែងមួយរបស់ក្រុមឯកអគ្គរដ្ឋទូតវ័យក្មេងនៃសាកលវិទ្យាល័យព្រិកហាំយ៉ង់នៅក្នុងឆ្នាំ ១៩៨២ ។ ពេលយើងបានជួបគាត់ គាត់ទើបតែបានត្រឡប់មកពីបេសកកម្មរបស់គាត់វិញនៅទីក្រុងហ្វ្រេស្នូ រដ្ឋកាលីហ្វញ៉ា ស.រ.អា. ។ គាត់នៅតែពាក់ស្លាកឈ្មោះអ្នកផ្សព្វផ្សាយសាសនារបស់គាត់ ហើយបន្តបង្រៀនដល់នរណាដែលនឹងស្ដាប់នៅក្នុងទីក្រុងដេលី ។ រ៉ាគឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកប្រហែលជា ៦០០ នាក់នៅក្នុងប្រទេសឥណ្ឌានៅពេលនោះ ប៉ុន្តែ ចំពោះខ្ញុំ គាត់ហាក់បីដូចជាពួកបរិសុទ្ធតែម្នាក់នៅក្នុងសមុទ្រដែលមានមនុស្សរាប់លាននាក់ ។

ខ្ញុំត្រូវបានបំផុសគំនិតដោយគំរូរបស់ រ៉ា យូម៉ា កាលដែលខ្ញុំបានជ្រើសរើសដើម្បីបម្រើបេសកកម្មផងដែរ ។ រ៉ាក៏បានត្រួសត្រាយផ្លូវនៃសេចក្ដីជំនឿសម្រាប់ពួកអ្នកផ្សព្វផ្សាយសាសនាជនជាតិឥណ្ឌាដំបូងមួយចំនួនឲ្យបម្រើនៅក្នុងប្រទេសនោះផងដែរ ។ ស៊ូវ៉ារណា កាទូកា និងពួកមិត្តអ្នកផ្សព្វផ្សាយសាសនារបស់គាត់បានទទួលការបំពាក់បំប៉នផ្សព្វផ្សាយសាសនាខ្លះៗនៅក្នុងទីក្រុងឈិនណៃ ។ ប្រធានបេសកកម្មរបស់ពួកគេ នៅប្រទេសសាំងហ្គាពួរ បានចាត់ឲ្យរ៉ាផ្ដល់ការបំពាក់បំប៉នបន្ថែមទៀតនៅក្នុងទីក្រុងដេលី ។

ស៊ូវ៉ារណា កាទូកា ចាំពីរបៀបដែលកិច្ចការផ្សព្វផ្សាយសាសនារបស់ពួកគេបានផ្លាស់ប្ដូរដោយសារតែគំរូ និងការបំពាក់បំប៉នរបស់ រ៉ា យូម៉ា ។ ពួកគេអាចមានលទ្ធភាពជំនួសអារម្មណ៍នៃការភ័យខ្លាចដោយសេចក្ដីជំនឿ និងភាពក្លាហានកាន់តែខ្លាំងឡើង ។ ស៊ូវ៉ារណាបានពន្យល់ថា « ពេលនោះហើយដែលខ្ញុំគិតថាការប្រែចិត្តជឿរបស់ខ្ញុំបានចាប់ផ្ដើម ។ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ហើយពេលនោះហើយដែលខ្ញុំបានសម្រេចចិត្តដើម្បីជួយស្ថាបនានគរនៅក្នុងប្រទេសឥណ្ឌានេះ » ។[៣]

ស៊ូវ៉ារណាបានចូលសាសនាចក្រនៅទីក្រុងរ៉ាចាម៉ុនឌ្រី ។ គាត់ រួមជាមួយនឹងបងប្អូនប្រុសប្រាំនាក់ និងប្អូនស្រីម្នាក់បានទទួលបុណ្យជ្រមុជទឹកនៅក្នុងឆ្នាំ ១៩៨៤ ។ នៅថ្ងៃនៃបុណ្យជ្រមុជទឹករបស់គាត់ ស៊ូវ៉ារណាត្រូវបានតែងតាំងជាសង្ឃ ហើយត្រូវបានញែកចេញជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានសាខា ។ គាត់ក៏ត្រូវបានសន្យានៅក្នុងពរជ័យមួយផងដែរថា ប្រសិនបើគាត់បន្តស្មោះត្រង់ នោះគាត់នឹងជា « បង្គោលនៃសាសនាចក្រនៅក្នុងប្រទេសឥណ្ឌា » ។

ប្អូនស្រីរបស់ស៊ូវ៉ារណា សារ៉ាឡា ក៏បានបម្រើបេសកកម្មផងដែរ ។ ពីមុនគាត់បានចាកចេញ គាត់បានណែនាំដំណឹងល្អទៅមិត្តរបស់គាត់ ស្វារ៉ូប៉ា ។ ពេលស៊ូវ៉ារណាត្រឡប់មកពីបេសកកម្មរបស់គាត់



*នៅក្នុងឆ្នាំ ១៩៨១ ខ្ញុំបានជួប រ៉ា យូម៉ា បន្ទាប់ពីបេសកកម្មរបស់គាត់ ។ ដោយនៅតែពាក់ស្លាកឈ្មោះអ្នកផ្សព្វផ្សាយសាសនារបស់គាត់ គាត់បានចែកចាយដល់អស់អ្នកណាដែលនឹងស្ដាប់ ។*



*អែលឌើរ ខានដាវ៉ែលលី សាម៉ា កាទូកា និងរ៉ាជូ*



*គ្រួសាររបស់អែលស៊ី និងអែដវិន ដាម៉ារ៉ាជូ នៅថ្ងៃដែលពួកគេទទួលបុណ្យជ្រមុជទឹក ។*

ការបម្រើដ៏លះបង់របស់សមាជិកជាច្រើននៅក្នុងប្រទេសឥណ្ឌាពិតជាបានធ្វើឲ្យពួកគេក្លាយជាសសរនៃសាសនាចក្រ ។

វិញ គាត់បានទទួលពរជ័យដោយសារកិច្ចការផ្សព្វផ្សាយសាសនារបស់ប្អូនស្រីគាត់ ហើយបានរៀបការនឹងស្វារ៉ូប៉ា ។ សាខាដ៏តូចនៅទីក្រុងរ៉ាចាម៉ុនឌ្រីនោះឥឡូវនេះបានក្លាយជាស្តេកមួយ ។ អ្នកត្រឡប់ពីបេសកកម្មជាច្រើនពីទីក្រុងរ៉ាចាម៉ុនឌ្រីបានក្លាយជាថ្នាក់ដឹកនាំនៅក្នុងសាសនាចក្រនៅទូទាំងប្រទេសឥណ្ឌា ។

ខ្ញុំបានជួបនឹងកូនៗរបស់ស៊ូវ៉ារណា និងស្វារ៉ូប៉ា កាទូកាពេលបង្រៀននៅប៊ី.វ៉ៃ.យូ នៅក្នុងឆ្នាំ ២០១៤ ។ ចស កាទូកា ទើបតែបញ្ចប់បេសកកម្មរបស់គាត់នៅទីក្រុងបាងហ្គាឡូប្រទេសឥណ្ឌា ហើយប្អូនស្រីគាត់ ធីមណា ទើបតែបានទទួលការហៅរបស់នាងទៅកាន់បេសកកម្មដដែលនោះ ។ ពេលខ្ញុំសួរធីមណា និងចស ថាពួកគេស្គាល់រ៉ាយូម៉ាដែរឬទេ ពួកគេបាននិយាយថា « បាទ/ចាស៎ គាត់ជាពូរបស់យើង ! » រ៉ា យូម៉ា បានរៀបការនឹងសារ៉ាឡា ។

ខ្ញុំមានអំណរគុណចំពោះគ្រួសារកាទូកា ដែលបានណែនាំខ្ញុំទៅកាន់ពួកអ្នកត្រួសត្រាយផ្លូវផ្សេងទៀត ពេលដែលពួកគេបានជួយខ្ញុំធ្វើដំណើរនៅក្នុងប្រទេសឥណ្ឌា ។ ពួកគេជាច្រើនបានទទួលឥទ្ធិពលដោយផ្ទាល់ ឬប្រយោលពីសេចក្តីស្រឡាញ់ និងគំរូរបស់គ្រួសារកាទូកា ។ នៅពេលមួយ ស៊ូវ៉ារណា និងស្វារូប៉ាបានមានឱកាសដើម្បីធ្វើអន្តោប្រវេសន៍ទៅប្រទេសកាណាដា ។ ប៉ុន្តែពួកគេបានបដិសេធដោយសារពួកគេបានមានអារម្មណ៍ថាព្រះអម្ចាស់ត្រូវការពួកគេឲ្យបន្តនៅប្រទេសឥណ្ឌា ហើយស្ថាបនានគរព្រះនៅទីនោះ ។ ការបម្រើដ៏លះបង់របស់ពួកគេពិតជាបានធ្វើឲ្យពួកគេក្លាយជាសសរនៃសាសនាចក្រ ។

## សមាជិកអ្នកត្រួសត្រាយផ្លូវនៅក្នុងទីក្រុងប៉ែងហ្គាលូរូ និងហៃឌើរ៉ាបាដ ។

អំឡុងពាក់កណ្តាលចុងក្រោយនៃទសវត្សរ៍ទី ២០នេះ សាសនាចក្រត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងផ្សេងៗនៅក្នុងប្រទេសឥណ្ឌាតាមរយៈពួកសមាជិកដែលជាអ្នកត្រួសត្រាយផ្លូវទាំងនេះ ។[១៤] រឿងរ៉ាវនីមួយៗជាសាក្សីពីរបៀបដែលព្រះអម្ចាស់បានកំពុងដឹកនាំរាស្ត្ររបស់ទ្រង់មកកាន់ដំណឹងល្អដែលបានស្តារឡើងវិញ ។

ម៉ែឃើល អែនថូនី ជាសមាជិកអ្នកត្រួសត្រាយផ្លូវម្នាក់នៅក្នុងទីក្រុងបាងហ្គាឡូ ( ឥឡូវនេះជាបឹងហ្គាលូរូ ) ដោយអព្ភូតហេតុបានភ្ជាប់ទំនាក់ទំនងនឹងសមាជិកសាសនាចក្រម្នាក់នៅក្នុងឆ្នាំ ១៩៧០ ។ ពេល ឌែលវិន ផោន ជាប៊ីស្សពមួយរូបនៅរដ្ឋយូថាហ៍បានទៅគ្រូចាប់សសៃដោយសារតែឈឺខ្នង នោះគាត់បានឃើញអត្ថបទទស្សនាវដ្តីមួយនៅការិយាល័យរបស់គ្រូចាប់សរសៃអំពីអង្គការមិនរកកម្រៃមួយដែលជួយឧបត្ថម្ភសិស្សនៅក្នុងប្រទេសឥណ្ឌា ។ គាត់បានទទួលអារម្មណ៍បំផុសដ៏ខ្លាំងមួយដើម្បីឧបត្ថម្ភដល់សិស្សម្នាក់ក្នុងចំណោមនោះ ។ ការណ៍នេះបាននាំទៅកាន់ការប្រាស្រ័យទាក់ទាក់ដោយអនាមិកដែលបានឈានដល់គ្រួសារផោនធ្វើការទាក់ទងជាមួយម៉ែឃើល និងចែកចាយដំណឹងល្អជាមួយគាត់ ។ ម៉ែឃើលបានទទួលបុណ្យជ្រមុជទឹកនៅក្នុងឆ្នាំ ១៩៨១ ហើយបានបម្រើបេសកកម្មនៅក្នុងទីក្រុងសលត៍លេកនៅក្នុងឆ្នាំ ១៩៨២ ។ គាត់បានត្រឡប់ទៅផ្ទះវិញមុនកំណត់ដោយសារម្តាយគាត់ឈឺជាទម្ងន់ ដូច្នេះគាត់បានបម្រើបេសកកម្ម

រូបថតទីក្រុងហៃឌើរ៉ាបាដ ដោយ GETTY IMAGES



*ខែលវិន ផោន ( កណ្ដាល ) បានណែនាំម៉ៃយើល អែនថូនី ឲ្យស្គាល់សាសនាចក្រនៅក្នុងឆ្នាំ ១៩៨១ ។*



ហៃឌើរ៉ាបាដ ជាទីក្រុងមួយដែលមានអត្រាប្រជាជន ៨ លាននាក់ ហើយជាកន្លែងដែលមានស្តេកដំបូងគេនៅក្នុងប្រទេសឥណ្ឌា ។

របស់គាត់បីខែចុងក្រោយនៅក្នុងទីក្រុងបាងហ្គាឡូ ជាកន្លែងដែលគាត់បានបង្រៀនដល់មិត្តភក្តិមួយចំនួនរបស់គាត់ និងអ្នកផ្សេងទៀតដែលបានក្លាយជាសមាជិកនៃសាខាដំបូងបំផុតនៅទីនោះ ។[៥] ឥឡូវនេះផែនការកំពុងតែដំណើរការក្នុងការសាងសង់ព្រះវិហារបរិសុទ្ធមួយនៅក្នុងទីក្រុងបឹងហ្គាឈ្លូ ។

អែលស៊ី និងអែដវិន ដាម៉ារ៉ាជូ បានចូលសាសនាចក្រនៅក្នុងប្រទេសសាម័រ ហើយត្រូវបានហៅដោយប្រធាន ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ឲ្យត្រឡប់ទៅកាន់ទីក្រុងកំណើតរបស់ពួកគេនៅហៃឌើរ៉ាបាដវិញក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាដល់គ្រួសារពួកគេ ។ នៅក្នុងឆ្នាំ ១៩៧៨ សមាជិកគ្រួសាររបស់អែលស៊ី និងអែដវិន ចំនួន ២២ នាក់បានទទួលបុណ្យជ្រមុជទឹក ហើយចេញពីការចាប់ផ្ដើមនេះ ស្តេកដំបូងគេបំផុតនៅក្នុងប្រទេសនេះត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងហៃឌើរ៉ាបាដនៅក្នុងឆ្នាំ ២០១២ ។[៦]

សមាជិកនៃស្តេកហៃឌើរ៉ាបាដសព្វថ្ងៃនេះគិតអំពីខ្លួនឯងថាជាពួកអ្នកត្រួសត្រាយផ្លូវពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ពិធីប្រារព្ធថ្ងៃត្រួសត្រាយផ្លូវប្រចាំស្តេករបស់ពួកគេបានរំឭកពីការធ្វើដំណើរនៃពួកអ្នកត្រួសត្រាយផ្លូវពីដើម ក៏ដូចជាដំណើរត្រួសត្រាយផ្លូវនៅសម័យទំនើបផងដែរ ។ ការប្រារព្ធពិធីរបស់ពួកគេរួមមានការរាំជាក្រុម ការដើរកាត់ព្រៃភ្នំជាការរំឭក និងការជិះរទេះរុញផងដែរ ។

នៅក្នុងការប្រារព្ធពិធីត្រួសត្រាយផ្លូវឆ្នាំ ២០១៤ របស់ពួកគេ ពួកគេបានដាក់ដុំទឹកកកជាជួរនៅខាងក្រោយព្រះវិហារ ហើយបានអញ្ជើញសមាជិកឲ្យដោះស្បែកជើងពួកគេ ហើយដើរកាត់ទឹកកកនោះ ដោយគិតអំពីរបៀបដែលពួកអ្នកត្រួសត្រាយផ្លូវជំនាន់ដើមបានដើរឆ្លងកាត់ទន្លេកក ។ នៅចុងបញ្ចប់នៃការប្រារព្ធពិធីរបស់ពួកគេ សមាជិកនៃស្តេកហៃឌើរ៉ាបាដត្រូវបានលើកទឹកចិត្តឲ្យចងចាំពីស្មារតីនៃពួកអ្នកត្រួសត្រាយផ្លូវជំនាន់ដើម ហើយថា « ពួកគេទាំងអស់គ្នាគឺជាអ្នកត្រួសត្រាយផ្លូវសម្រាប់គ្រួសាររបស់ពួកគេ » ។[៧]

ពួកគេបានស្ដាប់ដល់ ចន សេនថូស មូរ៉ាឡា ដែលពេលនោះបម្រើនៅក្នុងគណៈប្រធានបេសកកម្ម និយាយអំពីរបៀបដែលមីងអែលស៊ី និងពូអែដវិន ដាម៉ារ៉ាជូរបស់គាត់បានមកទីក្រុងហៃឌើរ៉ាបាដដើម្បីបង្រៀនគ្រួសាររបស់ពួកគាត់អំពីដំណឹងល្អ ។ ចនគឺជាសមាជិកគ្រួសារដែលក្មេងជាងគេបំផុតក្នុងចំណោមសមាជិកត្រួសត្រាយផ្លូវ ២២ នាក់ដែលបានជ្រមុជទឹកនៅក្នុងឆ្នាំ ១៩៧៨ នោះ ។

ពេលខ្ញុំបានទៅលេងទីក្រុងហៃឌើរ៉ាបាដនៅក្នុងឆ្នាំ ២០១៤ ចន មូរ៉ាឡាបានប្រាប់ខ្ញុំពីរឿងរបស់គាត់ និងប្រវត្តិសាស្ត្រសាសនាចក្រជាច្រើនដែលគាត់បានប្រមូលផ្ដុំយ៉ាងឧស្សាហ៍ព្យាយាម ។ គាត់ក៏បានណែនាំខ្ញុំឲ្យស្គាល់ភរិយាគាត់ អានណាភូណាផងដែរ ដែលបានប្រាប់ខ្ញុំពីរឿងអ្នកត្រួសត្រាយផ្លូវបរិសុទ្ធថ្ងៃចុងដ៏មានអានុភាពបំផុតមួយជាងរឿងនានាដែលខ្ញុំធ្លាប់បានឮកន្លងមក ។





*អានណាភូណា និងចន មូរ៉ាឡា ដែលជាសមាជិកត្រួសត្រាយផ្លូវនៅក្នុងទីក្រុងហៃឌើរ៉ាបាដ ដូចដែលបានបង្ហាញនៅទីនេះ កំពុងជួយក្នុងការធ្វើឡើងវិញនូវការធ្វើដំណើរដោយរទេះ និងថ្ងៃដែលពួកគេបានផ្សារភ្ជាប់នៅព្រះវិហារបរិសុទ្ធហុងកុង ។*



*សមាជិកនៃស្តេកហៃឌើរ៉ាបាដ ធ្វើពិធីរំឭកថ្ងៃត្រួសត្រាយផ្លូវតាមរយៈចម្រៀង ការរាំ និងការជិះរទេះផងដែរ ។*



*មជ្ឈមណ្ឌលស្តេកនៃស្តេក ហៃឌើរ៉ាបាដ ឥណ្ឌា បានបង្កើតឡើងនៅក្នុងឆ្នាំ ២០១២ ដោយប្រធាន ដាលីន អេច. អូកស៍ ។*

សមាជិកសាសនាចក្រនៅក្នុងប្រទេសឥណ្ឌាគិតថាខ្លួនឯងជាអ្នកត្រួសត្រាយផ្លូវសម្រាប់គ្រួសារពួកគេកាលដែលពួកគេខិតខំរស់នៅតាមដំណឹងល្អ ។

អានណាភូណាមានអាយុ ១២ ឆ្នាំ នៅក្នុងឆ្នាំ ១៩៩១ ពេលបងប្រុសនាងមើរធីបានទទួលការបង្រៀនដំណឹងល្អពីពួកអ្នកផ្សព្វផ្សាយសាសនាពីរនាក់នៅក្នុងទីក្រុងហៃឌើរ៉ាបាដ ។ ឪពុកម្ដាយរបស់អានណាភូណាពុំបានអនុញ្ញាតឲ្យនាងស្ដាប់ដល់ពួកអ្នកផ្សព្វផ្សាយសាសនា ឬចូលរួមក្នុងព្រះវិហារទេ ។ ទោះជាយ៉ាងណា មើរធីបានឲ្យព្រះគម្ពីរមរមនដល់នាង និងសម្ភារអក្សរសាស្ត្ររបស់សាសនាចក្រយ៉ាងខ្ជាប់ខ្ជួនឲ្យនាងអាន ។ អានណាភូណាបានសិក្សាដំណឹងល្អដោយខ្លួនឯង ហើយទទួលបានទីបន្ទាល់ដ៏រឹងមាំមួយអំពីសេចក្ដីពិតរបស់វា ។ នាងចង់ទទួលបុណ្យជ្រមុជទឹកបម្រើបេសកកម្ម ហើយរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ប៉ុន្តែពុំបានទទួលការអនុញ្ញាតពីឪពុកម្ដាយរបស់នាងទេ ។

អានណាភូណាបានប្រឈមនឹងការសម្រេចចិត្តដ៏ពិបាកនៅក្នុងជីវិតនាង ពេលដែលនាងត្រូវបានណែនាំឲ្យស្គាល់ចន ម៉ូរ៉ាឡា ។ ចនបានបន្តរឹងមាំនៅក្នុងទីបន្ទាល់របស់គាត់តាំងពីគាត់ជ្រមុជទឹកនៅក្នុងឆ្នាំ ១៩៧៨ ហើយកំពុងស្វែងរកសមាជិកសាសនាចក្រម្នាក់ដើម្បីរៀបការជាមួយ ។ បន្ទាប់ពីបានជួបគ្នាមួយភ្លែត ជាកន្លែងដែលអានណាភូណាបានចែកចាយទីបន្ទាល់របស់នាងអំពីដំណឹងល្អ ចនបានជឿថាគាត់បានជួបអនាគតភរិយារបស់គាត់ហើយ ។ អានណាភូណាបានដឹងថា ប្រសិនបើនាងរៀបការនឹងចន នោះនាងនឹងអាចទទួលបុណ្យជ្រមុជទឹក ហើយថ្ងៃណាមួយនឹងបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ទោះជាយ៉ាងណានៅពេលជាមួយគ្នានោះ ឪពុកម្ដាយរបស់អានណាភូណាបានមានផែនការដើម្បីរៀបចំអាពាហ៍ពិពាហ៍មួយសម្រាប់នាង ។

អានណាភូណាបានធ្វើការសម្រេចចិត្តដ៏ពិបាកដើម្បីចាកចេញពីផ្ទះ ហើយរៀបការជាមួយចន ។ នាងបានមានអារម្មណ៍ថានោះជាមធ្យោបាយតែមួយគត់ដែលនាងអាចចូលសាសនាចក្រ ។ នាងបាននិយាយថា នាង « ពិតជាខ្វេចខ្វាំដួងចិត្តណាស់ » ដែលចាកចេញពីឪពុកម្ដាយនាង ។ ប៉ុន្តែរហូតមកដល់ថ្ងៃនេះ នាងបញ្ជាក់ថា « សម្រាប់សេចក្ដីសង្គ្រោះរបស់មនុស្សគ្រប់គ្នា . . . សម្រាប់កូនចៅខ្ញុំ និងសម្រាប់ឪពុកម្ដាយខ្ញុំ ព្រមទាំងបុព្វការីជនរបស់ពួកគាត់ ដើម្បីធ្វើកិច្ចការព្រះវិហារបរិសុទ្ធរបស់ពួកគាត់ ខ្ញុំត្រូវតែបោះជំហានមួយនោះ » ។[៨]

ចន និងអានណាភូណាមានអំណរគុណដែលឪពុកម្ដាយនាងបានទទួលយកអាពាហ៍ពិពាហ៍របស់ពួកគេឥឡូវនេះ ។ សមាជិកជាច្រើននៅក្នុងប្រទេសឥណ្ឌាបានធ្វើការលះបង់នានា ដូចជាពួកអ្នកត្រួសត្រាយផ្លូវពីជំនាន់ដើមដែរ ដើម្បីក្លាយជាសមាជិកសាសនាចក្រ ។ ប៉ុន្តែពួកបរិសុទ្ធទាំងនេះបានឈានទៅមុខដោយសេចក្ដីជំនឿ ដោយសារពួកគេគិតអំពីខ្លួនឯងថាជាពួកអ្នកត្រួសត្រាយផ្លូវ ហើយជាតំណផ្សារភ្ជាប់សម្រាប់គ្រួសារពួកគេនៅសងខាងនៃវាំងនន ។ ខ្ញុំស្រឡាញ់រឿងរ៉ាវនៃសេចក្ដីជំនឿ ការលះបង់ និងភាព



*វិចិត្រករធ្វើរេនដឺព្រះវិហារបរិសុទ្ធបេងហ្គាឡូរ៉ា ។ ទីកន្លែងនេះនឹងមានទាំង សាលាប្រជុំ មជ្ឈមណ្ឌលចែកចាយ ការិយាល័យរបស់សាសនាចក្រ និងជាផ្ទះសំណាក់សម្រាប់អ្នកបម្រើការងារក្នុងព្រះវិហារបរិសុទ្ធ ។*

ក្លាហានជាច្រើន ដែលខ្ញុំបានឮពីសមាជិកដែលត្រួសត្រាយផ្លូវក្នុងព្រំប្រទល់នៃដំណឹងល្អថ្មី ។ ខ្ញុំនៅតែគិតអំពីពួកអ្នកត្រួសត្រាយផ្លូវដែលទាញរទេះ ហើយឆ្លងកាត់ទន្លេទាំងឡាយ ប៉ុន្តែឥឡូវនេះ ខ្ញុំអាចគិតអំពីពួកអ្នកត្រួសត្រាយផ្លូវសម័យទំនើបនៅក្នុងប្រទេសឥណ្ឌា និងនៅទូទាំងពិភពលោកទាំងអស់ ។

នៅទីបំផុត ផ្លូវនៃអ្នកត្រួសត្រាយផ្លូវទាំងអស់ត្រូវបានត្រួសត្រាយដោយបុគ្គលទាំងឡាយដែលដើរតាមស្នាមព្រះបាទរបស់ព្រះអង្គសង្គ្រោះយេស៊ូវគ្រីស្ទ ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ព្រះគ្រីស្ទត្រូវបានហៅថាជា « អ្នកត្រួសត្រាយនៃសេចក្តីសង្គ្រោះ [ របស់យើង ] » ( សូមមើល ហេព្រើរ ២:១០ កំណែបទដ្ឋានដែលកែសម្រួលថ្មី ) ។ ព្រះយេស៊ូវគ្រីស្ទបានរៀបចំផ្លូវសម្រាប់យើងឲ្យត្រឡប់ទៅផ្ទះសួគ៌ារបស់យើងវិញ ។ អ្នកត្រួសត្រាយផ្លូវដ៏ពិតធ្វើតាម ហើយចង្អុលបង្ហាញផ្លូវយើងទៅកាន់ព្រះគ្រីស្ទ ដែលកំពុងតែដឹកនាំកិច្ចការដ៏អស្ចារ្យនេះនៅក្នុងថ្ងៃចុងក្រោយ ។ ■

**កំណត់ចំណាំ**

១. « Whenever I Think about Pioneers » *ចម្រៀងកុមារ ( អង់គ្លេស )* ទំព័រ ២២២–២៣ ។
២. Oxford English Dictionary ( ឆ្នាំ ១៩៧១ ) « Pioneer » ។ សូមមើល ថូម៉ាស អេស ម៉នសុន « Led by Spiritual Pioneers » *Liahona* ខែ សីហា ឆ្នាំ ២០០៦ ទំព័រ ៣ ។
៣. ស៊ូវ៉ារណា កាទូកា ការសម្ភាសពីប្រវត្តិសាស្ត្រដោយផ្ទាល់មាត់ដោយ ថៅណាលីន រូស័រហ្វ៊ត ខែ ឧសភា ឆ្នាំ ២០១៤ ទីក្រុងដេលី ប្រទេសឥណ្ឌា ។
៤. រឿងរ៉ាវអ្នកត្រួសត្រាយផ្លូវជាច្រើនពីប្រទេសឥណ្ឌាអាចរកបាននៅក្នុងផ្នែកប្រវត្តិសាស្ត្រសាសនាចក្រនៃកម្មវិធីបណ្ណាល័យដំណឹងល្អ នៅក្រោម « Global Histories » ។
៥. សូមមើល « A History of the Church in India » ចងក្រងដោយ Jerry C. Garlock ( មិនបានបោះពុម្ព ឆ្នាំ ១៩៩៥ ) ទំព័រ ៤៩–៥០ ។
៦. សូមមើល « I Will Establish a Church by Your Hand » history.ChurchofJesusChrist.org ។
៧. សូមមើល « Hyderabad Stake Pioneer Day Activity » lds.org.in/hyderabad-stake-pioneer-day-activity ។
៨. អានណាភូណា ហ្គូ មូរ៉ាឡា ការសម្ភាសពីប្រវត្តិសាស្ត្រដោយផ្ទាល់មាត់ដោយ ថៅណាលីន រូស័រហ្វ៊ត ទីក្រុងហៃឌើរ៉ាបាដ ប្រទេសឥណ្ឌា ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៤ ។ សូមមើលផងដែរ Rochelle Welty and Jan Pinborough « God Had His Own Plans for Me » *Liahona* ខែ មេសា ឆ្នាំ ២០០៣ ទំព័រ ៣០–៣២ ។



ដោយ ត្រាវីស អ៊ីវែល

ជាច្រើនឆ្នាំកន្លងមកហើយ ខ្ញុំបានតាមដានការសន្ទនាមួយនៅលើបណ្ដាញសង្គមរវាងដៃគូពីរនាក់ពីក្នុងបេសកកម្មរបស់ខ្ញុំ ។ ពួកគេជាបុរសដែលខ្ញុំស្រឡាញ់ និងគោរព ។

ពួកគេបានពិភាក្សាពីសំណួរដែលពួកគេមានអំពីសាសនាចក្រ និងគោលលទ្ធិរបស់វា ។ មិនយូរប៉ុន្មាន វាបង្ហាញយ៉ាងច្បាស់ថា ពួកគេបានចាកចេញពីព្រះវិហារហើយ ។ វាធ្វើឲ្យខ្ញុំតក់ស្លុត ហើយរំខានដល់ចិត្តខ្ញុំណាស់ ។ ខ្ញុំពុំដែលបានឮពីអ្វីមួយចំនួនដែលពួកគេបានកំពុងពិភាក្សានោះទេ ។ ខ្ញុំបានមានអារម្មណ៍ថា ខ្ញុំត្រូវតែដឹងថាបើរឿងទាំងនេះពិតឬទេ ។ ដូច្នេះខ្ញុំបានចាប់ផ្ដើមមើលទៅក្នុងការជជែកវែកញែករបស់ពួកអ្នកដែលមានកង្វល់អំពីសាសនាចក្រ ។

រឿងរ៉ាវមួយចំនួនដែលបានអានពីរឆ្នាំបន្ទាប់ពីនោះ បានដឹកនាំខ្ញុំឲ្យសង្ស័យអ្វីៗគ្រប់យ៉ាងអំពីសាសនាចក្រ ។ អ្នកខ្លះដែលឆ្លងកាត់រឿងនេះ មានអារម្មណ៍សោកសៅ ។ ពួកគេកើតទុក្ខយ៉ាងខ្លាំងចំពោះការបាត់បង់សេចក្ដីជំនឿរបស់ពួកគេ ។ ខ្ញុំមានចិត្តខឹងសម្បារ ។ ខ្ញុំបានមានអារម្មណ៍ថា សាសនាចក្របានបោកបញ្ឆោតខ្ញុំ ។ ខ្ញុំពុំដឹងប្រាកដថា អ្វីជាការពិត ហើយនរណាដែលខ្ញុំអាចទុកចិត្តបានទៀតឡើយ ។

ខ្ញុំមានការពិបាកក្នុងការទៅព្រះវិហារ ។ ខ្ញុំបានសូមដោះលែងពីការហៅបម្រើរបស់ខ្ញុំ ។ ចំណងទាក់ទងជាមួយភរិយាខ្ញុំ ឈែរី និងគ្រួសារខ្ញុំមានភាពតានតឹងណាស់ ។ ខ្ញុំបានបន្តទៅព្រះវិហារ ប៉ុន្តែវាគ្រាន់តែដើម្បីបង្ហាញគេ និងដើម្បីព្យាយាម ហើយរក្សាក្រុមគ្រួសារខ្ញុំឲ្យជុំគ្នាប៉ុណ្ណោះ ។ ជីវិតគឺច្របូកច្របល់ណាស់ ។ ខ្ញុំពុំអាចមានព្រះវិញ្ញាណទេ ហើយសង្ស័យថាតើខ្ញុំធ្លាប់ទទួលអារម្មណ៍ពីព្រះវិញ្ញាណដែលឬទេ ។

ពេលដែលកូនច្បងរបស់ខ្ញុំ ខេសុន បានចាកចេញទៅបេសកកម្មរបស់គាត់ ខ្ញុំបានបង្កើតបរិយាកាសអវិជ្ជមានទៅលើអ្វីដែលគួរតែជាឱកាសដ៏ពោរពេញដោយអំណរមួយ ។ បន្ទាប់ពីពីរឆ្នាំ ភាគច្រើនបំផុតនៅក្នុងគ្រួសារខ្ញុំបានដឹងពីអ្វីដែលខ្ញុំកំពុងឆ្លងកាត់ ។ ពេលដែលពួកគេទាំងអស់គ្នាបានទៅព្រះវិហារបរិសុទ្ធជាមួយខេសុនជាលើកដំបូងសម្រាប់គាត់ ខ្ញុំពុំបាននៅទីនោះទេ ។

ខ្ញុំមានអារម្មណ៍ឯកោណាស់ឆ្លងកាត់បទពិសោធន៍ទាំងអស់នេះ ។

## ការគាំទ្រនៅជុំវិញខ្លួនខ្ញុំ

ថ្ងៃមួយបងប្អូនប្រុសរបស់ខ្ញុំបានមកជុំគ្នាដើម្បីនិយាយពីអ្វីដែលខ្ញុំកំពុងឆ្លងកាត់ ។ ខ្ញុំពិតជាមិនចាំពីអ្វីដែលពួកគេនិយាយនោះទេ ប៉ុន្តែខ្ញុំបានដឹងថាវាត្រូវបានធ្វើឡើង

រចនារូបភាពដោយ ម៉ាក ស្មីធ



# ពេលខ្ញុំមានអារម្មណ៍ថាត្រូវបានបំភាន់អំពីសាសនាចក្រ

*ហេតុអ្វីខ្ញុំបានចាកចេញ ។ ហើយមូលហេតុអ្វីខ្ញុំបានត្រឡប់មកវិញ ។*

ដោយសារសេចក្ដីស្រឡាញ់ ។ កាលដែលពួកយើងបាននិយាយគ្នា ខ្ញុំបានចាប់ផ្ដើមដឹងពីអ្វីដែលខ្ញុំកំពុងខកខាន ។ វាបានក្លាយជាការជំរុញឲ្យផ្លាស់ប្ដូរ ។ វាគួរតែជារូបខ្ញុំដែលត្រូវតែងតាំងខេសុនជាអែលឌើរម្នាក់ ។ វាគួរតែជាខ្ញុំដែលអមដំណើរគាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។ វាគួរតែជាខ្ញុំដែលជាអ្នកផ្ដល់ពរជ័យឪពុកដល់គាត់មុនគាត់ចាកចេញ ។ ហេតុការដ៏សំខាន់បំផុតទាំងនោះនៅក្នុងជីវិតគាត់គឺសម្រាប់ខ្ញុំដើម្បីនៅទីនោះ មិនមែននរណាម្នាក់ផ្សេងទៀតទេ ។ ខ្ញុំចាំពីការសួរខ្លួនឯងថា « តើខ្ញុំកំពុងធ្វើអ្វី ? »

មិនយូរបន្ទាប់មក មិត្តដ៏ល្អម្នាក់បានទទួលការបំផុសគំនិតណែនាំខ្ញុំឲ្យស្គាល់សមាជិកម្នាក់ក្នុងគណៈប្រធានស្តេករបស់គាត់ ។ បុរសដ៏ចិត្តល្អនេះបានស្តាប់ដល់រឿងរ៉ាវរបស់ខ្ញុំដោយចេតនាពិត ហើយហាក់ដូចជាដឹងពីអ្វីដែលខ្ញុំកំពុងនិយាយពីមុនខ្ញុំនិយាយវាទៀត ។ យើងបាននិយាយគ្នារាប់ម៉ោង ។ រឿងរបស់ខ្ញុំ សំណួររបស់ខ្ញុំ ភាពសមហេតុផលដែលខ្ញុំបានជួប គឺស្រដៀងគ្នាណាស់ទៅនឹងអ្វីដែលអ្នកផ្សេងទៀតបានចែកចាយនឹងគាត់ ។ ខ្ញុំបានចាប់ផ្ដើមដឹងថា មិនមានចម្លើយសមហេតុផលនានាសម្រាប់កង្វល់ភាគច្រើនរបស់ខ្ញុំទេ ហើយថាសំណួរភាគច្រើនរបស់ខ្ញុំ ទោះជាវាជាសំណួរដ៏ស្មោះត្រង់ក្ដី ក៏វាបានកើតឡើងដោយមកពីមនុស្សដទៃទៀតដែលមានបំណងបំផ្លាញសេចក្ដីជំនឿ ។

តើសំណួរ និងកង្វល់ទាំងឡាយរបស់ខ្ញុំត្រូវបានដោះស្រាយភ្លាមៗឬ ? អត់ទេ ពិតជាអត់ទេ ។ ប៉ុន្តែដួងចិត្តរបស់ខ្ញុំត្រូវបានបន្ទន់គ្រប់គ្រាន់ធ្វើឲ្យខ្ញុំដឹងពីសេចក្ដីពិតដ៏អស្ចារ្យមួយ ៖ សំណួរគឺល្អ ប៉ុន្តែសំណួរមួយចំនួនសំខាន់ជាងមួយចំនួនផ្សេងទៀត ។[១] តើការបាត់បង់គ្រួសាររបស់ខ្ញុំ ហើយការឈរនៅចំពោះព្រះសមនឹងតម្លៃនៃសំណួរដែលមិនមានចម្លើយមួយចំនួននោះឬ ? ពេលដែលខ្ញុំផ្ដោតជាដំបូងទៅលើសំណួរទាំងឡាយដែលសំខាន់បំផុត ហើយដាក់ព្រះជាទីមួយវិញនៅក្នុងដួងចិត្តខ្ញុំ នោះខ្ញុំបានចាប់ផ្ដើមរកឃើញចម្លើយទាំងឡាយដែលបានបញ្ជាក់ដល់ខ្ញុំម្ដងទៀតថា ខ្ញុំកំពុងតែស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវ ។

ប្រធានស្តេក និងប៊ីស្សពរបស់ខ្ញុំក៏បានឈោងមកជួយខ្ញុំផងដែរ ។ ពួកគាត់ជាជំនួយដ៏អស្ចារ្យដល់ខ្ញុំ និងឈៃរីអំឡុងគ្រាដ៏ងងឹងទាំងឡាយនេះ ។ ពួកគាត់មិនដែលបោះបង់ចោលទេ ។ ពួកគាត់ និងគ្រួសារខ្ញុំនៅទាំងសងខាងនៃវាំងននគឺជាឧបករណ៍នៅក្នុងការជួយខ្ញុំ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ស្គាល់ ហើយស្រឡាញ់ខ្ញុំ ។ ទ្រង់ដាក់មនុស្សនៅតាមផ្លូវរបស់យើងពេលយើងត្រូវការពួកគេ ។ យើងគ្រាន់តែត្រូវមានឆន្ទៈដើម្បីទទួលយកជំនួយរបស់ពួកគេប៉ុណ្ណោះ ។



**តើនឹងធ្វើអ្វីប្រសិនបើជាបងប្អូនវិញនោះ**

ខ្ញុំដឹងថាមានមនុស្សផ្សេងទៀតដែលអាចនឹងកំពុងឆ្លងកាត់រឿងរ៉ាវស្រដៀងគ្នានេះ ។ វាអាចជាបងប្អូន ឬនរណាម្នាក់ដែលបងប្អូនស្គាល់ ។

ខ្ញុំដឹងថាព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្ររបស់ទ្រង់ជាមួយនឹងសិទ្ធិអំណាចដើម្បីផ្ដល់នូវពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាទាំងឡាយ ដែលយើងត្រូវការដើម្បីវិលត្រឡប់ទៅកាន់ទ្រង់វិញ ។ សាតាំងកំពុងធ្វើការបន្ថែមម៉ោងដើម្បីបង្ខូចសាសនាចក្ររបស់ព្រះអម្ចាស់ ដោយប្រើគ្រប់មធ្យោបាយណាដ៏ដោយដែលវាអាចធ្វើបាន ។ ការមានសំណួរ និងបង្កើតជាការសង្ស័យគឺងាយស្រួលណាស់ ។ ការធ្លាក់ចូលទៅក្នុងអន្ទាក់របស់វាគឺអាចកើតឡើងដល់មនុស្សគ្រប់គ្នា ។ ការពឹងផ្អែកលើព័ត៌មាន និងចម្លើយដែលអ្នកផ្សេងទៀតផ្ដល់ឲ្យអាចជាការងាយស្រួលជាងការធ្វើកិច្ចការស្វែងរកសេចក្ដីពិតដោយខ្លួនឯង « ដោយសារការសិក្សា និង*ដោយសារសេចក្ដីជំនឿផង* » នោះខ្លាំងណាស់ ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៨ ការសង្កត់ន័យត្រូវបានបន្ថែម ) ។ ប៉ុន្តែនៅទីបំផុតនោះជាអ្វីដែលព្រះតម្រូវឲ្យធ្វើ ។

ប្រសិនបើបងប្អូនកំពុងជួបការលំបាកជាមួយនឹងសំណួរ និងការសង្ស័យទាំងឡាយអំពីសាសនាចក្រ ឬពីសេចក្ដីជំនឿរបស់បងប្អូន បងប្អូននឹងមិនរកឃើញសេចក្ដីពិតដោយការអានតាមអ៊ិនធើរណិត ឬការស្ដាប់ការផ្សាយតាមវិទ្យុ ឬតាមអ៊ិនធើរណិតពីមនុស្សដែលមិនយល់ស្របនឹងសាសនាចក្រ ឬដែលបានចាកចេញពីសាសនាចក្រឡើយ ។ ប៉ុន្តែបងប្អូនក៏ប្រហែលជានឹងមិនបានស្កប់ស្កល់នឹងចម្លើយរាក់កំផែលដែរ ហើយបងប្អូនក៏ប្រហែលជាមិនពេញចិត្តចំពោះការផ្ដល់យោបល់ឲ្យ « ទុកសំណួររបស់បងប្អូននៅលើធ្នើរសិននោះដែរ » ។

ពេលដែលខ្ញុំផ្ដោតជាដំបូងទៅលើសំណួរទាំងឡាយដែលសំខាន់បំផុត ហើយដាក់ដួងចិត្តខ្ញុំទៅក្នុងព្រះហស្តព្រះវិញ នោះខ្ញុំបានចាប់ផ្ដើមរកឃើញចម្លើយទាំងឡាយដែលបានបញ្ជាក់ដល់ខ្ញុំម្ដងទៀតថាខ្ញុំកំពុងតែស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវ ។

ខ្ញុំបានរៀនថា យើងមិនអាចតែងតែរស់នៅដោយផ្អែកលើពន្លឺដែលខ្ចីពីគេនោះដែរ ប៉ុន្តែផ្ទុយទៅវិញ យើងត្រូវតែងាកទៅរកព្រះដែលជាប្រភពនៃពន្លឺ និងសេចក្ដីពិតទាំងអស់ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៩៣:២៦ ) ។ យើងត្រូវតែសិក្សាវានៅក្នុងគំនិតរបស់យើងផ្ទាល់ ប៉ុន្តែយើងក៏ត្រូវសួរដល់ព្រះផងដែរថាបើអ្វីដែលយើងកំពុងគិតនោះជាការត្រឹមត្រូវឬទេ ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៩:៨ ) ។ យើងត្រូវតែរៀនដោយខ្លួនឯងផ្ទាល់ ដូចជាយ៉ូសែប ស្ម៊ីធបានធ្វើ ( សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២០ ) ហើយមានការអត់ធ្មត់នៅក្នុងការស្រាវជ្រាវរបស់យើង ( សូមមើល អាលម៉ា ៣២:៤១ ) ។ ប៉ុន្តែការរៀនដោយសេចក្ដីជំនឿមានន័យថា យើងត្រូវតែបង្ហាញពីសេចក្ដីពិតដោយការរស់នៅតាមវា ( សូមមើល យ៉ូហាន ៧:១៧; ថែស្សាឡូនីចទី១ ៥:២១ ) ។

ពេលខ្ញុំកំពុងសិក្សាអ្វីៗដែលប្រឆាំងនឹងសាសនាចក្រ នោះខ្ញុំបានមានអារម្មណ៍ដូចជាខ្ញុំពិតជាកំពុងស្ថិតនៅក្នុងអ័ព្ទនៃសេចក្ដីងងឹង ( សូមមើល នីហ្វៃទី១ ៨:២៣–២៤; ១២:១៧ ) ។ ពេលខ្ញុំឱបក្រសោបកិច្ចការរបស់ព្រះ ហើយបោះជំហានដំបូងនោះឆ្ពោះ



**សំណួរដែលមិនត្រូវបានឆ្លើយទល់នឹងភាពច្បាស់លាស់ខាងគោលលទ្ធិ**

« ខ្ញុំអាចរស់នៅជាមួយនឹងភាពមិនល្អឥតខ្ចោះនៃមនុស្សលោក សូម្បីតែក្នុងចំណោមពួកព្យាការីនៃព្រះ—នោះជាអ្វីដែលអាចរំពឹងពីមនុស្សរមែងស្លាប់ ។ ខ្ញុំអាចរស់នៅជាមួយនឹងការរកឃើញខាងវិទ្យាសាស្ត្រដែលបានចោទប្រកាន់ទាស់នឹងព្រះគម្ពីរមរមន ពេលវេលានឹងកែតម្រូវវា ។ ហើយខ្ញុំអាចរស់នៅជាមួយនឹងភាពមិនប្រក្រតីខាងប្រវត្តិសាស្ត្រមួយចំនួន វាជាការណ៍តូចតាចបើប្រៀបធៀបនឹងទំហំសរុបនៃសេចក្ដីពិត ។ ប៉ុន្តែខ្ញុំពុំអាចរស់នៅដោយគ្មានសេចក្ដីពិត និងពិធីបរិសុទ្ធទាំងឡាយខាងគោលលទ្ធិដែលបានស្ដារឡើងវិញដោយយ៉ូសែប ស្ម៊ីធ នោះទេ ខ្ញុំពុំអាចរស់នៅដោយគ្មានបព្វជិតភាពនៃព្រះដើម្បីប្រសិទ្ធិពរដល់គ្រួសារខ្ញុំឡើយ ហើយខ្ញុំពុំអាចរស់នៅដោយពុំដឹងថាភរិយា និងកូនៗខ្ញុំត្រូវបានផ្សារភ្ជាប់ជាមួយខ្ញុំអស់កល្បជានិច្ចនោះទេ ។ នោះជាជម្រើសដែលយើងប្រឈមជាមួយ—យើងអាចជ្រើសរើសរវាងសំណួរដែលមិនមានចម្លើយមួយចំនួនតូចនៅនឹងដៃម្ខាង ទល់នឹងភាពច្បាស់លាស់ខាងគោលលទ្ធិជាច្រើន និងអំណាចនៃព្រះនៅដៃម្ខាងទៀត » ។

**អែលឌើរ ថាត អរ ខាលីស្ទើរ កំពុងបម្រើនៅក្នុងគណៈប្រធាននៃពួកចិតសិបនាក់ ពេលដែលលោកបានផ្ដល់សុន្ទរកថានេះ « What Is the Blueprint of Christ's Church? » ( ការប្រជុំធម្មនិដ្ឋានប្រព័ន្ធអប់រំសាសនាចក្រសម្រាប់យុវមជ្ឈិមវ័យ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៤ ) broadcasts.ChurchofJesusChrist.org ។**



ទៅកាន់ទ្រង់ នោះហើយជាអ្វីទាំងអស់ដែលទ្រង់ត្រូវការដើម្បីបញ្ជូនព្រះវិញ្ញាណរបស់ទ្រង់ឲ្យប៉ះដួងចិត្តខ្ញុំ ។

### តើសេចក្តីសង្ឃឹមគ្រប់គ្រាន់ទេ ?

ពីរបីសប្តាហ៍បន្ទាប់ពីខេសុនបានចាកចេញទៅបេសកកម្មរបស់គាត់ ប្រធានស្តេករបស់ខ្ញុំបានមកសួរសុខទុក្ខខ្ញុំ ។ ខ្ញុំបានប្រាប់គាត់អំពីអ្វីដែលបានកើតឡើងនៅអំឡុងប៉ុន្មានសប្តាហ៍នោះ បន្ទាប់ពីបងប្អូនប្រុសខ្ញុំបាននិយាយជាមួយខ្ញុំ ។ ខ្ញុំបាននិយាយថា ខ្ញុំចង់ទទួលបានបណ្ណចូលព្រះវិហារបរិសុទ្ធថ្មីមួយ ។ គាត់បានសួរថា តើខ្ញុំអាចឆ្លើយនឹងសំណួរសម្រាប់បណ្ណចូលព្រះវិហារបរិសុទ្ធដោយត្រឹមត្រូវបានទេ ។ ខ្ញុំបានសារភាពថា « ប្រធាន ខ្ញុំមិនគិតថា ខ្ញុំអាចនិយាយថា ខ្ញុំដឹងថាសាសនាចក្រពិតនៅឡើយទេ ប៉ុន្តែខ្ញុំពិតជាសង្ឃឹមដោយអស់ពីដួងចិត្តខ្ញុំថាវាពិត ។ ហើយខ្ញុំនឹងរស់នៅស្របនឹងសេចក្តីសង្ឃឹមនោះ ។ តើវាគ្រប់គ្រាន់ទេ ? »

គាត់បានផ្អាកមួយសន្ទុះហើយនិយាយថា « ត្រាវីស ការណ៍នោះតែងតែគ្រប់គ្រាន់ជានិច្ច » ។

នៅតែមានអ្វីមួយចំនួនដែលខ្ញុំនៅតែរង់ចាំដើម្បីយល់ ប៉ុន្តែរឿងរ៉ាវមួយចំនួនបានក្លាយជាច្បាស់ក្រឡែតដល់ខ្ញុំ ។ ខ្ញុំដឹងថាព្រះវរបិតាសួគ៌ស្រឡាញ់ខ្ញុំ ។ ខ្ញុំដឹងថា យើងអាចនឹងវង្វេង ហើយមានការលំបាកអស់មួយពេល ។ ប៉ុន្តែខ្ញុំដឹងថា តាមរយៈព្រះគ្រីស្ទ ដង្វាយធួនរបស់ទ្រង់ និងសេចក្តីសង្ឃឹមដែលវានាំមក នោះវាអាចទៅរួចដើម្បីត្រឡប់មកលើផ្លូវដែលដឹកនាំទៅកាន់ទ្រង់វិញ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

១. សូមមើល លរ៉េនស៍ អ៊ី ឃរប្រ៊ីជ « Stand Forever » ( ការប្រជុំធម្មនិដ្ឋានសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៩ ) នៅលើគេហទំព័រ speeches.byu.edu ។

### គំនិតសម្រាប់ជួយដល់នរណាម្នាក់ដែលអ្នកស្រឡាញ់

ដូចខ្ញុំដែរ មនុស្សជាច្រើនដែលមានសំណួរ ឬការសង្ស័យមានអារម្មណ៍ដូចជាពួកគេមិនមែនជារបស់សាសនាចក្រ ។ ប៉ុន្តែយើងមិនអាចបិទទ្វារឃាំងពួកគេ ឬអ្នកដទៃទៀតឡើយ ។ ព្រះអង្គសង្គ្រោះបានបញ្ជាដល់រាស្ត្ររបស់ទ្រង់ឲ្យ « ត្រូវធ្វើការងារបម្រើ » ដល់ពួកគេដោយសារយើងមិនដែលដឹងថាពេលណាដែលពួកគេនឹងត្រឡប់មកកាន់ទ្រង់វិញ ហើយបានព្យាបាលឲ្យជានោះទេ ( សូមមើល នីហ្វៃទី៣ ១៨:២២–៣២ ) ។

នេះជាវិធីប្រាំយ៉ាងដែលយើងអាចបន្តផ្តល់ការងារបម្រើដល់ពួកអ្នកដែលកំពុងពុះពារនឹងការសង្ស័យ ដើម្បីឲ្យពួកគេមានអារម្មណ៍ស្វាគមន៍ មិនថាពួកគេជ្រើសរើសដើម្បីត្រឡប់មកវិញ ឬអត់នោះទេ ។

១. **បន្តស្រឡាញ់ ។** អំឡុងពេលដែលខ្ញុំពុះពារ ខ្ញុំបានមានអារម្មណ៍ថាខ្ញុំឯកោ ។ ពិតណាស់ព្រះវរបិតាសួគ៌ពុំបានបោះបង់ខ្ញុំទេ ហើយគ្រួសារខ្ញុំ ឬថ្នាក់ដឹកនាំសាសនាចក្រក៏មិនបានបោះបង់ខ្ញុំដែរ ។ ការទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់តាមរយៈពួកគេបានជួយខ្ញុំឲ្យដឹងថាខ្ញុំអាចត្រឡប់ទៅវិញបាន ។

២. **បន្តឈោងជួយ ។** ការស្រឡាញ់អ្នកដទៃមិនគួរផ្អែកទៅលើជំនឿរបស់ពួកគេ ការចូលរួមរបស់ពួកគេនៅសាសនាចក្រ ឬសូម្បីតែរបៀបដែលពួកគេមានអារម្មណ៍អំពីយើងនោះទេ ។ ព្រះយេស៊ូវសូមឲ្យយើងឈោងទៅជួយច្រើនជាងពួកអ្នកដែលគ្រាន់តែនៅក្នុងរង្វង់គ្រួសារមិត្តភក្តិយើងស្រាប់ហើយនោះ ( សូមមើល ម៉ាថាយ ៥:៤៦–៤៧ ) ។

៣. **បន្តមានសេចក្តីសង្ឃឹម ។** យើងតម យើងអធិស្ឋាន យើងសម្លឹងមើល ហើយរង់ចាំដោយអត់ធ្មត់ ហើយយើងមិនដែលលះបង់ចោលសេចក្តីសង្ឃឹមឡើយ ។ « ព្រះមានមធ្យោបាយដ៏ឆ្នៃប្រឌិតដើម្បីសង្គ្រោះបុត្រម្នាក់ៗរបស់ទ្រង់ » ( ហិនរី ប៊ី អាវរីង « To My Grandchildren » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៧១ ) ។

៤. **គោរពដល់សិទ្ធិជ្រើសរើសរបស់ពួកគេ ។** មានសេចក្តីសង្ឃឹម ប៉ុន្តែសូមគោរពដល់ការសម្រេចចិត្តរបស់ពួកគេ ។ យើងពុំចាំបាច់បញ្ចុះបញ្ចូលពួកគេ ឬប្រកែកជាមួយពួកគេអំពីគោលលទ្ធិនោះទេ ។ ដូចជាកូនប្រុសខ្ជះខ្ជាយដែរ ពួកយើងជាច្រើនត្រូវការព្រឹត្តិការណ៍ខ្លះនៅក្នុងជីវិតដែលនឹងបន្ទន់ចិត្តយើងជាមុនសិន ។

៥. **ប្រព្រឹត្តិចំពោះពួកគេដោយសេចក្តីថ្លៃថ្នូរ មិនមែនដូចជាពួកគេអាក្រក់នោះទេ ។** ជៀសវាងពាក្យសម្តីដែលជាការវិនិច្ឆ័យ រិះគន់ ឬមើលងាយ ។ មនុស្សសមហេតុផលអាចមានជំនឿខុសពីយើង ហើយយើងគួរតែផ្តល់ដល់ពួកគេនូវការគោរពដូចគ្នាដែលយើងសង្ឃឹមចង់បានពីពួកគេ ។



ខ្ញុំមិនគិតថា ខ្ញុំអាចនិយាយថា ខ្ញុំដឹងថាសាសនាចក្រពិតនៅឡើយទេ ប៉ុន្តែខ្ញុំសង្ឃឹមថា សាសនាចក្រគឺពិត ហើយខ្ញុំនឹងរស់នៅឲ្យស្របតាមសេចក្តីសង្ឃឹមនោះ ។

# អ្នកស្រឡាញ់ ទ្រង់សង្គ្រោះ

*យើងបានអធិស្ឋានថា ដួងចិត្តកូនៗរបស់យើងនឹងផ្លាស់ប្ដូរ ។ ក្រោយមកមាននូវការយល់ដឹងដ៏មិនស្រណុកចិត្ត ( និងមានសេរីភាព ) មួយ ។*

**ដោយ គ្រីស្ដា រ៉ូជ័រ ម៉ រធិនសិន**

ស្វាមីខ្ញុំ និងខ្ញុំបានចិញ្ចឹមកូនៗយើងនៅក្នុងដំណឹងល្អ ។ យើងបានសិក្សាព្រះគម្ពីរជាគ្រួសារជារៀងរាល់ព្រឹក អធិស្ឋានជាគ្រួសារ និងរាត្រីជួបជុំគ្រួសារជារៀងរាល់សប្ដាហ៍ ។ យើងបានទៅព្រះវិហារ បានទទួលទានអាហារពេលល្ងាចជាមួយគ្នា ហើយបានទៅវិស្សមកាលជាគ្រួសារ ។ កូនៗរបស់ខ្ញុំបានទៅព្រះវិហារបរិសុទ្ធជាទៀងទាត់ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន ពួកគេបានបញ្ចប់ការសិក្សាពីថ្នាក់សិក្ខាសាលា ហើយពួកគេពីរនាក់បានបម្រើបេសកកម្ម ។

ហើយបន្ទាប់មក ពេលជាមជ្ឈិមវ័យ ពួកគេបានចាប់ផ្ដើមស្ទង់មើលផ្លូវ និងគំនិតទាំងឡាយដែលខុសពីអ្វីៗដែលយើងបានបង្រៀនពួកគេ ។ កូនៗរបស់យើងបានឈប់ចូលរួមក្នុងសាសនាចក្រម្ដងម្នាក់ៗ រហូតសល់តែម្នាក់ប៉ុណ្ណោះក្នុងចំណោមកូនទាំងប្រាំនាក់ដែលនៅតែបន្តចូលរួម ។ យើងបានសម្រក់ទឹកភ្នែកជាច្រើនដោយសារកូនៗយើង ហើយបានឆ្ងល់ថាបើយើងបានបរាជ័យក្នុងនាមជាឪពុកម្ដាយ ឬថាបើមានអ្វីដែលយើងអាចធ្វើខុសពីនេះ ។

យើងបានទូលអង្វរព្រះអម្ចាស់អស់ពេលជាយូរដើម្បីទ្រង់ផ្លាស់ប្ដូរដួងចិត្តរបស់ពួកគេ ហើយនៅទីបំផុតព្រះអម្ចាស់បានឆ្លើយតបដល់ការអធិស្ឋានរបស់យើង ។ ប៉ុន្តែមិនតាមរបៀបមួយដែលយើងរំពឹងនោះទេ ។

ជំនួសឲ្យការគ្រាន់តែផ្លាស់ប្ដូរដួងចិត្តរបស់កូនៗយើង ទ្រង់បានបង្ហាញយើងថា យើងត្រូវតែចាប់ផ្ដើមដោយការផ្លាស់ប្ដូរដួងចិត្តរបស់យើងវិញ ។ ខណៈដែលឪពុកម្ដាយដើរតួយ៉ាងសំខាន់នៅក្នុងការបង្រៀនកូនៗរបស់ពួកគេ ទ្រង់បានរំឭកយើងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះ និងជាអង្គកាត់សេចក្ដីរបស់ពួកគេ ។

នៅក្នុងការប្ដេជ្ញាចិត្តដើម្បីសង្គ្រោះកូនៗខ្ញុំ ខ្ញុំបានចំណាយពេលជាច្រើនម៉ោងក្នុងការអធិស្ឋាន អានព្រះគម្ពីររបស់ខ្ញុំ និងទៅព្រះវិហារបរិសុទ្ធ ដោយគិតថាប្រសិនបើខ្ញុំបានធ្វើការណ៍ត្រឹមត្រូវទាំងអស់នេះ នោះខ្ញុំនឹងសក្ដិសមនឹងទទួលបានការអន្តរាគមពីព្រះ—ដូចជាថាដោយរបៀបណាមួយនោះ សកម្មភាពរបស់ខ្ញុំនឹងនាំឲ្យព្រះឈ្នះលើសិទ្ធិជ្រើសរើសរបស់ពួកគេ ហើយបង្ខំឲ្យពួកគេជឿដូចជាខ្ញុំជឿ ។

ស្វាមីខ្ញុំ និងខ្ញុំចង់សង្គ្រោះពួកគេខ្លាំងណាស់ ប៉ុន្តែរបៀបនៃការសង្គ្រោះរបស់យើងមើលទៅដូចជាការប្រៀនប្រដៅ និយាយច្រំដែលៗ ឬបង្ហាញពីការមិនយល់ស្របនឹងជម្រើសរបស់ពួកគេច្រើនជាង ដែលនៅទីបំផុតនាំទៅរកការឈ្លោះប្រកែកគ្នា ។ យើងបានដឹង



ថា នៅក្នុងការខំប្រឹងជាខ្លាំងដើម្បីនាំកូនៗយើងឲ្យត្រឡប់មកវិញ នោះតាមពិតទៅយើងកំពុងច្រានពួកគេចេញវិញ ។ ពួកគេកាន់តែទទួលអារម្មណ៍នៃការវិនិច្ឆ័យ និងការខកចិត្តច្រើនប៉ុណ្ណា នោះពួកគេកាន់តែគេចវេសពីយើងច្រើនប៉ុណ្ណឹងដែរ ។

ការអធិស្ឋានរបស់ខ្ញុំបានផ្លាស់ប្ដូរទៅជាការអង្វរដើម្បីឲ្យដួងចិត្តខ្ញុំបានផ្លាស់ប្ដូរវិញ ។ ខ្ញុំបានដឹងថា មូលហេតុរបស់ខ្ញុំដែលចង់ឲ្យកូនៗរបស់ខ្ញុំផ្លាស់ប្ដូរគឺមិនត្រឹមត្រូវទេ ។ ខ្ញុំបានអធិស្ឋានសូមសេចក្ដីស្រឡាញ់កាន់តែច្រើន ។ ខ្ញុំក៏បានអធិស្ឋានដើម្បីយកឈ្នះអារម្មណ៍នៃការខ្មាស់អៀន និងភាពអាម៉ាស់របស់ខ្ញុំ ដែលគ្រួសារខ្ញុំពុំបានមើលទៅដូចជាគ្រួសារដ៏ល្អឥតខ្ចោះដែលមិត្តភក្ដិរបស់ខ្ញុំបានបង្ហាញនៅលើបណ្ដាញសង្គមជាមួយនឹងរូបថតនៃអាពាហ៍ពិពាហ៍ព្រះវិហារបរិសុទ្ធរបស់កូនៗពួកគេ ឬបុណ្យជ្រមុជទឹកចៅៗរបស់ពួកគេ ។

កាលដែលខ្ញុំងាកទៅរកព្រះអង្គសង្គ្រោះដើម្បីបានការព្យាបាល នោះដួងចិត្តខ្ញុំបានចាប់ផ្ដើមបន្ទន់ទៅកាន់កូនៗរបស់ខ្ញុំ ។ ខ្ញុំបានដឹងថា ដើម្បីស្រឡាញ់ពួកគេដូចជាទ្រង់ស្រឡាញ់ពួកគេ មានន័យថាត្រូវធ្វើការផ្លាស់ប្ដូរខ្លះៗ ។ ចំពោះទ្រង់ សេចក្ដីស្រឡាញ់មិនមែនជាវិធីសាស្ត្រមួយនោះទេ—វាគឺជាការជំរុញចិត្តដែលបណ្ដាលឲ្យទ្រង់ធ្វើអ្វីៗគ្រប់យ៉ាង ។ ទ្រង់បានមានព្រះបន្ទូលថា ទ្រង់ពុំបាន « ធ្វើការណ៍ណាឡើយ លើកលែងតែការណ៍នោះមានប្រយោជន៍ដល់មនុស្សលោក ត្បិតទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ » ( នីហ្វៃទី២ ២៦:២៤ ) ។

ការទុកចិត្តលើសមត្ថភាពរបស់ព្រះអង្គសង្គ្រោះដើម្បីធ្វើកិច្ចការរបស់ទ្រង់ ( សូមមើល នីហ្វៃទី២ ២៧:២០ ) បានអនុញ្ញាតឲ្យខ្ញុំផ្ដោតទៅលើការស្រឡាញ់កូនៗរបស់ខ្ញុំ ហើយបង្វែរការសង្គ្រោះទៅព្រះអម្ចាស់វិញ ។ វាមិនមានន័យថាលះបង់ការព្យាយាមជួយពួកគេនោះទេ ប៉ុន្តែពេលដែលការស្រឡាញ់ពួកគេក្លាយជាកម្លាំងជំរុញពីក្រោយការប្រាស្រ័យទាក់ទងរបស់ខ្ញុំជាមួយពួកគេ នោះវាបានផ្លាស់ប្ដូរ*របៀប*ដែលខ្ញុំបានប្រាស្រ័យទាក់ទង ។

ខ្ញុំបានចាប់ផ្ដើមមើលឃើញពួកគេក្នុងទស្សនៈផ្សេងមួយ ។ ខ្ញុំបានចាប់ផ្ដើមផ្ដោតទៅលើភាពខ្លាំងរបស់ពួកគេ និងទេពកោសល្យរបស់ពួកគេ ហើយបានចាប់ផ្ដើមឃើញថាពួកគេជាមនុស្សពោរពេញដោយក្ដីស្រឡាញ់ សប្បុរស ឆ្លាតវៃ និងល្អយ៉ាងណា ។

ស្វាមីខ្ញុំ និងខ្ញុំបានស្ដាប់ច្រើន ហើយនិយាយតិចវិញ ។ យើងបានសួរសំណួរអំពីជីវិតពួកគេ និងចំណាប់អារម្មណ៍របស់ពួកគេ ។ ជំនួសឲ្យការវិនិច្ឆ័យ យើងបង្ហាញពីការចង់ដឹងចង់ឮវិញ ។ យើងបានជំនួសការរិះគន់ និងការខកចិត្តជាមួយនឹងការបង្ហាញសេចក្ដីស្រឡាញ់វិញ ហើយកូនៗរបស់យើងអាចទទួលអារម្មណ៍ថាវាស្មោះត្រង់ ។

ផ្ទះរបស់យើងបានក្លាយជាកន្លែងដែលពួកគេអាចមានអារម្មណ៍នៃសេចក្ដីស្រឡាញ់ និងការទទួលយក ។ ពួកគេបានឈប់លាក់បាំងរឿងរ៉ាវពីយើង ហើយបានចាប់ផ្ដើមស្មោះត្រង់ ហើយបើកចំហរអំពីអ្វីៗដែលកំពុងកើតឡើងនៅក្នុងជីវិតពួកគេ ។ យើងបានមានភាពស្និទ្ធស្នាលគ្នាកាន់តែខ្លាំង ។

គ្រួសារយើងនៅតែបន្តខិតខំរីកចម្រើន ប៉ុន្តែកូនៗយើងរីករាយនឹងការមកលេងផ្ទះយើង និងចំណាយពេលជាមួយយើងឥឡូវនេះ ។ ពួកគេមានអារម្មណ៍ថាមានសុវត្ថិភាពចំពោះវត្តមានយើង ហើយតាមរយៈសេចក្ដីស្រឡាញ់របស់យើង ពួកគេអាចទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់ព្រះចំពោះពួកគេ ។ ខ្ញុំមិនដឹងថាពួកគេនឹងត្រឡប់មករកអ្វីៗដែលពួកគេត្រូវបានបង្រៀនពេលនៅក្មេងៗ នៅក្នុងជីវិតនេះដែរឬទេ ប៉ុន្តែខ្ញុំដឹងថា ពួកគេស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអង្គសង្គ្រោះ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

## អ្វីដែលបានជួយខ្ញុំ

### ការអធិស្ឋាន
ការអង្វរដើម្បីឲ្យដួងចិត្តខ្ញុំផ្លាស់ប្ដូរ





### ទស្សនៈវិស័យ
មើលឃើញកូនៗខ្ញុំក្នុងពន្លឺផ្សេងមួយ

### សេចក្ដីស្រឡាញ់
កុំគ្រាន់តែនិយាយ—ស្ដាប់





### ការទុកចិត្ត
កិច្ចខិតខំរបស់ខ្ញុំជាដៃគូជាមួយនឹងព្រះ

# ពួកគាត់បានទុកការសាកល្បងរបស់ពួកគាត់មួយឡែក

ដោយ ណាតាលី ចូនស៍ រដ្ឋយូថាហ៍ ស.រ.អា.

*នៅថ្ងៃនោះ ឃិនដ្រា ប្រិនថ៍ និងថៃសុន គឺជាគំរូដ៏ពិតនៃការផ្ដល់ការងារបម្រើដូចជាព្រះគ្រីស្ទ ។*

យើងទាំងអស់គ្នាជួបរឿងល្អ និងអាក្រក់នៅក្នុងជីវិតរបស់យើង ប៉ុន្តែនៅឆ្នាំ ២០១៣ ជាពិសេសគឺជាឆ្នាំដ៏ពិបាកសម្រាប់គ្រួសារយើង ។ យើងបានជួបនូវបទពិសោធន៍ដែលមិនបានរំពឹងទុក ដោយត្រូវការជួសជុលផ្ទះ និងយានយន្តដែលត្រូវអស់ប្រាក់យ៉ាងច្រើន ។ ស្វាមីខ្ញុំ រ៉ាយអិន បានបាត់បង់ការងារ ហើយកូនប្រុសពៅរបស់យើងបានកើតមកជាមួយនឹងបញ្ហានានា ហើយត្រូវចំណាយពេលពីរបីសប្ដាហ៍នៅក្នុងមន្ទីរព្យាបាលទារកទើបនឹងកើតដែលមានស្ថានភាពធ្ងន់ធ្ងរ ។ ខ្ញុំក៏មានការលំបាកជាមួយនឹងជំងឺបាក់ទឹកចិត្តក្រោយសម្រាលកូនផងដែរ ។ ស្ថានភាពទាំងអស់នេះ រួមនឹងការធ្វើជាឪពុកម្ដាយដល់កូនតូចៗបួននាក់ បានធ្វើឲ្យយើងមានភាពតានតឹងទាំងខាងផ្នែកហិរញ្ញវត្ថុ និងខាងផ្លូវចិត្ត ។

រ៉ាយអិនរកបានការងារថ្មី ប៉ុន្តែគាត់ធ្វើការជាច្រើនម៉ោង ហើយត្រូវទៅក្រៅក្រុងម្ដងៗជាច្រើនសប្ដាហ៍ ។ កូនប្រុសអាយុប្រាំឆ្នាំរបស់យើង វេសលី បានចាប់ផ្ដើមមានការថប់បារម្ភអំពីការដែលប៉ាគាត់ទៅបាត់ជាញឹកញាប់ ។ គាត់ភ្ញាក់ច្រើនដងនៅពេលយប់ដោយសារសុបិនអាក្រក់ ។

សាច់ញាតិរបស់យើងបានជួយគាំទ្រខ្ញុំពេលពួកគេអាចធ្វើបាន ប៉ុន្តែភាគច្រើនបំផុតខ្ញុំនៅតែមានអារម្មណ៍ហត់នឿយ ហើយឯកោ ។ ខ្ញុំដឹងថាព្រះវរបិតាសួគ៌ស្រឡាញ់ ហើយត្រាសដឹងពីគ្រួសារខ្ញុំ ប៉ុន្តែខ្ញុំបានមានអារម្មណ៍ដូចជាយើងកំពុងតែលង់ទឹក ។

នៅរសៀលមួយ ពេលរ៉ាយអិនទៅធ្វើការក្រៅក្រុង ខ្ញុំបានបើកឡានដឹកកូនខ្ញុំទៅផ្ទះពីសាលា ហើយបានអធិស្ឋានជាខ្លាំងដើម្បីសូមជំនួយ ។ ក្រោយមកនៅយប់នោះ អ្នកជិតខាងខ្ញុំ ឃិនដ្រា បានគោះទ្វារផ្ទះយើង ។ គាត់បានដឹងពីស្ថានភាពរបស់យើង ហើយបានសួរថាខ្ញុំមានសុខទុក្ខយ៉ាងណាដែរ ។ ខ្ញុំពុំមានបំណងអ្វីទាំងដាក់គាត់ទេ ហើយគាត់គឺជាមនុស្សចុងក្រោយដែលខ្ញុំនឹងសូមជំនួយ ។ ស្វាមីគាត់ ប្រិនថ៍ បានប្រយុទ្ធនឹងមហារីកអស់បួនឆ្នាំកន្លងមកនេះ ។

ខ្ញុំបានប្រាប់ឃិនដ្រាថាខ្ញុំមិនអីទេ ប៉ុន្តែគាត់បានសួរខ្ញុំម្ដងទៀតដោយស្មោះសរ ។ ខ្ញុំបានបើកដួងចិត្តប្រាប់គាត់ទាំងទឹកភ្នែកពីការលំបាករបស់ខ្ញុំ ។ ពេលខ្ញុំប្រាប់គាត់អំពីការថប់បារម្ភរបស់វេសលី និងសុបិនអាក្រក់ គាត់បានសួរថាបើខ្ញុំចង់ឲ្យប្រិនប្រសិទ្ធិពរដល់វេសលីឬទេ ។

មួយសន្ទុះក្រោយមក ឃិនដ្រា ប្រិនថ៍ និងកូនប្រុសច្បងរបស់ពួកគាត់ ថៃសុន បានមកដល់មាត់ទ្វារយើងនៅក្នុងសំលៀកបំពាក់ព្រះវិហារ ។ ប្រិនថ៍ទន់ខ្សោយ ។ ខ្ញុំប្រាកដណាស់ថា គាត់បានប្រមូលកម្លាំងទាំងអស់ដែលគាត់មានដើម្បីមកផ្ទះយើង ។ គាត់បានប្រសិទ្ធពរវេសលី ហើយថៃសុនបានប្រសិទ្ធិពរដល់ខ្ញុំ ។



នៅថ្ងៃនោះ ឃិនដ្រា ប្រិនថ៍ និងថៃសុន គឺជាគំរូដ៏ពិតនៃការផ្ដល់ការងារបម្រើដូចជាព្រះគ្រីស្ទ ។ ពួកគាត់បានទុកការសាកល្បងរបស់ពួកគាត់មួយឡែក ដើម្បីផ្ដល់សេចក្ដីស្រឡាញ់ និងការអាណិតអាសូរដល់យើងដោយស្មោះសរ ។ ខ្ញុំមានអារម្មណ៍ថាមានពរជ័យដែលព្រះវរបិតាសួគ៌បានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំតាមរបៀបនេះ ។ ប្រិនថ៍បានស្លាប់ពីរសប្ដាហ៍ក្រោយមក ។

នៅថ្ងៃនោះនៅក្នុងផ្ទះរបស់យើង ប្រិនថ៍បានឈរជាសាក្សីម្នាក់របស់ព្រះ តាមរយៈការអនុវត្តបព្វជិតភាពដោយសុចរិត ( សូមមើល ម៉ូសាយ ១៨:៩ ) ។ ចំពោះខ្ញុំ វាពិសិដ្ឋដែលការងារបម្រើរបស់គាត់ដល់គ្រួសារយើងជាទង្វើចុងក្រោយបំផុតមួយនៅលើផែនដីនេះ ។ ■

រចនារូបភាពដោយ ត្រិន ហ្គ័តម៉ាន់សិន

# ទ័ពអាកាសដ៏ក្លាហាន

ដោយ វេន អែល ប៊ែល រដ្ឋសៅកាកូតា ស.រ.អា.

*ពុំមាននរណាម្នាក់ហ៊ានឆ្លើយនឹងគ្រូបង្វឹកទាហាននោះទេ ប៉ុន្តែគួរឲ្យភ្ញាក់ផ្អើល បុរសវ័យក្មេងម្នាក់បានលើកដៃគាត់ ។*

ជាច្រើនឆ្នាំមកហើយខ្ញុំបានចូលកងទ័ពអាកាសសហរដ្ឋអាមេរិកដើម្បីបម្រើប្រទេសខ្ញុំ ។ មិនយូរប៉ុន្មានខ្ញុំបានទៅជំរុំហាត់ទាហាននៅរដ្ឋតិចសាស ស.រ.អា. ។ ពេលវេលាកន្លងទៅយ៉ាងយឺត កាលដែលខ្ញុំតស៊ូនឹងការណ៍ជាច្រើនដែលធម្មតាមាននៅជំរុំហាត់ទាហាន ។

ថ្ងៃមួយខ្ញុំបានចូលរួមការប្រជុំធំមួយដែលមានទ័ពអាកាសជាង ២០០ នាក់ ដែលកំពុងនៅក្នុងការហ្វឹកហាត់ដូចខ្ញុំដែរ ។ ការប្រជុំបានចាប់ផ្តើមជាមួយនឹងគ្រូបង្វឹកម្នាក់របស់យើង—ដែលជាធម្មតាគាត់ស្រែកខ្លាំងៗ ហើយបន្ទាបបន្ថោក—ស្រែកឡើងថា « តើមាននរណាម្នាក់ជំទាស់នឹងរបៀបដែលខ្ញុំដំណើរការណ៍អ្វីៗនៅទីនេះទេ ? »

ប្រាកដណាស់ ពុំមាននរណាម្នាក់ហ៊ានឆ្លើយទេ ប៉ុន្តែគួរឲ្យភ្ញាក់ផ្អើល បុរសវ័យក្មេងម្នាក់បានលើកដៃគាត់ឡើង ។

គ្រូបង្វឹកនោះបានស្រែកថា « ទ័ពអាកាសក្រោកឈរឡើង ! » « តើឯងជំទាស់នឹងអ្វី ? »

យើងទាំងអស់គ្នាបានប្រឹងស្តាប់ ពេលដែលបុរសវ័យក្មេងនោះបានប្រកាសយ៉ាងព្រៃៗថា « ខ្ញុំជំទាស់នឹងលោកប្រើព្រះនាមរបស់ព្រះអង្គសង្គ្រោះរបស់ខ្ញុំដោយឥតបានការ ។ វាធ្វើឲ្យព្រលឹងខ្ញុំឈឺចាប់ ។ ខ្ញុំសូមឲ្យលោកបញ្ឈប់វា » ។

បន្ទប់នោះប្រែជាស្ងាត់ជ្រាប ។ គ្រូបង្វឹកនោះបានសម្លឹងទៅគាត់ ហើយបន្ទាប់មកបានសួរគាត់ថាគាត់នៅសាសនាអ្វី ។ ទ័ពអាកាសដ៏ក្លាហាននេះបាននិយាយដោយមោទនភាពថា « ខ្ញុំគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ! »

គ្រូបង្វឹកនោះបានអរគុណដល់ទ័ពអាកាសនោះសម្រាប់ភាពក្លាហានរបស់គាត់ក្នុងការហ៊ាននិយាយឡើង ហើយការប្រជុំនោះបានបន្តទៅទៀត ។ ទង្វើនោះមានឥទ្ធិពលយ៉ាងធំធេងចំពោះខ្ញុំ ។ ខ្ញុំបានគិតជាញឹកញាប់ថា ខ្ញុំចង់មានភាពក្លាហានដូចឈ្មោះដូចជាទ័ពអាកាសនោះដែរ ។





បន្ទាប់ពីជំរុំហាត់ទាហាន និងការបំពាក់បំប៉នផ្នែកវេជ្ជសាស្ត្រ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅបន្ទាយកងទ័ពអាកាសនៅរដ្ឋខូឡូរ៉ាដូ ស.រ.អា. ។ ថ្ងៃមួយខ្ញុំបានទទួលសំបុត្រពីបងប្រុសច្បងបង្អស់របស់ខ្ញុំដែលឈរជើងនៅប្រទេសហ្វីលីពីន ។ គាត់បានចូលកងទ័ពអាកាសប្រហែលមួយឆ្នាំមុនខ្ញុំចូល ។ គាត់បានប្រាប់ខ្ញុំថា គាត់បានចូលជាសមាជិកសាសនាចក្រ ហើយគាត់ចង់ឲ្យខ្ញុំជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ។ ភ្លាមៗនោះខ្ញុំបាននឹកឃើញពីបទពិសោធន៍នៅក្នុងជំរុំហាត់ទាហានជាមួយនឹងទ័ពអាកាសដ៏ក្លាហាននោះ ។ ភរិយាខ្ញុំ និងខ្ញុំបានជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ហើយមិនយូរប៉ុន្មានយើងបានទទួលបុណ្យជ្រមុជទឹក ។

ពីរបីខែក្រោយមក ខ្ញុំបានឲ្យពួកអ្នកផ្សព្វផ្សាយសាសនាជួបនឹងប្អូនប្រុសខ្ញុំ ។ គាត់ និងភរិយាគាត់បានទទួលបុណ្យជ្រមុជទឹកផងដែរ ។ ឥឡូវនេះបងប្អូនប្រុសខ្ញុំ និងខ្ញុំមានកូនចៅជាច្រើននាក់ ។ យើងទាំងអស់គ្នាស្រឡាញ់ព្រះអម្ចាស់ និងសាសនាចក្ររបស់ទ្រង់ ។

ខ្ញុំមិនស្គាល់ឈ្មោះរបស់ទ័ពអាកាសដ៏ក្លាហាននោះទេ ។ ខ្ញុំមិនដែលបានជួបគាត់ម្តងទៀតឡើយ ប៉ុន្តែខ្ញុំនឹងមានអំណរគុណដ៏អស់កល្បជានិច្ចសម្រាប់ភាពក្លាហានរបស់គាត់ ដើម្បីក្រោកឈរសម្រាប់អ្វីដែលគាត់ជឿ ។ ■

# ការរង់ចាំការសន្យា

ដោយ វ៉ែណ្ណា ម៉ូរេណូ ដេ រូស្ស ទីក្រុងសូណូរ៉ា ប្រទេសម៉ិកស៊ិក

*កូនស្រីខ្ញុំបានឃ្លាតចេញឆ្ងាយពីសាសនាចក្រ ប៉ុន្តែខ្ញុំដឹងថា នាងនឹងទទួលពរជ័យដោយអ្វីៗដែលនាងត្រូវបានបង្រៀនអំពីដំណឹងល្អ ។*

បីខែមុនពេលឈានដល់អាយុ ២១ ឆ្នាំ ខ្ញុំបានទទួលបុណ្យជ្រមុជទឹកជាមួយបងស្រីខ្ញុំ ម្ដាយខ្ញុំ និងក្មួយប្រុសអាយុប្រាំបីឆ្នាំរបស់ខ្ញុំ ។ ប៉ុន្មានឆ្នាំមកនេះ យើងបានតោងជាប់នឹងដំណឹងល្អ ទោះយើងមានឧបសគ្គនានាក្ដី ។

ពេលស្វាមីខ្ញុំ និងខ្ញុំរៀបការ យើងបានប្ដេជ្ញាចិត្តថានឹងបន្តសកម្មនៅក្នុងសាសនាចក្រ ។ ពេលយើងមានកូន ស្វាមីខ្ញុំ និងខ្ញុំប្រឹងប្រែងដើម្បីធ្វើជាឪពុកម្ដាយល្អ ហើយបង្រៀនដំណឹងល្អនៅក្នុងផ្ទះរបស់យើង ។



ថ្ងៃមួយខ្ញុំបានចូលរួមសន្និសីទមួយជាមួយកូនស្រីអាយុមួយឆ្នាំរបស់ខ្ញុំ ។ នៅក្នុងសន្និសីទនោះ ពួកចិតសិបប្រចាំតំបន់ម្នាក់បាននិយាយអំពីការទទួលខុសត្រូវរបស់ឪពុកម្ដាយក្នុងការបង្រៀនដំណឹងល្អដល់កូនចៅរបស់ពួកគេ ។ បន្ទាប់មកលោកបានធ្វើការសន្យាមួយដែលបានមានឥទ្ធិពលយ៉ាងធំធេងលើខ្ញុំ ។ លោកបានមានប្រសាសន៍ ៖ « បន្ទាប់ពីអ្វីៗដែលអាចធ្វើដើម្បីបង្រៀនដំណឹងល្អ នោះប្រសិនបើកូនណាម្នាក់របស់អ្នកចាកចេញពីសាសនាចក្រ ពួកគេនឹងនៅតែទទួលពរដោយសារការចងចាំពីការណ៍ទាំងឡាយដែលពួកគេបានដកពិសោធន៍នៅផ្ទះ » ។

ពាក្យសម្ដីរបស់ពួកចិតសិបប្រចាំតំបន់នោះ បានធ្វើឲ្យខ្ញុំពោរពេញដោយសេចក្ដីសង្ឃឹម ដោយសារខ្ញុំមានក្មួយស្រី និងក្មួយប្រុសដែលបានចាកចេញពីសាសនាចក្រ ។ ជាច្រើនឆ្នាំក្រោយមក កូនស្រីរបស់ខ្ញុំ ជាកូនអាយុមួយឆ្នាំដដែលដែលខ្ញុំបានបីនៅក្នុងដៃអំឡុងពេលសន្និសីទនោះ នាងបានចាកចេញពីសាសនាចក្រពេលនាងអាយុ ១៧ ឆ្នាំ ។ នាងបានជួបនឹងមនុស្សម្នាក់ដែលពុំមានទីបន្ទាល់រឹងមាំអំពីដំណឹងល្អ ហើយពួកគេបានរៀបការ ។ នាងមិនដែលទៅព្រះវិហារទៀតតាំងពីនោះមក ។

វាធ្វើឲ្យខ្ញុំឈឺចាប់ណាស់ ។ ខ្ញុំបានសួរខ្លួនឯងម្ដងហើយម្ដងទៀតថាខ្ញុំបានធ្វើអ្វីខុស ។ ឪពុកនាង និងខ្ញុំតែងតែព្យាយាមរក្សាបទបញ្ញត្តិ ហើយបម្រើនៅក្នុងសាសនាចក្រ ។ យើងស្រឡាញ់កូនៗយើង ហើយចង់បានអ្វីដែលល្អបំផុតសម្រាប់ពួកគេ ។ បន្ទាប់ពីស្រក់ទឹកភ្នែកអស់ជាច្រើនដំណក់ និងសំណួរជាច្រើន នៅទីបំផុតយើងបានសន្និដ្ឋានថា កូនៗធំហើយ ពួកគេអនុវត្តសិទ្ធិជ្រើសរើសរបស់ពួកគេ ហើយមិនតែងតែជឿលើអ្វីដែលពួកគេត្រូវបានបង្រៀននៅផ្ទះនោះទេ ។

ជាអកុសល អាពាហ៍ពិពាហ៍របស់កូនស្រីខ្ញុំបែកបាក់ ហើយនាងនៅតែមិនចង់ត្រឡប់មកព្រះវិហារវិញទេ ។ អ្វីដែលខ្ញុំអាចធ្វើគឺចងចាំការសន្យានោះថា នាងនឹងចងចាំ ហើយទទួលពរជ័យដោយសារតែការណ៍ទាំងឡាយដែលនាងត្រូវបានបង្រៀននៅផ្ទះ ។

ខ្ញុំបន្តអធិស្ឋានសម្រាប់កូនស្រីរបស់ខ្ញុំ ។ ខ្ញុំស្រឡាញ់នាងអស់ពីដួងចិត្តខ្ញុំ ហើយវាធ្វើឲ្យខ្ញុំឈឺចាប់ដែលឃើញនាងឃ្លាតឆ្ងាយពីសាសនាចក្រ ។ ប៉ុន្តែខ្ញុំដឹងថា ថ្វីបើខ្ញុំមិនល្អឥតខ្ចោះក្ដី តែការណ៍ទាំងឡាយដែលខ្ញុំបានបង្រៀនដល់នាងគឺត្រឹមត្រូវ និងពិត ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌យុត្តិធម៌ ហើយពោរពេញដោយក្ដីស្រឡាញ់ ហើយថាទ្រង់ព្រះសណ្ដាប់ដល់ការអធិស្ឋានរបស់យើង ។ ដោយគ្មានការសង្ស័យនៅក្នុងដួងចិត្ត ខ្ញុំដឹងថា ប្រសិនបើខ្ញុំធ្វើផ្នែករបស់ខ្ញុំ នោះទ្រង់នឹងឆ្លើយតបនៅក្នុងគ្រាដែលទ្រង់ឃើញថាត្រឹមត្រូវ ។ ■

គំនូររូបភាពដោយ មីហ្គិន សៅហ្គាដ

# « នរណាបើកឡានបុកកូនប្រុសខ្ញុំ ? »

ដោយ សេនដ្រា ប៊ីតធី ខេត្តអនតារីយ៉ូ ប្រទេសកាណាដា

*ខ្ញុំបានប្រមើលមើលខ្លួនឯងស្រែកគំហកដាក់មនុស្សដែលបានបើកឡានបុកកូនខ្ញុំ ក្រោយមកខ្ញុំបានជួបដោយផ្ទាល់មុខនឹងអ្នកបើកឡាន ។*

ខ្ញុំទើបនឹងទម្លាក់កូនស្រីខ្ញុំនៅផ្ទះមិត្តភក្តិ ពេលដែលខ្ញុំបានទទួលទូរសព្ទពីស្វាមីខ្ញុំ ចនណាថាន ។ គាត់បានប្រាប់ខ្ញុំថាកូនប្រុសអាយុដប់មួយឆ្នាំរបស់យើង អែដិន ត្រូវបានឡានមួយបុកពេលគាត់ និងចនណាថាន កំពុងដើរឆ្លងផ្លូវ ។

អ្នកបើកឡាននោះបានបត់ឆ្វេងនៅមុខចនណាថាន ហើយមិនបានឃើញអែដិនកំពុងជិះកង់គាត់ទេ ។ អ្នកបើកឡាននោះបានបុកពីមុខកង់របស់អែដិន ។ គាត់ហោះទៅលើអាកាស នៅតែកាន់កង់គាត់ជាប់ ហើយបានបោកក្បាលគាត់ទៅនឹងចំហៀងឡានពេលគាត់ធ្លាក់មកក្រោម ។ បន្ទាប់មកគាត់ធ្លាក់នៅលើផ្លូវដោយមានកង់គាត់សង្កត់លើគាត់ ។ អរគុណណាស់ដែលគាត់ពាក់មួកការពារ ។ អ្នកបើកឡាន និងមនុស្សផ្សេងទៀតបានឈប់ដើម្បីជួយពេលដែលចនណាថានបានទូរសព្ទហៅរថយន្តសង្គ្រោះបន្ទាន់ ។

មួយរំពេចនោះ គំនិត និងអារម្មណ៍ខ្ញុំរករឹខ្លាំងណាស់ ។ ខ្ញុំបានបើកឡានយ៉ាងលឿនទៅផ្លូវប្រសព្វដែលគ្រោះថ្នាក់បានកើតឡើងនោះ ដោយសង្ឃឹមថាអាចទៅទាន់រថយន្តសង្គ្រោះបន្ទាន់ដើម្បីខ្ញុំអាចនៅជាមួយនឹងអែដិន ។

ខ្ញុំបានគិតថានឹងតទល់នឹងអ្នកបើកឡាននោះដោយកំហឹង ។ « តើអ្នកបើកឡាននោះកំពុងគិតអ្វី ? » ខ្ញុំបានគិត ។ « តើគេស្រវឹងមែនទេ ? តើគេកំពុងប្រើទូរសព្ទឬ ? » ខ្ញុំខឹងខ្លាំងណាស់ ហើយហួសពីព្រួយបារម្ភទៀត ។ ខ្ញុំមិនដឹងទេថាអែដិនឈឺប៉ុណ្ណានោះ ។

ពេលខ្ញុំមកដល់កន្លែងកើតហេតុ រថយន្តសង្គ្រោះបន្ទាន់បានចេញបាត់ទៅហើយ ។ មានតែឡានប៉ូលីសពីរ និងឡានមួយទៀតបានចតនៅខាងផ្លូវដែលនៅនឹងកន្លែងកើតហេតុ ។ ស្ត្រីម្នាក់ដែលមើលទៅពោរពេញដោយទុក្ខព្រួយបានឈរនៅក្បែរឡាននោះ ។

ខ្ញុំបានដើរទៅកាន់គាត់ ហើយបានសួរថា « តើអ្នកបានឃើញនរណាបុកកូនប្រុសខ្ញុំទេ ? »

គាត់បាននិយាយស្ងាត់ស្ងៀមថា « ខ្ញុំបានធ្វើ » ។

ខ្ញុំបានប្រមើលមើលខ្លួនឯងស្រែកគំហកដាក់មនុស្សដែលមិនខ្វល់ខ្វាយដែលបានបើកឡានបុកកូនខ្ញុំ ប៉ុន្តែពេលខ្ញុំបានជួបដោយផ្ទាល់មុខនឹងអ្នកបើកឡាននោះ ភាពអវិជ្ជមានបានសាត់បាត់ទៅ ។ ខ្ញុំបានយំ ហើយឱបគាត់ ។ គាត់បានសូមទោស ហើយខ្ញុំបានប្រាប់គាត់ថាអ្វីៗនឹងមិនអីទេ ។ ក្រោយមកខ្ញុំបានដឹងថា នោះជាពាក្យដូចគ្នាដែលអែដិនបាននិយាយទៅកាន់គាត់ពីមុនប៉ូលីសមកដល់ ។ នៅចុងបញ្ចប់ អែដិនបានឆ្លងផុតដោយគ្រាន់តែមានស្នាម និងជាំមួយចំនួនប៉ុណ្ណោះ ។

ខ្ញុំមានអំណរគុណដែលនៅគ្រាដ៏សំខាន់ក្រៃលែងនោះ ព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើងបានប្រទានពរខ្ញុំឲ្យមានកម្លាំងដើម្បីផ្តល់ការអត់ទោសជំនួសឲ្យការស្អប់ សូម្បីតែពេលដែលខ្ញុំមិនបានទូលសូមដល់ទ្រង់ ។ ខ្ញុំដឹងថា ទ្រង់ជ្រាបដឹងពីយើង ហើយតែងតែប្រទានជំនួយរបស់ទ្រង់ដល់យើង ។ ■



រចនារូបភាពដោយ អែលលើរ អាណាយស៍

# អាលម៉ា ២៣–២៩

ថ្ងៃទី ២៩ ខែ មិថុនា–ថ្ងៃទី ៥ ខែ កក្កដា

ក្រោយពីការប្រែចិត្តជឿរបស់ពួកគេ ពួកសាសន៍លេមិនដ៏ស្មោះត្រង់ចង់បានឈ្មោះថ្មីមួយដើម្បីបំបែកពួកគេពីពួកសាសន៍លេមិនដទៃទៀត និងដើម្បីជាសញ្ញាដល់ការប្រែចិត្តជឿរបស់ពួកគេដល់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេបានហៅខ្លួនឯងថាសាសន៍អាន់តៃ-នីហ្វ-លីហៃ ( សូមមើល អាលម៉ា ២៣:១៦–១៧ ) ។ យើងបំបែកខ្លួនយើងសព្វថ្ងៃនេះដោយការយកព្រះនាមព្រះយេស៊ូវមកដាក់លើខ្លួនយើង ។

## តើអ្វីជាសារសំខាន់នៃឈ្មោះមួយ ?



### និមិត្តរូបនៃការប្រែចិត្តជឿរបស់យើង

នៅឯពិធីបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញាដើម្បីលើកដាក់លើខ្លួនយើងនូវព្រះនាមរបស់ព្រះគ្រីស្ទ ។ រាល់ដងដែលយើងទទួលទានសាក្រាម៉ង់ យើងរំឭកចាំសេចក្តីសញ្ញារបស់យើង ។ តើយើងធ្វើសេចក្តីសញ្ញាដើម្បីចងចាំ និងធ្វើអ្វីខ្លះ ពេលយើងលើកដាក់លើខ្លួនយើងនូវព្រះនាមរបស់ទ្រង់ ? ( សូមមើល ម៉ូសាយ ១៨:៨–៩; គោលលទ្ធិ និង សេចក្តីសញ្ញា ២០:៧៧ ) ។



### សាក្សីអំពីព្រះគ្រីស្ទ

ពួកសាវកជា « ពួកសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទនៅពេញសព្វក្នុងពិភពលោក » ( គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:២៣ ) ។ យើងអាចធ្វើជាសាក្សីអំពីព្រះគ្រីស្ទផងដែរ ។ តើបងប្អូនអាចឈរជាមួយនឹងពួកព្យាការី និងសាវក ហើយធ្វើជាសាក្សីម្នាក់អំពីព្រះនាមនៃព្រះគ្រីស្ទដល់មនុស្សនៅជុំវិញបងប្អូនយ៉ាងដូចម្តេច ?



### ប្រភពនៃអំណាច

ថ្មីៗនេះ ប្រធាន រ័សុល អិម ណិលសុន បានទទូចយើងឲ្យហៅសាសនាចក្រតាមឈ្មោះត្រឹមត្រូវ ៖ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ លោកបានសន្យាថា អំណាចនឹងចាក់ស្រោចលើពួកបរិសុទ្ធកាលដែលយើងធ្វើដូច្នោះ ( សូមមើល « The Correct Name of the Church » *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៨៩ ) ។ តើមានអ្វីខ្លះដែលបងប្អូនអាចធ្វើដើម្បីប្រើប្រាស់ឈ្មោះត្រឹមត្រូវរបស់សាសនាចក្រឲ្យបានកាន់តែប្រសើរ ហើយជួយអ្នកផ្សេងទៀតឲ្យធ្វើដូចគ្នាដែរនោះ ?

រូបសញ្ញាដោយ ប្រាយអិន ប៊ីច



### ការពិភាក្សា

តើការលើកយកព្រះនាមរបស់ព្រះគ្រីស្ទដាក់លើខ្លួនបងប្អូននៅក្នុងការគិត និងសកម្មភាពប្រចាំថ្ងៃរបស់បងប្អូន ជំរុញបងប្អូនឲ្យក្លាយជាសិស្សកាន់តែល្អរបស់ទ្រង់យ៉ាងដូចម្តេច ?

អាលម៉ា ៣០–៣១
ថ្ងៃទី ៦–១២ ខែ កក្កដា

# តើយើងអាចទប់ទល់នឹងការបង្រៀនក្លែងក្លាយដោយរបៀបណា ?

កូរីហូរជាអ្នកទទឹងនឹងព្រះគ្រីស្ទ ដែលបានផ្សព្វផ្សាយ « ទាស់នឹងពាក្យព្យាករណ៍ទាំងឡាយ ដែលបានថ្លែងដោយពួកព្យាការី អំពីការយាងមកនៃព្រះគ្រីស្ទ » ( អាលម៉ា ៣០:៦ ) ។ គាត់បានផ្សព្វផ្សាយភាពមិនពិតផ្សេងៗទៀត ហើយបាននាំឲ្យ « បង្វែរចិត្តមនុស្សជាច្រើនចេញ » ( អាលម៉ា ៣០:១៨ ) ។

សូម្បីតែការណ៍នេះបានកើតឡើងជាង ២០០០ ឆ្នាំកន្លងមកហើយក្តី ក៏មនុស្សជាច្រើននៅសព្វថ្ងៃនេះផ្សព្វផ្សាយពីការណ៍ស្រដៀងគ្នានេះផងដែរ ។ តើយើងអាចធ្វើអ្វីខ្លះដើម្បីពង្រឹងខ្លួនយើងទាស់នឹងការបង្រៀនខុសឆ្គងនៅក្នុងជំនាន់របស់យើង ?

### យើងអាចទទួលទីបន្ទាល់ដោយខ្លួនយើងផ្ទាល់

កូរីហូរបានបង្រៀនមនុស្សថា « គ្មានព្រះគ្រីស្ទទេ » ហើយ « ពុំអាចមានដង្វាយធួន » ហើយគាត់បានបដិសេធថាមានព្រះ ( សូមមើល អាលម៉ា ៣០:១២, ១៧, ២៨ ) ។

តើយើងអាចដឹងថាព្រះ និងព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ដោយរបៀបណា ? តើព្រះគម្ពីរ និងបទពិសោធន៍ផ្ទាល់ខ្លួនអាចពង្រឹងទីបន្ទាល់របស់បងប្អូនអំពីពួកទ្រង់ដោយរបៀបណា ?

### យើងអាចទុកចិត្តលើវិវរណៈបាន

កូរីហូរបានបដិសេធវិញ្ញាណនៃការព្យាករណ៍ និងនៃវិវរណៈ ។ គាត់បានព្យាយាមធ្វើឲ្យមនុស្សជឿថា « គ្មានមនុស្សណាអាចដឹងនូវអ្វីដែលនឹងកើតឡើងនោះទេ » ហើយ « អ្នករាល់គ្នាមិនអាចដឹងនូវអ្វីៗដែលអ្នករាល់គ្នាមើលមិនឃើញនោះទេ » ( អាលម៉ា ៣០:១៣, ១៥ ) ។

យើងអាចសម្លឹងទៅពួកព្យាការី និងសាវកដើម្បីទទួលបានព្រះបន្ទូលរបស់ព្រះសម្រាប់សម័យកាលរបស់យើង ។ តើការធ្វើតាមព្យាការីការពារបងប្អូនដើម្បីទាស់នឹងការបង្រៀនខុសឆ្គងដោយរបៀបណា ?



### យើងអាចចងចាំថាសេចក្តីពិតគឺជាសេចក្តីពិត

កូរីហូរបានប្រាប់ប្រជាជនថា ពុំមានរបៀបណាដែលពួកគេអាចដឹងពីអ្វីដែលពិតបានឡើយ ( សូមមើល អាលម៉ា ៣០:២៤ ) ប៉ុន្តែប្រធាន រ័សុល អិម ណិលសុន បានបង្រៀន ៖ « រឿងខ្លះគឺពិត ។ . . . « . . . សេចក្តីពិតគឺផ្អែកលើច្បាប់ដែលព្រះបានបង្កើត ។ . . . ច្បាប់ដ៏អស់កល្បទាំងឡាយអនុវត្តនៅក្នុង ហើយប៉ះពាល់ដល់ជីវិតយើងម្នាក់ៗ មិនថាយើងជឿលើវា ឬអត់នោះទេ » ( « The Love and Laws of God » [ Brigham Young University devotional ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៩ ] speeches.byu.edu ) ។ តើយើងអាចរកឃើញសេចក្តីពិតរបស់ព្រះដោយរបៀបណា ហើយតើវាផ្តល់ពរជ័យដល់យើងយ៉ាងណា ?

### ការពិភាក្សា

តើនរណាជាអ្នកបង្រៀនភាពមិនពិតទាំងឡាយនៅសព្វថ្ងៃនេះ ? តើពួកគេបញ្ជូនសារដំណឹងអ្វីខ្លះ ? តើព្រះបានប្រទានអ្វីដល់យើងដើម្បីទប់ទល់នឹងភាពមិនពិតទាំងឡាយ ហើយរៀនពីសេចក្តីពិត ?

រូបភាពយកពី GETTY IMAGES

អាលម៉ា ៣២–៣៥
ថ្ងៃទី ១៣–១៩ ខែ កក្កដា

# តើហេតុអ្វីបានជាអាលម៉ាចែកចាយរឿងរ៉ាវអំពីម៉ូសេ និងសត្វពស់លង្ហិន ?



បន្ទាប់ពីអាលម៉ាប្រៀបធៀបព្រះបន្ទូលនៃព្រះទៅនឹងគ្រាប់ពូជមួយ ( សូមមើល អាលម៉ា ៣២:២៨–៤៣ ) នោះប្រជាជនបានសួរលោកពីរបៀបដើម្បីដាំគ្រាប់ពូជនោះ ។ អាលម៉ាបានប្រើប្រាស់ដំណើររឿងរបស់ម៉ូសេ និងពស់លង្ហិន ចេញពី ជនគណនា ទំពូក ២១ ជាគំរូអំពីការប្រព្រឹត្តិដោយសេចក្តីជំនឿ ( សូមមើល អាលម៉ា ៣៣:១៩–២៣ ) ។

## និមិត្តរូបមួយនៃព្រះគ្រីស្ទ

*និមិត្តរូបមួយ*គឺជាអ្វីមួយដែលតំណាង ឬបង្ហាញជាមុនពីវត្ថុមួយ ឬបុគ្គលម្នាក់ ។ ពេលសាសន៍អ៊ីស្រាអែលត្រូវបានខាំដោយពស់មានពិស នោះម៉ូសេបានលើកឡើងនូវពស់លង្ហិននោះ ដែលក្លាយជានិមិត្តរូបមួយនៃព្រះគ្រីស្ទ ។ អស់អ្នកណាដែលប្រព្រឹត្តិដោយសេចក្តីជំនឿ ហើយសម្លឹងទៅវា ត្រូវបានព្យាបាលឲ្យជា ដូចដែលអស់អ្នកទាំងឡាយណាដែលប្រព្រឹត្តិដោយសេចក្តីជំនឿលើព្រះគ្រីស្ទនឹងត្រូវបានព្យាបាលខាងវិញ្ញាណដែរ ។

## មនុស្សខ្លះបានពង្រឹងចិត្តរបស់ពួកគេ

ដោយព្រោះវាងាយស្រួលពេកដោយគ្រាន់តែសម្លឹងមើល នោះមនុស្សខ្លះបានពង្រឹងចិត្តរបស់ពួកគេ ហើយបានបដិសេធ ហើយពួកគេបានស្លាប់ដោយសារមកពីត្រូវបានចឹក ។ ហេតុអ្វីពួកគេមិនបានសម្លឹង ? ( សូមមើល អាលម៉ា ៣៣:២០ ) ។ តើរឿងនេះបង្រៀនអ្វីដល់យើងអំពីសេចក្តីជំនឿ និងការមិនជឿ ?

## តើបងប្អូននឹងបានព្យាបាលដែរឬទេ ?

ប្រសិនបើបងប្អូនអាចបានជាដោយការធ្វើអ្វីមួយដែលសាមញ្ញដូចជាការសម្លឹងមើល តើនឹងមិនធ្វើវាទេឬ ? អាលម៉ាបានចោទជាសំណួរនេះឡើង ហើយអញ្ជើញយើងឲ្យសម្លឹងទៅព្រះអង្គសង្គ្រោះដោយជឿលើទ្រង់ ( សូមមើល អាលម៉ា ៣៣:២១–២២ ) ។

## ការពិភាក្សា

ពួកសាសន៍អ៊ីស្រាអែលគ្រាន់តែត្រូវសម្លឹងមើលប៉ុណ្ណោះដើម្បីបានជា ។ តើគោលការណ៍ដំណឹងល្អណាខ្លះដែលហាក់ដូចជាងាយស្រួលដូចជា « ការសម្លឹងមើល » នោះ ? តើឥរិយាបថ ឬការប្រព្រឹត្តិអ្វីខ្លះ ដែលរារាំងយើងពីការរស់នៅតាមគោលការណ៍ដំណឹងល្អដ៏សាមញ្ញនោះ ?

តើបងប្អូនអាចសម្លឹងទៅកាន់ព្រះអង្គសង្គ្រោះនៅក្នុងការណ៍ទាំងឡាយដែលបងប្អូនជួបប្រទះជារៀងរាល់ថ្ងៃដោយរបៀបណា ?

ចេញរូបភាពដោយ ដាន ប៊ឺ

អាលម៉ា ៣៦–៣៨

ថ្ងៃទី ២០–២៦ ខែ កក្កដា៦

# តើការប្រែចិត្តផ្លាស់ប្ដូរទុក្ខព្រួយទៅជាអំណរតាមរបៀបណា ?

អាលម៉ាបានចែកចាយបទពិសោធន៍នៃការប្រែចិត្តជឿរបស់លោកជាមួយហេលេមិនជាកូនប្រុសលោក ។ អាលម៉ាបានប្រាប់គាត់ពីរបៀបដែលលោក « ត្រូវញាំញីដោយសេចក្ដីទុក្ខវេទនា » ដោយសារតែ « អស់ទាំងអំពើបាប [ របស់លោក ] » ( អាលម៉ា ៣៦:១២–១៣ ) ។ តើអ្នកមានអារម្មណ៍ដូចម្ដេច នៅពេលអ្នកដកពិសោធន៍អារម្មណ៍ថាមានកំហុសដោយសារអំពើបាប ?



### កើតពីព្រះ

បន្ទាប់ពីបីថ្ងៃនៃសេចក្ដីទុក្ខវេទនានៅខាងក្នុងចិត្ត អាលម៉ាបានមានគំនិតមួយដែលបានសម្រួលដល់ទុក្ខវេទនាដែលលោកទទួលនោះ ( សូមមើល អាលម៉ា ៣៦:១៩ ) ។ លោកបានថ្លែងទីបន្ទាល់ថាលោកបាន « កើតមកអំពីព្រះ » ( អាលម៉ា ៣៦:២៣ ) ។ តើគំនិតអ្វីដែលបានដឹកនាំទៅកាន់ការកើតមកអំពីព្រះរបស់លោក ? ( សូមមើល ខទី ១៨ ) ។

### អំណរបន្ទាប់ពីទុក្ខព្រួយដ៏ធំធេង

អាលម៉ាបានដកពិសោធន៍នូវទុក្ខព្រួយដ៏ធំ ដោយសារតែអំពើបាបរបស់លោក ប៉ុន្តែពេលលោកបានចងចាំ ហើយបានអំពាវនាវដល់ព្រះយេស៊ូវគ្រីស្ទ នោះទុក្ខព្រួយរបស់លោកត្រូវបានជំនួសដោយអំណរនៃការអត់ទោសដ៏ផ្អែមល្ហែម និងជ្រួតជ្រាប ( សូមមើល អាលម៉ា ៣៦:២០ ) ។

### ទុកចិត្តលើព្រះ

ដោយការចងចាំនូវដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអាលម៉ាបានរៀនដើម្បីទុក្ខចិត្តលើព្រះ ហើយបានដឹងថា លោកនឹងត្រូវបានលើកឡើងនៅថ្ងៃចុងក្រោយ ( សូមមើល អាលម៉ា ៣៦:៣ ) ។ តើការចងចាំ និងពឹងផ្អែកលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះនាំអំណរដល់បងប្អូនដោយរបៀបណា ?

### ការពិភាក្សា

តើបងប្អូនអាចធ្វើអ្វីខ្លះដើម្បីបន្តទុកចិត្តលើព្រះអម្ចាស់ ហើយចងចាំការលះបង់ដ៏ធួនរបស់ទ្រង់ ?

តើបងប្អូនអាចនាំព្រលឹងកាន់តែច្រើនមកកាន់ការប្រែចិត្តដើម្បីឲ្យពួកគេអាចដកពិសោធន៍នូវអំណរដ៏អស្ចារ្យ និងជារៀងរហូតផងដែរដោយរបៀបណា ?

រូបភាពដោយ ប៊ែន ស៊ីម៉ុនស៊ិន

# ខ្ញុំប្រឈមនឹងការទាក់ចិត្តនឹងភេទដូចគ្នា—

## តើសមាជិកសាសនាចក្រស្វាគមន៍ខ្ញុំវិញទេ ?



**ប៊ូយ « បប់ » អេស. អេកូម៉ា វើសធេច**

*កំណត់ចំណាំពីអ្នកនិពន្ធ ៖ ខ្ញុំចែកចាយរឿងរ៉ាវរបស់ខ្ញុំជាការបង្ហាញនូវការដឹងគុណរបស់ខ្ញុំចំពោះថ្នាក់ដឹកនាំ និងសមាជិកសាសនាចក្រ ដែលបានលាដៃស្វាគមន៍ខ្ញុំ បានជួយខ្ញុំត្រឡប់មកសកម្មពេញលេញវិញ ហើយបានបម្រើប្រកៀកនឹងខ្ញុំក្នុងនាមជាសិស្សរបស់ព្រះគ្រីស្ទ ។*

នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៣ បន្ទាប់ពីការប្រយុទ្ធនឹងជំងឺភ្លេចភ្លាំងអស់ជាយូរ ដៃគូជីវិតរបស់ខ្ញុំដែលបាននៅជាមួយគ្នាអស់ ២៥ ឆ្នាំ បានទទួលមរណភាព ។ ជេ អ៊ែល ឌ្រីហ្គគឺជាអ្នកឯកទេសខាងជំងឺបេះដូងដ៏ល្បីនៅលើពិភពលោក ។ យើងទាំងពីរនាក់បានបម្រើបេសកកម្មសម្រាប់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពេលយើងនៅក្មេង ប៉ុន្តែក្រោយមកបានឃ្លាតឆ្ងាយពីសាសនាចក្រដោយសារមានការទាក់ចិត្តនឹងភេទដូចគ្នា ។

មរណភាពរបស់ជេ ទោះជាមិនបានរំពឹងទុកក្ដី គឺធ្វើឲ្យខ្ទេចខ្ទាំចិត្តណាស់ ។ ខ្ញុំមានអារម្មណ៍ខូចចិត្តជាខ្លាំង វង្វេង និងឯកោ ។

ពេលកំពុងបើកឡានមកផ្ទះវិញបន្ទាប់ពីធ្វើការរៀបចំបុណ្យសព ខ្ញុំបានទទួលឥទ្ធិពលពីព្រះវិញ្ញាណសន្ធប់លើខ្ញុំយ៉ាងខ្លាំងរហូតដល់ខ្ញុំត្រូវតែឈប់ឡាននៅចិញ្ចើមផ្លូវ ។ ខ្ញុំបានដឹងថា ព្រះកំពុងមានព្រះបន្ទូលមកខ្ញុំ កំពុងហៅខ្ញុំឲ្យត្រឡប់ទៅកាន់ទ្រង់វិញ ប៉ុន្តែខ្ញុំបានមានចិត្តរឹងរូស ។ « តើទ្រង់មិនឃើញទេឬថាខ្ញុំកំពុងតែរងទុក្ខ ? » ខ្ញុំបាននិយាយឮៗ ។ « ខ្ញុំមិនអាចប្រឈមនឹងការត្រឡប់ទៅកាន់ព្រះវិហារវិញទេឥឡូវនេះ » ។

ប៉ុន្តែពេលដែលខ្ញុំកាន់តែតតាំង ព្រះវិញ្ញាណមានឥទ្ធិពលមកលើខ្ញុំកាន់តែខ្លាំង អញ្ជើញខ្ញុំឲ្យត្រឡប់ទៅព្រះវិហារវិញ ។



**តើពួកគេនឹងទទួលខ្ញុំទេ ?**

ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងក្នុងការត្រឡប់ទៅព្រះវិហារវិញ ។ ខ្ញុំពុំបានទៅការប្រជុំសាក្រាម៉ង់អស់ ២៥ ឆ្នាំហើយ ។ តើពួកគេនឹងទទួលខ្ញុំទេ ? តើខ្ញុំទទួលយកពួកគេទេ ? តើប៊ីស្សពនឹងនិយាយយ៉ាងណា ? ខ្ញុំមានការថប់បារម្ភ ហើយមិនប្រាកដ ហើយនៅតែមានទុក្ខសោកយ៉ាងខ្លាំងនៅឡើយ ។

ប៉ុន្តែទីបន្ទាល់របស់ខ្ញុំអំពីដំណឹងល្អមិនដែលចុះខ្សោយទេនៅជាច្រើនឆ្នាំមកនេះ ។ ជេ និងខ្ញុំស្រឡាញ់សាសនាចក្រ និងគោលការណ៍ណែនាំរបស់វា—ពោលគឺ សេចក្តីសប្បុរស សេចក្តីមេត្តាករុណា និងការអត់ទោស ។ ខ្ញុំបានដឹងថា ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ ហើយថាសាសនាចក្ររបស់ទ្រង់គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ខ្ញុំបានដឹងការណ៍នោះតាំងពីការប្រែចិត្តជឿ និងការជ្រមុជទឹករបស់ខ្ញុំនៅពេលខ្ញុំអាយុ ១៤ ឆ្នាំម្ល៉េះ ។ ខ្ញុំនឹងមិនបដិសេធការណ៍នោះឥឡូវនេះទេ ។

នៅទីបំផុត បន្ទាប់ពីប្រមូលផ្តុំនូវភាពក្លាហានគ្រប់គ្រាន់ហើយ ខ្ញុំបានទូរសព្ទទៅវួដលីនវូដនៅក្នុងរដ្ឋនូវជើស៊ី ស.រ.អា. ដើម្បីដឹងពីថាម៉ោងណាដែលការប្រជុំសាក្រាម៉ង់ចាប់ផ្តើម ។

ពេលថ្ងៃអាទិត្យឈានចូលមកដល់ មារសត្រូវបានដាក់ឧបសគ្គជាច្រើននៅតាមផ្លូវរបស់ខ្ញុំ ដែលអាចរារាំងខ្ញុំពីការទៅចូលរួមបានយ៉ាងងាយ ។ ខ្ញុំមានអំណរគុណណាស់ដែលព្រះវិញ្ញាណបរិសុទ្ធមានះតស៊ូនឹងខ្ញុំ ។

ខ្ញុំបានមានអារម្មណ៍ភ័យខ្លាច ពេលខ្ញុំចូលទៅក្នុងអគារ ប៉ុន្តែទំនុកតម្កើងបើកនៅក្នុងការប្រជុំសាក្រាម៉ង់បានបញ្ជាក់ដល់ខ្ញុំជាថ្មីថា ខ្ញុំបានត្រឡប់មកផ្ទះម្តងទៀតហើយ ។ ទំនុកតម្កើង « មក មក ពួកបរិសុទ្ធ » ( ទំនុកតម្កើង លេខ ១៨ ) បានអញ្ជើញព្រះវិញ្ញាណយ៉ាងមានអានុភាព ដែលធ្វើខ្ញុំស្រក់ទឹកភ្នែក ។ ខ្ញុំបានដឹងនៅគ្រានោះភ្លាមថា ព្រះវរបិតាសួគ៌ត្រាស់ដឹងពីខ្ញុំ និងទុក្ខសោកដ៏ជ្រាលជ្រៅដែលខ្ញុំកំពុងមាន ។

ទំនុកតម្កើងនោះបានក្លាយជាភ្លេងជាតិមិនផ្លូវការសម្រាប់សាសនាចក្រ ប៉ុន្តែវាបានក្លាយជាភ្លេងជាតិផ្ទាល់ខ្លួនសម្រាប់ខ្ញុំផងដែរ ។

« មក » ទំនុកតម្កើងបានអញ្ជើញខ្ញុំ ។ « ថ្វីបើដំណើរនេះលំបាករបៀបណា ព្រះគុណនឹងជួយលើកទ្រ » ។

ដំណើររបស់ខ្ញុំ*គឺ*លំបាក ។ ប៉ុន្តែព្រះគុណ*ពិតជា*ហែហមខ្ញុំដូចដែលបានសន្យា ។



**សមាជិកពេញទំហឹង**

« មនុស្សម្នាក់ដែលកំពុងធ្វើតាមសេចក្ដីសញ្ញា និងបទដ្ឋាន និងការបង្រៀនទាំងឡាយរបស់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ—ថ្វីបើពួកគេអាចនឹងកំពុងជួបនឹងការទាក់ចិត្តនឹងភេទដូចគ្នាក្ដី—ពិតជាគ្មានមូលហេតុណាដែលពួកគេមិនអាចចូលរួមយ៉ាងពេញលេញ [ ឬ ] ជាសមាជិកពេញទំហឹងរបស់សាសនាចក្រ ហើយកាន់ការហៅបម្រើនានា ព្រមទាំងឡើងនិយាយ និងចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយបម្រើនៅទីនោះនោះទេ ។ ហើយគ្រប់ទាំងឱកាស និងពរជ័យផ្សេងៗទៀតទាំងអស់ដែលអាចបានមកពីភាពជាសមាជិកនៃសាសនាចក្រ នឹងមានដល់ពួកគេ » ។

**អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « LGBT People Who Live God's Laws Can Fully Participate in the Church » ( វីដេអូ ) .ChurchofJesusChrist.org/topics/gay ។**

ប៊ីស្សព ខេរិន ប៊ីដ និងក្រុមជំនុំគឺប្រពៃណាស់ ហើយមានការស្វាគមន៍ ។ ពួកគេបានទទួលខ្ញុំជាបងប្អូនប្រុសរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ ។

## ផ្សះផ្សាជាមួយព្រះ តាមរយៈព្រះគ្រីស្ទ ។

ពាក្យដែលថា « មក មក ពួកបរិសុទ្ធ » បានមានអត្ថន័យកាន់តែខ្លាំងចំពោះខ្ញុំ កាលដែលខ្ញុំបានទទួលអារម្មណ៍ថាព្រះវរបិតាសួគ៌កំពុងណែនាំខ្ញុំពីរបៀបដែលខ្ញុំត្រូវបន្តទៅមុខទៀត ។

*យើងនឹងរកឃើញកន្លែងដែលព្រះរៀបទុក*
*នៅទិសខាងលិចដ៏ឆ្ងាយ*
*គឺជាកន្លែងដែលគ្មានអ្នកណាបញ្ឈឺ ឬកំហែង*
*ពួកបរិសុទ្ធបានពរ ។*

ខ្ញុំបានទៅទិសខាងលិច ហើយបានទិញផ្ទះនៅក្នុងទីក្រុងហ្វេនចិនហៀលស៍ រដ្ឋអារីហ្សូណា ស.រ.អា. ជាកន្លែងដែលខ្ញុំបានជួបនឹងប៊ីស្សព ដើរ អូលសុន ។ ពេលដែលខ្ញុំស្នើសុំជួបនឹងគាត់ ហើយចាប់ដៃគាត់ ព្រះវិញ្ញាណបានបញ្ជាក់ប្រាប់ខ្ញុំថា បុរសនេះនឹងជួយខ្ញុំឲ្យត្រឡប់មកសកម្មពេញលេញវិញនៅក្នុងព្រះវិហារ ។

កាលដែលខ្ញុំបានចាប់ផ្ដើមជួបនឹងប៊ីស្សព ហើយចាប់ផ្ដើមការផ្សះផ្សាជាមួយព្រះវរបិតាសួគ៌វិញ នោះខ្ញុំបានឃើញអព្ភូតហេតុខាងវិញ្ញាណជាច្រើន ។ ខ្ញុំបាននិយាយដោយឥតលាក់លៀមជាមួយនឹងប៊ីស្សព ដែលធ្វើឲ្យគាត់មានអំណរគុណណាស់ ។ គាត់បាននិយាយថា អ្វីទាំងនោះជួយគាត់ឲ្យយល់កាន់តែច្បាស់ថា ស្ថានភាពខ្ញុំបាននៅត្រង់ណា ហើយស្ថានភាពខ្ញុំយ៉ាងណាដែរឥឡូវនេះទាក់ទងនឹងចំណងទាក់ទងរបស់ខ្ញុំជាមួយព្រះ ។ គាត់ក៏បានផ្ដល់ព័ត៌មានដល់ខ្ញុំផងដែរថា នេះជាលើកទីមួយហើយដែលគាត់បានមានឱកាសផ្ដល់ការងារបម្រើដល់មនុស្សម្នាក់ដែលមានការទាក់ចិត្តនឹងភេទដូចគ្នា ហើយគាត់បានសូមឲ្យខ្ញុំមានការអត់ធ្មត់ និងអត់ទោស ប្រសិនបើគាត់បាននិយាយ ឬធ្វើអ្វីមួយដែលធ្វើឲ្យខ្ញុំអាក់អន់ចិត្តនៅក្នុងដំណើរការនេះ ។

ខ្ញុំបានអរគុណគាត់ចំពោះភាពស្មោះត្រង់របស់គាត់ ហើយបាននិយាយថា « មែនហើយ នេះជាលើកទីមួយរបស់ខ្ញុំផងដែរ ។ យើងនឹងរៀនជាមួយគ្នា » ។

ការណ៍នោះបានចាប់ផ្ដើមដំណើរដ៏ស្រស់បំព្រងមួយ ព្រមទាំងមិត្តភាពផង !

មិនយូរប៉ុន្មានខ្ញុំបានមានផែនការសេកម្មភាពមួយអំពីរបៀបដើម្បីក្លាយជាសមាជិកម្ដងទៀត ។ ខ្ញុំបានទទួលការប្រឹក្សាដ៏ពោរពេញដោយសេចក្ដីស្រឡាញ់ និងការអធិស្ឋាន ដោយដួងចិត្តពេញដោយអំណរគុណ ហើយបានចាប់ផ្ដើមដំណើរការនោះ ។

## ការលួងលោមនៅក្នុងព្រះវិហារបរិសុទ្ធ

ក្រោយមក កាលដែលខ្ញុំបានធ្វើតាមការប្រឹក្សានោះ ហើយបានខិតខំខិតកាន់តែជិតព្រះគ្រីស្ទ នោះខ្ញុំបានទទួលការស្ដារឡើងវិញនូវបព្វជិតភាពរបស់ខ្ញុំ និងពរជ័យនៃព្រះវិហារបរិសុទ្ធ ព្រមទាំងបានទទួលការហៅបម្រើមួយឲ្យបម្រើនៅក្នុងកូរ៉ុមអែលឌើរទៀតផង ។ នៅក្នុងព្រះវិហារបរិសុទ្ធដ៏បរិសុទ្ធកាលដែលខ្ញុំប្រាស្រ័យទាក់ទងនឹងព្រះវរបិតាសួគ៌ នោះទ្រង់បានបង្ហាញខ្ញុំថាទ្រង់ស្រឡាញ់បុត្រាបុត្រីទ្រង់ខ្លាំងយ៉ាងណា ។ ខ្ញុំបានទទួលអារម្មណ៍លួងលោម និងបំណងប្រាថ្នាដ៏ជ្រាលជ្រៅមួយដើម្បីធ្វើឲ្យទ្រង់សព្វព្រះទ័យ ។

ជាច្រើនខែក្រោយមក ប៊ីស្សពថ្មីម្នាក់ត្រូវបានហៅ ដែលខ្ញុំក៏បានកសាងនូវមិត្តភាពដ៏ពោរពេញដោយក្ដីស្រឡាញ់ផងដែរ ។ ប៊ីស្សព លែរី វ៉ាដហ្វដ បានដឹងពីស្ថានភាពរបស់ខ្ញុំ ហើយបានមានអំណរគុណចំពោះការបម្រើរបស់ខ្ញុំនៅក្នុងកូរ៉ុមអែលឌើរ ដែលគាត់បាននិយាយថា ខ្ញុំបានបម្រើដោយ



រចនាប្រភាពដោយ ជីនណា ផាឡាស៊ីស

សេចក្តីស្រឡាញ់ និងការលះបង់ មិនត្រឹមតែដល់ក្រុមប៉ុណ្ណោះទេ តែថែមទាំង—ហើយកាន់តែសំខាន់ទៀតនោះ—គឺដល់ព្រះ ។ ពាក្យសម្តី និងការលើកទឹកចិត្តដ៏សប្បុរសរបស់គាត់ បានជួយខ្ញុំឲ្យទទួលអារម្មណ៍ថា ព្រះអម្ចាស់ និងពួកបរិសុទ្ធជាមិត្តរបស់ខ្ញុំ រីករាយនឹងការបម្រើរបស់ខ្ញុំ ។

ឥឡូវនេះខ្ញុំបម្រើដោយស្មោះត្រង់ជាស្មៀនវួដ ។

**ការយល់ថាខ្ញុំជានរណា**

ការទាក់ចិត្តនឹងភេទដូចគ្នា និងការធ្វើជាសមាជិកសកម្មក្នុងសាសនាចក្រគឺមិនតែងតែជាការងាយស្រួលនោះទេ ។ តែពេលដែលខ្ញុំដាក់សេចក្តីជំនឿ និងការទុកចិត្តទាំងអស់របស់ខ្ញុំទៅលើព្រះ នោះខ្ញុំអាចទទួលអារម្មណ៍ថាទ្រង់កំពុងពង្រឹងកម្លាំងខ្ញុំ ។ គ្មានការសង្ស័យទេ អ្នករិះគន់ពិតជានឹងនិយាយថា ខ្ញុំមិនពិតចំពោះខ្លួនឯង ឬថាខ្ញុំកំពុងធ្វើឲ្យសហគន៍ LGBT+ ខកចិត្ត ។

ខ្ញុំយល់ពីការតានតឹងចិត្តរបស់ពួកគេ ហើយវាច្បាស់ណាស់ថា ខ្ញុំពុំមានចម្លើយទាំងអស់ទេ ។ ខ្ញុំគ្រាន់តែអាចនិយាយចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំប៉ុណ្ណោះ ។ ហើយបទពិសោធន៍នោះបានបង្រៀនខ្ញុំការណ៍នេះ ៖ ខ្ញុំជាបុត្រារបស់ព្រះវរបិតាសួគ៌ ជាបុត្ររបស់ព្រះ ។ នោះជាស្លាកតែមួយគត់ដែលសំខាន់ចំពោះខ្ញុំ ។ ជាលទ្ធផល ខ្ញុំព្យាយាមមិនឲ្យស្លាករបស់ពិភពលោកដើម្បីកំណត់ពីខ្ញុំនោះទេ ។ ខ្ញុំព្រួយបារម្ភថា ការណ៍នោះនឹងកម្រិតពីសក្តានុពល និងការរីកចម្រើនអស់កល្បរបស់ខ្ញុំ

សាតាំងឆ្លាតវៃណាស់ ។ វាដឹងថា ដោយការដាក់ស្លាកឈ្មោះនានា វាអាចបំបែកយើងជាសហគមន៍មួយ និងជាសាសនាចក្រមួយ ។

ជាមួយនឹងទស្សនៈនោះនៅក្នុងគំនិត ជម្រើសដែលខ្ញុំជ្រើសរើសគឺមិនពឹងផ្អែកលើការទាក់ចិត្តនឹងភេទដូចគ្នារបស់ខ្ញុំនោះទេ ប៉ុន្តែលើរបៀបដើម្បីធ្វើជាសិស្សដ៏ពិតរបស់ព្រះគ្រីស្ទ *ដែលមាន*ការទាក់ចិត្តនឹងភេទដូចគ្នា ។ ដូចនីហ្វៃបាននិយាយ ៖

« ឱព្រះអម្ចាស់អើយ ទូលបង្គំបានទុកចិត្តទៅលើព្រះអង្គ ហើយទូលបង្គំនឹងទុកចិត្តទៅលើព្រះអង្គជារៀងដរាប ។ ទូលបង្គំនឹងមិនដាក់ទីទុកចិត្តរបស់ទូលបង្គំទៅលើដៃនៃមនុស្សឡើយ ។ . . .

« . . . ទូលបង្គំដឹងថា ព្រះទ្រង់នឹងប្រទានឲ្យអ្នកណា ដែលសូមដល់ទ្រង់ដោយសទ្ធា ។ មែនហើយ ព្រះរបស់ទូលបង្គំនឹងប្រទានឲ្យទូលបង្គំ បើសិនជាទូលបង្គំមិនសូមនូវអ្វីដែលទុច្ចរិត ហេតុដូច្នេះហើយ ទូលបង្គំនឹងបន្លឺសំឡេងឡើងដល់ព្រះអង្គ មែនហើយ ទូលបង្គំនឹងអំពាវនាវដល់ព្រះអង្គ ឱព្រះរបស់ទូលបង្គំ ដែលជាថ្មនៃសេចក្តីសុចរិតរបស់ទូលបង្គំអើយ ។ មើលចុះ សំឡេងរបស់ទូលបង្គំ នឹងអណ្តែតឡើងទៅដល់ព្រះអង្គជារៀងដរាប ដែលជាថ្ម ហើយជាព្រះដ៏គង់នៅអស់កល្បជានិច្ចរបស់ទូលបង្គំ ។ ( នីហ្វៃទី២ ៤:៣៤–៣៥ ) ។

**សេចក្តីស្រឡាញ់របស់ពួកបរិសុទ្ធ**

តាំងពីការត្រឡប់មកវិញរបស់ខ្ញុំ ខ្ញុំបានទទួលអារម្មណ៍នៃភាពជាដៃគូដ៏ពោរពេញដោយសេចក្តីស្រឡាញ់របស់ថ្នាក់ដឹកនាំ និងពួកបរិសុទ្ធរបស់ខ្ញុំ បូករួមទាំង LGBT+ សមាជិកដែលសកម្ម និងមិនសូវសកម្ម ។ ខ្ញុំបានរកឃើញកន្លែងដែលខ្ញុំអាចប្រឹងប្រែងលូតលាស់ ។ ខ្ញុំបានឃើញលក្ខណៈនៃព្រះគ្រីស្ទនៅក្នុងចំណោមពួកគេ ដែលខ្ញុំតែងតែងភ្ជាប់ជាមួយនឹងសេចក្តីជំនឿរបស់ខ្ញុំ ៖ សេចក្តីសប្បុរស ការអាណិតអាសូរ ការយោគយល់ និងលើសអ្វីៗទាំងអស់នោះគឺសេចក្តីស្រឡាញ់ ។

កាលដែលខ្ញុំបានមានការលំបាកនៅតាមផ្លូវជាមួយនឹងព្រះអង្គសង្គ្រោះរបស់ខ្ញុំ ខ្ញុំបានទទួលអារម្មណ៍នៃការលួងលោម និងភាពសុខសាន្ត កាលដែលខ្ញុំងាកទៅរកទ្រង់ ដោយដឹងថាខ្ញុំមិនមែនកំពុងដើរនៅលើផ្លូវនេះតែឯងឡើយ ។ ប៊ីស្សពជាច្រើនបាននៅក្បែរខ្ញុំ ។ សមាជិកក្នុងក្រុមរបស់ខ្ញុំ ។ បងប្អូនស្រីក្នុងវួដ ។ មានយុវជនម្នាក់នៅក្នុងវួដថែមទាំងសូមខ្ញុំឲ្យតែងតាំងគាត់ជាសង្ឃទៀតផង ។ ការអញ្ជើញដ៏សប្បុរសរបស់គាត់ធ្វើឲ្យខ្ញុំរំជួលចិត្តជាខ្លាំង ។ គាត់បានឃើញខ្ញុំថាជាបុរសម្នាក់ដែលកាន់បព្វជិតភាពរបស់ព្រះ ហើយជាមនុស្សម្នាក់ដែលអាចអនុវត្តបព្វជិតភាពនៅក្នុងការបម្រើដល់អ្នកដទៃទៀត ។

ឱកាសទាំងនោះដើម្បីបម្រើ និងថ្វាយបង្គំជាមួយពួកបរិសុទ្ធរបស់ខ្ញុំបានលើកស្ទួយខ្ញុំឡើង—ព្រមជាមួយនឹងពរជ័យជាច្រើនទៀតដែលខ្ញុំបានទទួលពីព្រះអម្ចាស់—បានជួយខ្ញុំឲ្យដកពិសោធន៍នូវសេចក្តីស្រឡាញ់ ការយោគយល់ និងការទទួលយកដែលខ្ញុំត្រូវការ ។

ព្រះអម្ចាស់បានមានបន្ទូលថា « ខ្ញុំមិនចោលអ្នករាល់គ្នាឲ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ » ( យ៉ូហាន ១៤:១៨ ) ។ ពាក្យទាំងនោះគឺពិត ។ ខ្ញុំត្រូវការការលួងលោម ហើយទ្រង់បានមកឯខ្ញុំ យ៉ាងបរិបូណ៌ជាងដែលខ្ញុំអាចស្រមៃឃើញទៅទៀត ។ ■



**ជម្រកនៃដំណឹងល្អ**

« ជម្រកនៃដំណឹងល្អគឺពិតជាធំគ្រប់គ្រាន់សម្រាប់មនុស្សគ្រប់គ្នាដែលមានបំណងធ្វើតាមព្រះអម្ចាស់ ។ ពេលណាដែលមនុស្សម្នាក់និយាយ ឬមានអារម្មណ៍ផ្ទុយពីនោះ ខ្ញុំគិតពី បប់ រើសធេច ហើយប្រាថ្នាថាពួកគេអាចជួបនឹងគាត់ ហើយបម្រើជាមួយគាត់ ។ បងប្រុសរើសធេចកំពុងអនុវត្តជាគំរូនៃអ្វីដែលដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអាចធ្វើ ពេលអនុវត្តវា ។ ក្នុងនាមជាប៊ីស្សព ខ្ញុំត្រូវបានលើកស្ទួយ និងលើកទឹកចិត្តដោយបុរសដ៏រាបទាបនេះជារៀងរាល់ថ្ងៃ » ។

**ប៊ីស្សព លែរី ក៉ាដហ្វដ វួដហ្វេនចិនហៀលស៍ ស្តេកស្កត់ស្តេលអារីហ្សូណាខាងជើង**

ប្រភពរូបថត GETTY IMAGES



## នៅក្នុងវគ្គនេះ:

**៤៦** មូលហេតុដែលព្រះវរបិតាមានព្រះទ័យឲ្យខ្ញុំទទួលការអប់រំ
ដោយ គ្លរីយ៉ា ខរនែលូ

**៥០** រឿងមួយអំពីអនាគតដែលខ្ញុំ*អាច*គ្រប់គ្រង
ដោយ ឡូរ៉ា ខេមផេន័រ

## មានតែឌីជីថលប៉ុណ្ណោះ

**អ្វីដែលត្រូវធ្វើដើម្បីទទួលបានបំណងប្រាថ្នាដ៏សុចរិតរបស់យើង**
ដោយ ម៉ាក ដេអូ ដេឡា ឃ្រូស

**របៀប មូលហេតុ ពេលណា និងកន្លែងណានៃការសន្សំប្រាក់**

**ភាពជាក់លាក់ ៥ យ៉ាងនៅក្នុងពិភពលោកដ៏មិនប្រាកដប្រជាមួយ**
ដោយ មេគ យសថ៍

ស្វែងរកអត្ថបទទាំងនេះ និងអ្វីៗបន្ថែមទៀត ៖
- នៅគេហទំព័រ **liahona.ChurchofJesusChrist.org**
- នៅក្នុង **យុវមជ្ឈិមវ័យប្រចាំសប្ដាហ៍** ( ខាងក្រោមវគ្គ « យុវមជ្ឈិមវ័យ » នៅក្នុងកម្មវិធី បណ្ណាល័យដំណឹងល្អ )

# ប្រឈមនឹងអនាគតដែលមិនច្បាស់លាស់ដោយសេចក្ដីជំនឿ

ខ្ញុំគឺជាអ្នកដាក់ផែនការ ។ ខ្ញុំចូលចិត្តដឹងពីអ្វីដែលត្រូវរំពឹងទុកជារៀងរាល់ថ្ងៃ ដើម្បីខ្ញុំអាចរៀបចំសម្រាប់វា ។ ប៉ុន្តែ **តើខ្ញុំអាចរៀបចំដោយរបៀបណាសម្រាប់ពេលអនាគត** ពេលដែលវានៅឆ្ងាយ ហើយមិនប្រាកដប្រជា ?

ជីវិតគឺធំល្វឹងល្វើយណាស់ ។ មានអ្វីៗជាច្រើននៅខាងមុខ ! មានអ្វីៗជាច្រើនដែលអាចកើតឡើង ! មានអ្វីៗជាច្រើនដែលខ្ញុំអាចធ្វើបាន !**ជួនកាលលទ្ធភាពមានច្រើនលើសលុប ។**

មានអ្វីៗជាច្រើនដែលខ្ញុំចង់បាន ៖ ស្វាមីមួយ ការងារល្អមួយ រស់នៅបរទេស ធ្វើជាម្ចាស់ឆ្មាមួយ សរសេរប្រលោមលោក រៀនភាសារុស្សី. . .ប៉ុន្តែខ្ញុំក៏ដឹងដែរថា បំណងប្រាថ្នា និងគោលដៅនានាផ្លាស់ប្ដូរ ។ អាទិភាពផ្លាស់ប្ដូរ ។

អាទិភាពមួយដែលត្រូវតែមិនដែលផ្លាស់ប្ដូរនោះគឺ **ការតាំងចិត្តរបស់យើងចំពោះព្រះ និងផែនការរបស់ទ្រង់ ។** ជាមួយនឹងចក្ខុវិស័យឃើញជាមុនរបស់ទ្រង់ **យើងអាចបត់បែនតម្រង់ទិសអនាគតដែល**ពោរពេញដោយសំណួរទាំងឡាយបាន ដោយសារទ្រង់នឹងជួយយើងរកឃើញចម្លើយមួយជំហានម្ដងៗ ។ យើងគ្រាន់តែត្រូវធ្វើការជ្រើសរើសដ៏ល្អបំផុតដែលយើងអាចធ្វើបានជាមួយនឹងជំហាននីមួយៗ ។

នៅក្នុងវគ្គនេះ យុវមជ្ឈិមវ័យចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ អំពីរបៀបដែលពួកគេដាក់ផែនការសម្រាប់អនាគតរបស់ពួកគេដោយមានជំនួយរបស់ព្រះវរបិតាសួគ៌ និង**របៀបដែលពួកគេឈានឆ្ពោះទៅមុខដោយសេចក្ដីជំនឿ** ពេលប្រឈមនឹងភាពមិនច្បាស់លាស់ជាច្រើន ។

ពេលនិយាយពីអនាគត មានសំណួរជាច្រើន ប៉ុន្តែនោះគ្រាន់តែមានន័យថា **មានសក្ដានុពលជាច្រើន ។** យើងក៏មានសក្ដានុពលដែរ—ជាសក្ដានុពលដើម្បីក្លាយដូចជាព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។

Meg

ហើយវាធ្វើឲ្យអនាគតរបស់យើងគឺរុងរឿង ។
មេគ យសថ៍

## ចែកចាយរឿងរបស់អ្នក

តើអ្នកមានបទពិសោធន៍មួយដើម្បីចែកចាយឬទេ ? ឬតើអ្នកចង់ឃើញអត្ថបទអ្វីខ្លះអំពីប្រធានបទជាក់លាក់នានា ? បើដូច្នេះ យើងចង់ឮពីអ្នក ! អ្នកអាចផ្ញើអត្ថបទ ឬមតិកែលម្អរបស់អ្នកតាមគេហទំព័រ **liahona.ChurchofJesusChrist.org** ។



# មូលហេតុដែលព្រះវរបិតាមានព្រះទ័យឲ្យខ្ញុំទទួលការអប់រំ

ដោយ គ្លរីយ៉ា ខរនៃលូ

មិនថាអ្វីជាបំណងប្រាថ្នាដ៏សុចរិតរបស់បងប្អូននោះទេ ព្រះវរបិតាសួគ៌នឹងប្រទានមធ្យោបាយមួយសម្រាប់បងប្អូនដើម្បីសម្រេចវាបាន ។

តាំងពីខ្ញុំនៅតូច ខ្ញុំតែងតែងចង់ធ្វើឲ្យព្រះវរបិតាសួគ៌របស់ខ្ញុំ និងគ្រួសារបច្ចុប្បន្ន និងអនាគតគ្រួសារខ្ញុំមានមោទនភាព ។ ខ្ញុំចង់ទទួលបានការអប់រំទាំងអស់ដែលខ្ញុំអាចទទួលបាន ដើម្បីអភិវឌ្ឍខ្លួនឯង និងជីវិតខ្ញុំ ។

នៅក្នុងប្រទេសរបស់ខ្ញុំគឺ ប្រទេសពេរូ ការអប់រំដ៏មានគុណភាពគឺថ្លៃណាស់ ហើយនៅតំបន់ខ្លះគឺមិនអាចរកបានតែម្ដង ។ គ្រួសារខ្ញុំក៏ពុំមានគ្រប់ធនធានទាំងអស់ដើម្បីគាំទ្រដល់ការអប់រំរបស់ខ្ញុំដែរ ។ ប៉ុន្តែឪពុកម្ដាយខ្ញុំបានបង្រៀនខ្ញុំថា ការខិតខំធ្វើការ ការឧស្សាហ៍ព្យាយាម និងការទូលសូមជំនួយពីព្រះវរបិតាសួគ៌ អាចជួយធ្វើឲ្យបំណងប្រាថ្នាសុចរិតរបស់យើងក្លាយជាការពិតបាន ។ ហើយខ្ញុំបានដាក់ផែនការដើម្បីខិតខំធ្វើការ ។

នៅក្នុងថ្នាក់បឋម និងវិទ្យាល័យ ខ្ញុំឧស្សាហ៍នៅក្នុងការសិក្សាដើម្បីអាចអភិវឌ្ឍខ្លួនឯងជារៀងរាល់ឆ្នាំ ។ បន្ទាប់ពីវិទ្យាល័យ ខ្ញុំត្រូវបានទទួលឲ្យចូលរៀនក្នុងសាកលវិទ្យាល័យលំដាប់ខ្ពស់របស់ប្រទេសពេរូ ហើយបានទទួលអាហារូបករណ៍ដ៏ល្អមួយ ។ ខណៈនៅទីនោះ ខ្ញុំបានធ្វើការជាមួយអង្គការមួយចំនួន រួមមានទាំងការចុះកម្មសិក្សាជាមួយនឹងអង្គការពិភពលោកមួយផងដែរ ហើយបានមានឱកាសដឹកនាំគម្រោងផ្សេងៗជាច្រើនប្រភេទ ។

អំឡុងកម្មសិក្សានោះ ខ្ញុំបានមានអារម្មណ៍ថា វានឹងជាឱកាសដ៏ល្អសម្រាប់ខ្ញុំដើម្បីទទួលការអប់រំជាភាសាអង់គ្លេស ។ ដូច្នេះខ្ញុំបានសម្រេចចិត្តផ្ទេរទៅសាកលវិទ្យាល័យព្រិកហាំយ៉ង់–អៃដាហូ ។ វាមានអារម្មណ៍គួរឲ្យភ័យខ្លាច ប៉ុន្តែខ្ញុំបានដឹងថា ព្រះវរបិតាសួគ៌នឹងជួយខ្ញុំឲ្យសម្រេចគោលដៅនេះ—ខ្ញុំគ្រាន់តែត្រូវទុកចិត្តលើទ្រង់ ហើយធ្វើផ្នែករបស់ខ្ញុំ ។

រូបថតដោយ GETTY IMAGES





ខ្ញុំគឺជានិស្សិតអន្តរជាតិដំបូងគេដែលបានទទួលបរិញ្ញាបត្រពី BYU-Pathway នៅទូទាំងពិភពលោក ។

## ការផ្លាស់ប្ដូរផែនការ

ខ្ញុំត្រៀមរួចរាល់ដើម្បីទៅប៊ី.វ៉ាយ.យូ–អៃដាហូ ប៉ុន្តែអំឡុងពេលដំណើរការនៃការដាក់ពាក្យស្នើសុំ ខ្ញុំបានទទួលអារម្មណ៍បំផុសមួយយ៉ាងខ្លាំងថា ខ្ញុំគួរតែបម្រើបេសកកម្មសិនមុននឹងផ្ទេរទៅទីនោះ ។ ដូច្នេះខ្ញុំបានធ្វើតាមព្រះរាជបំណងរបស់ព្រះវរបិតាសួគ៌ ហើយត្រូវបានហៅឲ្យបម្រើនៅក្នុងទីក្រុងទ្រូហៀយ៉ូ ប្រទេសពេរូ ។ ពេលខ្ញុំត្រឡប់មកផ្ទះវិញ ខ្ញុំបានដាក់ផែនការដើម្បីត្រឡប់ទៅសាកលវិទ្យាល័យនៅក្នុងប្រទេសពេរូវិញ ដោយសារខ្ញុំបានមានអារម្មណ៍ថា ខ្ញុំអាចទទួលបានសញ្ញាបត្រនៅទីនោះឆាប់រហ័ស ។ ទោះជាយ៉ាងណា ខ្ញុំបានរកឃើញថា អាហារូបករណ៍របស់ខ្ញុំនៅទីនោះត្រូវបានដកហូត ដោយសារតែខ្ញុំបានចាកចេញពីការសិក្សារបស់ខ្ញុំយូរជាងមួយឆ្នាំដើម្បីបម្រើបេសកកម្មរបស់ខ្ញុំ ។

ខ្ញុំមានចិត្តខ្វេចខ្វាំ ហើយវង្វេងវង្វាន់ ។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីឡើយ ។ ខ្ញុំមិនដឹងថា ហេតុអ្វីខ្ញុំត្រូវបានបំផុសឲ្យបម្រើបេសកកម្ម ប្រសិនបើវាមានន័យថាត្រូវបាត់បង់ឱកាសដើម្បីទទួលបានសញ្ញាបត្រមហាវិទ្យាល័យមួយនោះ ។

ប៉ុន្តែថ្ងៃមួយ ខ្ញុំបានចងចាំប្រធានបេសកកម្មរបស់ខ្ញុំបានប្រាប់ខ្ញុំអំពី BYU-Pathway Worldwide ។ គាត់បានអញ្ជើញយើងឲ្យអភិវឌ្ឍភាសាអង់គ្លេសរបស់យើង ហើយដើម្បីឈោងចាប់យកឱកាសនេះ ពេលយើងត្រឡប់ទៅផ្ទះវិញ—ហើយខ្ញុំបានធ្វើវា !

## ដំណើររបស់ខ្ញុំជាមួយ BYU-Pathway Worldwide

ខ្ញុំបានដឹងថា ការដែលប្រធានបេសកកម្មរបស់ខ្ញុំប្រាប់ខ្ញុំអំពី BYU-Pathway មិនមែនជាការចៃដន្យនោះទេ ។ ពេលខ្ញុំបានចាប់ផ្ដើមកម្មវិធី Pathway វាតម្រូវឲ្យខ្ញុំធ្វើដំណើរជិតបីម៉ោងរៀងរាល់សប្ដាហ៍ដើម្បីជួបជាមួយនឹងក្រុមរបស់ខ្ញុំ ។ ខ្ញុំបានលះបង់ច្រើនណាស់ ប៉ុន្តែខ្ញុំបានដឹងថាការទទួលបានការអប់រំគឺសំខាន់ចំពោះខ្ញុំផង និងចំពោះព្រះផង ។ ហើយការលះបង់ទាំងនោះបាននាំមកនូវពរជ័យទាំងឡាយ ។

BYU-Pathway Worldwide គឺជាទ្វារនៃឱកាសដែលខ្ញុំបានស្វែងរក ។ វាបានផ្ដល់ឲ្យខ្ញុំនូវការអប់រំក្នុងតម្លៃសមរម្យ អនុញ្ញាតឲ្យខ្ញុំមានពេលដើម្បីមានការងារមួយ ហើយបានជួយខ្ញុំទទួលបានការអប់រំជាភាសាអង់គ្លេស ។ ហើយតាមរយៈវា ខ្ញុំបានរកឃើញមិត្តភក្ដិដ៏ល្អៗដែលបានលើកទឹកចិត្តខ្ញុំឲ្យក្លាហាន ហើយបន្តខិតខំឆ្ពោះទៅកាន់គោលដៅទាំងឡាយរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍កាន់តែរឹងមាំខាងវិញ្ញាណ ហើយបានក្លាយជាសិស្សដ៏កាន់តែប្រសើររបស់ព្រះយេស៊ូវគ្រីស្ទ ។

នៅទីបំផុត ខ្ញុំជាសិស្សអន្តរជាតិដំបូងគេដែលបានទទួលសញ្ញាបត្របរិញ្ញាបត្រតាមរយៈ BYU-Pathway Worldwide ។ ការអប់រំបានបើកឱកាសអស្ចារ្យនានាដល់ខ្ញុំ ។ ឥឡូវនេះខ្ញុំជាអ្នកជំនាញផ្នែកសុខុមាលភាព និងខ្លួនទីពឹងខ្លួនសម្រាប់តំបន់ពាយព្យនៃអាមេរិកខាងត្បូងរបស់សាសនាចក្រ ហើយខ្ញុំក៏ជាអ្នកផ្សព្វផ្សាយសាសនាស្ម័គ្រចិត្តសម្រាប់ BYU-Pathway នៅក្នុងប្រទេសពេរូផងដែរ ។ ខ្ញុំបានឃើញពន្លឺជាច្រើននៅក្នុងនិស្សិតម្នាក់ៗ ហើយខ្ញុំលើកទឹកចិត្តពួកគេឲ្យឆ្ពោះទៅមុខ គឺដូចជាខ្ញុំត្រូវបានលើកទឹកចិត្តដោយមិត្តភក្ដិរបស់ខ្ញុំពេលខ្ញុំនៅរៀនដែរ ។

តាមរយៈដំណើរនេះ ខ្ញុំបានដឹងថា ព្រះវរបិតាសួគ៌បានគង់នៅជាមួយខ្ញុំគ្រប់ជំហានទាំងអស់នៅតាមផ្លូវ ។

## ព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យយើងជោគជ័យ

ដំណើររបស់ខ្ញុំបានពង្រឹងទីបន្ទាល់របស់ខ្ញុំអំពីការអប់រំ ។ ហើយខ្ញុំនៅតែដាក់ផែនការដើម្បីបន្តរីកចម្រើន និងរៀនឲ្យបានច្រើនតាមដែលអាចធ្វើទៅបានរៀងរាល់ថ្ងៃ ។ យើងនៅលើផែនដីនេះដើម្បីរីកចម្រើន ដើម្បីទទួលការសាកល្បងដើម្បីលូតលាស់ ដើម្បីបង្ហាញថាយើងគោរពប្រតិបត្តិ និងដើម្បីពឹងផ្អែកលើព្រះអង្គសង្គ្រោះដើម្បីក្លាយជាសក្តិសមដើម្បីត្រឡប់ទៅព្រះវរបិតាសួគ៌របស់យើងវិញ ។ ចំពោះព្រះ « អស់ទាំងរបស់របរគ្រប់យ៉ាង គឺជាវិញ្ញាណ » ( សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ២៩:៣៤ ) ។ បទពិសោធន៍ទាំងអស់ដែលយើងមាន និងចំណេះដឹងដែលយើងទទួលបាននៅលើផែនដីនេះនឹងជួយយើងឲ្យកាន់តែដូចព្រះអង្គសង្គ្រោះរបស់យើង ហើយនឹងរៀបចំយើងឲ្យធ្វើការសម្រេចចិត្តកាន់តែល្អដើម្បីបម្រើពិភពលោកនេះកាន់តែប្រសើរ ហើយដើម្បីធ្វើជាឧបករណ៍កាន់តែល្អនៅក្នុងព្រះហស្តទ្រង់ ។

ការអប់រំផ្តល់មធ្យោបាយមួយដើម្បីទទួលបានចំណេះដឹង ហើយបន្ទាប់មកធ្វើ ដើម្បីឈរសម្រាប់សេចក្តីពិត និងសេចក្តីត្រឹមត្រូវ ដើម្បីមានជីវិតមួយដែលព្រះវរបិតាសួគ៌របស់យើងមានព្រះទ័យចង់ឲ្យយើងមាន—ជាជីវិតមួយពេញដោយអំណរ ។

ខ្ញុំដឹងថា ព្រះវរបិតាសួគ៌របស់យើងប្រទានពរដល់ការប្រឹងប្រែងរបស់យើង ជាពិសេសពេលបំណងប្រាថ្នានៃដួងចិត្តយើងគឺដើម្បីរីកចម្រើន ហើយដើម្បីបម្រើទ្រង់ និងបុត្រាបុត្រីរបស់ទ្រង់ ។ ខ្ញុំដឹងថា ពេលទ្រង់ប្រទានការណែនាំដល់បុត្រាបុត្រីទ្រង់ « នឹងរៀបចំផ្លូវដើម្បីឲ្យគេអាចសម្រេចនូវអ្វីៗ ដែលទ្រង់បានបញ្ជាដល់ពួកគេទុកជាមុនសិន » ( នីហ្វៃទី១ ៣:៧ ) ។ ទ្រង់សព្វព្រះទ័យឲ្យយើងមានជោគជ័យ ។

យើងម្នាក់ៗគួរតែទាញយកប្រយោជន៍ពីឱកាសនីមួយៗសម្រាប់ទទួលបានការអប់រំ និងការលូតលាស់ ដែលព្រះអម្ចាស់ដាក់នៅតាមផ្លូវរបស់យើង មិនថាវាតាមរយៈ BYU-Pathway ឬឱកាសការអប់រំផ្សេងៗទៀតណាក៏ដោយ ។ ទ្រង់ស្រឡាញ់យើង ហើយនឹងណែនាំយើងជានិច្ច ។ ទ្រង់មានព្រះទ័យចង់ឲ្យយើងរៀនអ្វីទាំងអស់ដែលយើងអាចរៀននៅលើផែនដីនេះ ។ ហើយខ្ញុំដឹងថា យើងអាចដកពិសោធន៍នូវអព្ភូតហេតុកាន់តែធំធេង កាលដែលយើងធ្វើការដោយអំណរ និងដោយឧស្សាហ៍ ហើយទុកចិត្តលើការណែនាំរបស់ទ្រង់ ។ ខ្ញុំដឹងថា ខ្ញុំបានធ្វើដូច្នោះ ។ ■



*__គ្លរីយ៉ា ខរនែលូ__ មកពីទីក្រុងលីម៉ា ប្រទេសពេរូ គាត់ជក់ចិត្តយ៉ាងខ្លាំងទៅនឹងការធ្វើឲ្យអ្វីដែលមិនអាចទៅរួចកើតឡើងបាន ការបម្រើអ្នកដទៃ និងអភិវឌ្ឍជីវិត ការបង្រៀន ហើយតែងតែរៀនឲ្យបានច្រើនបំផុតតាមដែលគាត់អាចធ្វើបាន ជាពិសេសអំពីវប្បធម៌ផ្សេងៗ ។*

**ដើម្បីរកមើលបន្ថែមទៀតអំពី BYU-Pathway Worldwide សូមចូលទៅកាន់គេហទំព័រ byupathway.org ។**



### ការអប់រំសម្រាប់អនាគតដ៏ល្អប្រសើរមួយ

*យុវមជ្ឈិមវ័យចែកចាយពីរបៀបដែលការទទួលបានការអប់រំជាគន្លឹះដើម្បីទទួលបានអារម្មណ៍នៃក្តីសង្ឃឹមកាន់តែខ្លាំងអំពីអនាគត ៖*

« ខ្ញុំបានកើត និងធំឡើងនៅក្នុងប្រទេសហុងឌូរ៉ាស—ជាប្រទេសមួយដែលពោរពេញដោយឱកាស ប៉ុន្តែប្រកបដោយការប្រកួតប្រជែងនៅក្នុងជីវិតរស់នៅ ។ ខ្ញុំបានធំឡើងដោយស្តាប់ដល់រឿងរ៉ាវទាំងឡាយអំពីបុព្វការីជនរបស់ខ្ញុំតែងតែស្វែងរកឱកាសនានាដើម្បីជួយធ្វើឲ្យជំនាន់បន្ទាប់ទៀតបានប្រសើរឡើង ។

« សូមអរគុណដល់ការលះបង់របស់ឪពុកម្តាយខ្ញុំ បងប្រុសខ្ញុំ និងខ្ញុំទទួលបានការអប់រំដ៏ល្អបំផុតដែលអាចរកបាន ។ ខ្ញុំបានរៀនថា ការអប់រំគឺមិនមានដែនកំណត់ត្រឹមសញ្ញាបត្របរិញ្ញាបត្រនោះទេ ។ ការអប់រំត្រូវបានតភ្ជាប់ទៅនឹងស្ថានសួគ៌ ។

« បើយើងប្រុងប្រៀបទុកជាស្រេច នោះយើងនឹងមិនត្រូវខ្លាចឡើយ ។ ការអប់រំជាបទបញ្ញត្តិមួយពីព្រះវរបិតាសួគ៌ ហើយទ្រង់បានប្រទានដល់យើងនូវការសន្យាថា ដរាបណាយើងកាន់តាមបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះយើងនឹងបានចម្រើនឡើងនៅលើដែនដី ( សូមមើល នីហ្វៃទី២ ១:២០ ) ។ ការអប់រំបានជួយខ្ញុំឲ្យបង្កើត លូតលាស់ ហើយប្រុងប្រៀបជាស្រេចដើម្បីភ្ជាប់តំណរឹងមាំរបស់ជំនាន់របស់ខ្ញុំ ហើយវាអនុញ្ញាតឲ្យខ្ញុំជួយអ្នកដទៃទៀតធ្វើដូចគ្នាដែរ » ។

**—សារ៉ា អិម បាឡូវ ទីក្រុងថេហ្គូស៊ីហ្គាលផា ប្រទេសហុងឌូរ៉ាស**

« ការអប់រំបានជួយខ្ញុំឲ្យដឹង ហើយយល់កាន់តែច្បាស់ពីតួនាទី និងទីតាំងរបស់ខ្ញុំនៅក្នុងគ្រួសារមនុស្សលោកនេះ ហើយការណ៍នេះនាំមកនូវអំណរដ៏ច្រើនដល់ខ្ញុំ » ។

**—ខេរីអាតា យើរីន ទីក្រុងខេនធើរបើរី ប្រទេសនូវហ្សេឡែន**

« ការអប់រំធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ជាមួយនឹងការងារក្នុងពេលអនាគតរបស់ខ្ញុំ ខ្ញុំអាចជាពន្លឺមួយនៅក្នុងពិភពលោកនេះ ហើយនៅក្នុងការផ្សព្វផ្សាយដំណឹងល្អ » ។

**—ខ្លៅឌា អាស៊ូណា ថូម៉ាស ទីក្រុងអាន់តូហ្វាហ្គាស្តា ប្រទេសឈីលី**

# រឿងមួយអំពីអនាគតដែលខ្ញុំអាចគ្រប់គ្រង

ដោយ ឡូរ៉ា ខេមផេនើរ

សំឡេងដ៏តូចនោះនៅក្នុងក្បាលរបស់ខ្ញុំ គឺពិបាកនឹងមិនអើពើណាស់ ។ ឥឡូវនេះខ្ញុំអាយុ ២៨ ឆ្នាំហើយ នៅតែនៅលីវ ហើយមិនប្រាកដពីអ្វីដែលខ្ញុំចង់ធ្វើនៅក្នុងវិជ្ជាជីវៈ សូម្បីតែខ្ញុំមានការងារដ៏ល្អជាគិលានុបដ្ឋាយិកាខាងសម្ភពក៏ដោយ ។ ខ្ញុំបានមានអារម្មណ៍ថា គ្រប់ចំណុចនៃជីវិតរបស់ខ្ញុំពុំដំណើរការទេ ។ ខ្ញុំមានការសង្ស័យពីជម្រើសជីវិត ហើយមិនបានដឹងថាត្រូវជ្រើស យកផ្លូវណាទេ ។ ខ្ញុំមានអារម្មណ៍វង្វេងអស់ហើយ ។

ថ្ងៃមួយពេលខ្ញុំកំពុងមានអារម្មណ៍ធ្លាក់ចុះជាខ្លាំង មិត្តម្នាក់ដែលខ្ញុំមិនបាននិយាយជាមួយអស់មួយរយៈ បានទូរសព្ទមកខ្ញុំ ។ ពេលគាត់បានសួរខ្ញុំថាតើខ្ញុំមានសុខទុក្ខយ៉ាងណាដែរ ខ្ញុំបានពន្យល់ពីអារម្មណ៍ទាំងអស់នោះ ដែលខ្ញុំកំពុងជួប ។ គាត់បានស្ដាប់ បន្ទាប់មកបាននិយាយថា « ចុះតើឯងមានសុខទុក្ខយ៉ាងម៉េចដែរខាងវិញ្ញាណ ? »

ខ្ញុំបានឆ្លើយតបដោយស្វ័យប្រវត្តថា « អូ មែនហើយ វាឥតខ្ចោះ » ។ « ខ្ញុំមិនដែលមានអារម្មណ៍ជិតព្រះជាងពេលនេះទេនៅក្នុងជីវិតខ្ញុំ » ។

គាត់បានឆ្លើយតបថា « បើអញ្ចឹង ឯងមិនចាំបាច់ព្រួយពីអ្វីទៀតទេ » ។

## ទំនុកចិត្តលើផែនការដ៏ល្អឥតខ្ចោះរបស់ព្រះ

តាំងពីការសន្ទនានោះ ខ្ញុំបានយល់ដឹងរឿងពីរយ៉ាង ។ ទីមួយ ខ្ញុំបានដឹងថាខ្ញុំមានអំណរគុណដែលមានទីបន្ទាល់ដ៏រឹងមាំមួយអំពីដំណឹងល្អដែលបានស្តារឡើងវិញ ហើយអាចរស់នៅតាមបទបញ្ញត្តិ និងមានអារម្មណ៍ភ្ជាប់ទៅនឹងស្ថានសួគ៌ ។

ការមានភាពខ្លួនទីពឹងខ្លួនខាងវិញ្ញាណគឺសំខាន់ណាស់ចំពោះខ្ញុំ ហើយខ្ញុំនៅតែរៀនសូត្រពីរបៀបដើម្បីបើកស្ថានសួគ៌នៅក្នុងជីវិតរបស់ខ្ញុំ ។ ការអធិស្ឋាន និងការសិក្សាព្រះគម្ពីរជារៀងរាល់ព្រឹក ជាកិច្ចការសាមញ្ញពីរយ៉ាងដែលខ្ញុំមានអារម្មណ៍ថាបានធ្វើឲ្យមានភាពខុសគ្នាយ៉ាងធំបំផុតនៅក្នុងសមត្ថភាពរបស់ខ្ញុំដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន ។ ខ្ញុំក៏មានអារម្មណ៍ជិតស្និទ្ធនឹងស្ថានសួគ៌កាន់តែខ្លាំង ពេលខ្ញុំខិតខំដើម្បីមានសេចក្ដីសប្បុរស រស់នៅជីវិតមួយដែលមានសុខភាព ដើម្បីឲ្យ



រូបភាពពី GETTY IMAGES

ព្រះវិញ្ញាណអាចជាដៃគូរបស់ខ្ញុំជានិច្ច ដើម្បីគោរពតាមបទបញ្ញត្តិ និង ដើម្បីប្រែចិត្តដោយស្មោះសរ ។

ទីពីរ ខ្ញុំបានដឹងថា ការឆ្លើយតបរបស់ខ្ញុំទៅសំណួរមិត្តភក្តិរបស់ខ្ញុំ ពុំត្រឹមត្រូវទាំងស្រុងទេ—ខ្ញុំបានគិតថា ខ្ញុំកំពុងតែ « ឥតខ្ចោះ » ខាងវិញ្ញាណ ប៉ុន្តែខ្ញុំត្រូវការមានសេចក្តីជំនឿបន្ថែមទៀត ឈប់ព្រួយចិត្តច្រើនពេក ហើយទុកចិត្តលើព្រះឲ្យទ្រង់ដោះស្រាយនូវអ្វីដែលខ្ញុំពុំអាចគ្រប់គ្រងបាន ។

ទោះបីជាពេលដែលចំណុចខ្លះនៅក្នុងជីវិតរបស់ខ្ញុំពុំដំណើរការល្អដូចដែលខ្ញុំចង់បានក្តី ខ្ញុំដឹងថា អ្វីដែលសំខាន់បំផុតគឺការធ្វើអ្វីៗដោយសេចក្តីជំនឿ ហើយបង្ហាញព្រះថា ខ្ញុំប្រើប្រាស់សិទ្ធិជ្រើសរើសរបស់ខ្ញុំដើម្បីធ្វើការជ្រើសរើសល្អ ។ ខ្ញុំបានរៀនថា ពេលជីវិតពុំដំណើរការទៅតាមអ្វីដែលខ្ញុំរំពឹងចង់បាន គឺវាដើម្បីខ្ញុំអាចរៀន ហើយរីកចម្រើននៅក្នុងរបៀបទាំងឡាយដែលខ្ញុំមិនអាចធ្វើបានតាមរបៀបផ្សេងទៀត ។

ខ្ញុំមិនដែលស្រមៃទេថា ពេលខ្ញុំអាយុ ២៩ ឆ្នាំ ខ្ញុំនឹងឃើញថាខ្លួនឯងមានការសង្ស័យអំពីអាជីព និងដំណាក់កាលបន្ទាប់ទៀតនៃជីវិតខ្ញុំនោះទេ ។ ទោះជាមានអ្វីៗដែលខ្ញុំមិនដឹងទាំងអស់នេះក្តី ខ្ញុំមានទំនុកចិត្តទាំងស្រុងថា ព្រះមានផែនការឥតខ្ចោះមួយសម្រាប់ខ្ញុំ ។ ទ្រង់ត្រាសដឹងយ៉ាងប្រាកដពីអ្វីដែលកំពុងកើតឡើង និងអ្វីដែលខ្ញុំត្រូវការ ហើយទ្រង់នឹងតែងតែថែទាំខ្ញុំ ( សូមមើល ម៉ាថាយ ៦:២៨–៣៤ ) ។ ដូចជាអែលឌើរ អិល ធូដ ប៊ូដច៍ នៃពួកចិតសិបបានបង្រៀនថា « ទោះជាវាពិបាកយល់ក្តី ជាពិសេសនៅគ្រាក្នុងជីវិតរបស់យើងពេលដែលខ្យល់បក់បោកមកខ្លាំង ហើយសមុទ្រមានភាពខ្នួលខ្មាញ់ នោះយើងអាចមានការលួងលោមចិត្តដោយដឹងថា ព្រះតែងតែបក់យើងនៅក្នុងសេចក្តីល្អជានិរន្តរ៍របស់ទ្រង់ឆ្ពោះទៅរកផ្ទះជានិច្ច » ( « Consistent and Resilient Trust » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៩ ទំព័រ ៤៨ ) ។

## ទុកចិត្តកាន់តែច្រើន ព្រួយចិត្តកាន់តែតិច

ថ្ងៃខ្លះជីវិតហាក់ដូចជាពិបាកណាស់ ប៉ុន្តែពេលខ្ញុំគិតអំពីវា ខ្ញុំដឹងថាខ្ញុំមិនបាច់ព្រួយទេ ។ បន្តិចម្តងៗ ខ្ញុំបានដឹងថា ខ្ញុំត្រូវទុកចិត្តលើព្រះបន្តិចថែមទៀត ហើយព្រួយចិត្តកាន់តែតិចជាងអំពីអ្វីៗដែលខ្ញុំមិនអាចគ្រប់គ្រងបាន ។ រឿងមួយដែលខ្ញុំអាចគ្រប់គ្រងបានអំពីអនាគតគឺការទុកចិត្តលើព្រះ ហើយខិតខំលើការខិតឲ្យកាន់តែជិតទ្រង់ជារៀងរាល់ថ្ងៃ ។

ពេលខ្ញុំមានអារម្មណ៍វង្វេង នោះវាតែងតែមានពន្លឺគ្រប់គ្រាន់សម្រាប់ខ្ញុំ ដើម្បីឈានមួយជំហានទៅក្នុងអ្វីដែលមិនដឹង ហើយឆ្ពោះទៅមុខទៀត ។ ហើយដរាបណាខ្ញុំអនុវត្តសេចក្តីជំនឿ ហើយរក្សាសេចក្តីសញ្ញារបស់ខ្ញុំ ដរាបណាខ្ញុំចងចាំពីអត្តសញ្ញាណដ៏ពិតរបស់ខ្ញុំក្នុងនាមជាបុត្រីនៃព្រះបិតាព្រះមាតាសួគ៌ ហើយព្យាយាមម្តងហើយម្តងទៀត នោះអ្វីៗនឹងកើតឡើង នៅពេល និងតាមរបៀបដែលវាត្រូវកើត នោះហើយជាអ្វីដែលសំខាន់ ។ ■



***ឡូរ៉ា ខេមផេន័រ*** *បានធំឡើងនៅក្នុងភាគខាងត្បូងនៃប្រទេសបារាំងនៅក្នុងគ្រួសារអេស្ប៉ាញ ។ នាងធ្វើការជាធ្មប ហើយតែងតែស្វែងរកដំណើរផ្សងព្រេងថ្មីៗ ។ នាងចូលចិត្តនៅជាមួយមនុស្សម្នា ហើយចាប់អារម្មណ៍ជាខ្លាំងទៅលើវប្បធម៌ផ្សេងៗ ។*



*« នៅគ្រាក្នុងជីវិតរបស់យើងពេលដែលខ្យល់មកខ្លាំង ហើយសមុទ្រមានភាពខ្នួលខ្មាញ់ . . . យើងអាចមានការលួងលោមចិត្តដោយដឹងថា ព្រះតែងតែបក់យើងនៅក្នុងសេចក្តីល្អជានិរន្តរ៍របស់ទ្រង់ឆ្ពោះទៅរកផ្ទះជានិច្ច » ។*

—អែលឌើរ អិល ធូដ ប៊ូដច៍ នៃពួកចិតសិប





# យុវវ័យ

# ខ្ញុំចូលចិត្តធ្វើម្ហូបជាងអ្វីៗទាំងអស់ ។

ខ្ញុំធ្វើនំផេសស្ត្រី នំខាប់ខេក នំយុកឃីតូចៗ ម្ហូបសាច់ និងបាយ—តាមពិតទៅ គឺធ្វើគ្រប់យ៉ាង ! ខ្ញុំក៏ចូលចិត្តបង្រៀនផងដែរ ។ ខ្ញុំចូលចិត្តពេលគេអញ្ជើញខ្ញុំឲ្យបង្រៀនដល់ថ្នាក់យុវនារី ។

ខ្ញុំទៅសន្និសីទ ដ.ក.យ. ដោយសារខ្ញុំមានសំណួរមួយដែលខ្ញុំចង់បានចម្លើយ ។ ខ្ញុំមានអាហារូបករណ៍មួយដើម្បីទៅមហាវិទ្យាល័យ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែទៅបម្រើបេសកកម្ម ។ ប្រសិនបើខ្ញុំទៅ ខ្ញុំនឹងបាត់បង់អាហារូបករណ៍របស់ខ្ញុំ ។ ប៉ុន្តែបើខ្ញុំនៅ ហើយក្លាយជាគ្រូបង្រៀនម្នាក់ នោះខ្ញុំអាចធ្វើការ ហើយបង់ថ្លៃសាលាក្នុងពេលតែមួយ ។ អំឡុងសន្និសីទ ដ.ក.យ. បងស្រីម្នាក់បាននិយាយអំពីពរជ័យលោកអយ្យកោរបស់គាត់ ។ ខ្ញុំរៀបចំនឹងទទួលពរជ័យលោកអយ្យកោរបស់ខ្ញុំឥឡូវនេះ ហើយខ្ញុំសង្ឃឹមថា ពេលខ្ញុំទទួលវា ខ្ញុំនឹងដឹងកាន់តែច្បាស់ថាព្រះវរបិតាសួគ៌មានផែនការអ្វីសម្រាប់ខ្ញុំ ។ ខ្ញុំចូលចិត្តកម្មវិធីយុវវ័យ និង ដ.ក.យ. ណាស់ ដោយសារវាពង្រឹងដល់យុវវ័យ ។ ដោយសារសេចក្ដីពិតនោះគឺថា យើងទាំងអស់គ្នាត្រូវការភាពសុខសាន្ត ។

ក្រោយពីខ្ញុំបានទទួលបុណ្យជ្រមុជទឹក ខ្ញុំបានឈប់ទៅព្រះវិហារមួយរយៈ រួចហើយត្រឡប់ទៅវិញបានបន្តិច ហើយឈប់ទៅវិញទៀត ។ ប៉ុន្តែសមាជិកវួដបានមកសួរសុខទុក្ខខ្ញុំ ហើយបានអញ្ជើញខ្ញុំឲ្យត្រឡប់មកវិញ ។ ពួកគេបានប្រាប់ខ្ញុំថា សាសនាចក្រ និងសមាជិកនឹក ហើយត្រូវការខ្ញុំ ។ ខ្ញុំបានសម្រេចចិត្តដើម្បីត្រឡប់មកវិញ ហើយបានសកម្មតាំងពីនោះមក ។ ខ្ញុំបានឃើញថា ខ្ញុំត្រូវការសាសនាចក្រខ្លាំងណាស់ ។ ខ្ញុំអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ហើយមានអារម្មណ៍ល្អ ហើយខ្ញុំអាចទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ។ ដូច្នេះខ្ញុំបាននៅទីនេះ »

**អាឌ្រីអាណា ធី** ( ខាងឆ្វេងឆ្ងាយ ) អាយុ ១៧ ឆ្នាំ សាធារណរដ្ឋដូមីនីក

រូបថតដោយ លែល សេនធ៊ូល

នៅក្នុងវគ្គនេះ





៥៤ គ្រួសារចាស់ដ៏ថ្មីស្រឡាងរបស់ខ្ញុំ
ដោយ លេអូណាដូ ខនស៊ីខាអូ

៥៦ ការជ្រើសរើសផ្លូវតូច និងចង្អៀតជាជាងផ្លូវធំទូលាយ
ដោយអែលឌើរ តាខាស៊្សី វ៉ាដា

៦០ មេរៀនដែលប្រើសម្ភារសម្រាប់រាត្រីក្រុមគ្រួសារ : ការប្រើពេលវេលារបស់អ្នកឲ្យបានល្អ
ដោយ ណាតាស្យា អាន់ឌើរសិន

៦២ ទីកន្លែងរបស់យើង

៦៤ ពាក្យចុងក្រោយ : ទីបន្ទាល់ និង ការប្រែចិត្តជឿ
ដោយអែលឌើរ ដេវីឌ អេ បែដណា

៦៥ មនុស្សក្នុងព្រះគម្ពីរមរមន : អាមូលេក និង អាលម៉ា

# គ្រួសារចាស់ដ៏ថ្មីស្រទាប់របស់ខ្ញុំ

*ប្រសិនបើអ្នកអនុញ្ញាត នោះគ្មានអ្វីដែលដំណឹងល្អពុំអាចផ្លាស់ប្ដូរនោះទេ ។*

**ដោយ លេអូណាដូ ខនស៊ីខាអូ**

ពួកអ្នកផ្សព្វផ្សាយសាសនាកាន់រូបថតមួយ ។ ពួកគេបានសួរថា « តើប្អូនមើលឃើញអ្វី ? »

ខ្ញុំបានឆ្លើយថា « គ្រួសាររីករាយមួយ » ។

« តើគ្រួសារទាំងអស់សុទ្ធតែរីករាយឬ ? »

ខ្ញុំគ្រវីក្បាលខ្ញុំ ។ ខ្ញុំបានពន្យល់ថា « អ្នកឃើញគ្រួសារ*របស់ខ្ញុំ*ហើយ » ។

ខ្ញុំមានអាយុ ១៦ ឆ្នាំ រស់នៅប្រទេសប្រេស៊ីល ជាកន្លែងដែលខ្ញុំបានរស់នៅតាំងពីខ្ញុំកើតមក ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំអស់ជាច្រើនសប្ដាហ៍ ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងគ្រួសារខ្ញុំចង់ស្ដាប់ទេ ។ អំឡុងពេលនោះ ពួកអ្នកផ្សព្វផ្សាយសាសនាបានឃើញគ្រួសារខ្ញុំឈ្លោះប្រកែកគ្នាជាញឹកញាប់ ។ គ្រួសារខ្ញុំ និងគ្រួសារដែលញញឹមពព្រាយនៅក្នុងរូបថតនោះពុំមានអ្វីដែលដូចគ្នានោះទេ ។

អែលឌើរម្នាក់បាននិយាយថា « មែនហើយ ប្រហែលជាគ្រួសារបច្ចុប្បន្នរបស់ប្អូនមិនមែនដូចនេះទេ ។ ប៉ុន្តែប្អូនអាចកសាងអនាគតគ្រួសាររបស់ប្អូនឲ្យខុសពីនេះ » ។

ពេលយើងបានបញ្ចប់ការជួបនោះ ពួកគេបានសុំខ្ញុំម្ដងទៀតឲ្យអធិស្ឋានអំពីអ្វីដែលយើងបានរៀន ។ ដូចរាល់ដងដែរ ខ្ញុំមិនបានសន្យាដើម្បីធ្វើដូច្នោះឡើយ ។ ខ្ញុំរីករាយនឹងអារម្មណ៍ដែលខ្ញុំបានមានពេលពួកអ្នកផ្សព្វផ្សាយសាសនាបានមកជួប ហើយខ្ញុំរហ័សយល់អំពីដំណឹងល្អណាស់ ។ ប៉ុន្តែខ្ញុំបារម្ភពីចម្លើយដែលខ្ញុំអាចនឹងទទួល ។ បើដំណឹងល្អគឺពិត ខ្ញុំនឹងត្រូវតែធ្វើការផ្លាស់ប្ដូរជាច្រើន ។

## ជម្រើសថ្មី

បន្ទាប់ពីអែលឌើរបានចាកចេញទៅ ខ្ញុំពុំអាចឈប់គិតពីគ្រួសារដ៏រីករាយនោះបានទេ ។ គ្រួសារយើងមិនទាំងដូចនោះសូម្បីតែបន្តិច ។ ប៉ារបស់ខ្ញុំមិននៅក្នុងជីវិតខ្ញុំទេ ។ ចំណងទាក់ទងរបស់ខ្ញុំជាមួយនឹងម្ដាយខ្ញុំក៏មិនល្អដែរ ។ យាយរបស់ខ្ញុំជាអ្នកដែលថែទាំខ្ញុំ ប៉ុន្តែគ្មាននរណាក្នុងចំណោមយើងដែលប្រព្រឹត្តិដូចជាគ្រួសារមួយដែលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនឡើយ ។ គ្មាននរណាក្នុងចំណោមយើងបង្ហាញសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក ឬសូម្បីតែចំណាយពេលជាមួយគ្នាឲ្យបានច្រើនឡើយ ។

អស់មួយជីវិតខ្ញុំ ខ្ញុំបានសន្យានឹងខ្លួនឯងថា ខ្ញុំនឹងធ្វើជាឪពុកដ៏ល្អម្នាក់នៅថ្ងៃមួយ ។ ខ្ញុំនឹងធ្វើជាឪពុកដែលខ្ញុំមិនដែលមាន ។ ប៉ុន្តែនៅពេលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំ ខ្ញុំបានចាប់ផ្ដើមដឹងថា ខ្ញុំកំពុងធ្វើរឿងដូចគ្នាទៅនឹងឪពុកម្ដាយខ្ញុំបានធ្វើនៅពេលពួកគាត់អាយុស្របាលខ្ញុំ ។ ខ្ញុំ





ដំណឹងល្អបង្ហាញយើងពីរបៀបដើម្បីអភិវឌ្ឍគ្រួសារយើង មិនថាស្ថានភាពគ្រួសារមើលទៅយ៉ាងណានោះទេ ។

ដើរលេងយប់ជ្រៅ ធ្វើអ្វីដែលខ្ញុំចង់ធ្វើ ហើយរស់នៅដូចជាក្មេងទំនើងម្នាក់ ។ ខ្ញុំបានធ្វើរឿងដដែលដូចគ្នាដោយគ្មានចេតនា ។

វាដល់ពេលដើម្បីសួរដល់ព្រះហើយ ។

នៅទីបំផុត ពេលខ្ញុំបានអធិស្ឋាន ខ្ញុំបានទទួលចម្លើយដែលខ្ញុំរំពឹងថានឹងបានកន្លងមក ។ សាសនាចក្រគឺពិត ! ឥឡូវនេះ វាដល់ពេលដែលត្រូវធ្វើការជ្រើសរើសហើយ ។

## ខ្ញុំជាមនុស្សថ្មីម្នាក់

យាយខ្ញុំត្រូវតែផ្ដល់ការអនុញ្ញាតដល់ខ្ញុំពីមុនខ្ញុំអាចទទួលបុណ្យជ្រមុជទឹកបាន ។ គាត់បានជំទាស់ ប៉ុន្តែខ្ញុំជំនះ ។

« យាយ តើលេអូណាដូមួយណាដែលយាយចង់បានជាង ? » ខ្ញុំបានសួរ ។ « ជាម្នាក់ដែលដើរលេងក្រៅ ផឹក ជក់ ហើយមកផ្ទះវិញយប់ជ្រៅ ? ឬយាយពេញចិត្តខ្ញុំឥឡូវនេះជាង ? ការផ្លាស់ប្ដូរទាំងនេះគឺដោយសារតែដំណឹងល្អ » ។

ទីបំផុតយាយបានយល់ព្រម ហើយខ្ញុំបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។ តាំងពីគ្រានោះមក មានអ្វីមួយដែលគួរឲ្យចាប់អារម្មណ៍បានកើតឡើងនៅក្នុងគ្រួសារខ្ញុំ—ជាអ្វីដែលខ្ញុំពុំដឹងពេញលេញរហូតដល់ពីរបីឆ្នាំក្រោយមក ។

## គ្រួសារថ្មីមួយ

មុនពេលខ្ញុំចាកចេញទៅបេសកកម្មរបស់ខ្ញុំនៅភាគខាងត្បូងប្រទេសប្រេស៊ីល យាយបានចូលរួមសន្និសីទស្តេកមួយជាមួយខ្ញុំ ។ បន្ទាប់ពីនោះ យើងបានមានការប្រជុំថ្លែងទីបន្ទាល់តូចមួយជាមួយក្រុមគ្រួសារ និងមិត្តភក្តិ ។ ខ្ញុំភ្ញាក់ផ្អើលណាស់ដែលយាយចង់និយាយប្រាប់អ្វីមួយ ។

គាត់បាននិយាយថា « តាំងពីលេអូណាដូចូលព្រះវិហារអ្នកមក គ្រួសារខ្ញុំបានចាប់ផ្ដើមក្លាយជាគ្រួសារ*ពិត*មួយ » ។ បន្ទាប់មកគាត់បានរៀបរាប់ពីរបៀបដែលគ្រួសារយើងទាំងមូលបានខិតកាន់តែជិតស្និតនឹងគ្នា ៖ ឥឡូវនេះយើងបានចំណាយពេលជាមួយគ្នា ។ យើងបានចាប់ផ្ដើមនិយាយថា « ខ្ញុំស្រឡាញ់អ្នក » ទៅវិញទៅមក ដែលយើងមិនដែលនិយាយទេពីមុនមក ។ ការឈ្លោះប្រកែកបានបញ្ឈប់ ។ យើងបានអភិវឌ្ឍមិត្តភាពក្នុងចំណោមយើងទាំងអស់គ្នា ។ យើងមានម្ហូបទទួលទានកាន់តែច្រើន ហើយត្រូវបានប្រទានពរឲ្យយ៉ាងបរិបូរនៅចំនុចផ្សេងៗទៀត ។

ខ្ញុំបានសម្គាល់ឃើញការផ្លាស់ប្ដូរទាំងនេះផងដែរ ប៉ុន្តែខ្ញុំពុំបានដឹងថាពេលវេលាអាចភ្ជាប់ត្រឡប់ទៅពេលដែលខ្ញុំទទួលបុណ្យជ្រមុជទឹកនោះឡើយ ។

គាត់បាននិយាយថា « ខ្ញុំមិនមែនជាសមាជិកសាសនាចក្ររបស់អ្នក ប៉ុន្តែខ្ញុំជាមិត្តម្នាក់របស់សាសនាចក្រអ្នក ។ ហើយខ្ញុំដឹងថា គ្រួសារយើងត្រូវបានប្រទានពរដោយសារជម្រើសរបស់លេអូណាដូ » ។

## ការយល់ដឹងថ្មី

ខ្ញុំស្ទើរតែពុំអាចជឿបានទេ ! ប៉ុន្តែកាលដែលលោកយាយបាននិយាយអំពីរបៀបដែលគ្រួសារយើងកាន់តែមានភាពជិតស្និត មួយរំពេចនោះខ្ញុំបានចងចាំពីរូបថតដែលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្ហាញដល់ខ្ញុំជាច្រើនឆ្នាំកន្លងមក ។ កាលពីពេលនោះ ខ្ញុំបានគិតថា របៀបតែមួយដើម្បីមានគ្រួសារដ៏រីករាយគឺជាមួយគ្រួសារក្នុងពេលអនាគតរបស់ខ្ញុំ ។

ប៉ុន្តែខ្ញុំបានគិតខុសហើយ ។ គ្រួសារបច្ចុប្បន្នរបស់ខ្ញុំរីករាយ ! យើងបានចាប់ផ្ដើមស្រឡាញ់គ្នាទៅវិញទៅមក ។

ប្រហែលជាគ្មានសមាជិកគ្រួសាររបស់ខ្ញុំណាម្នាក់នឹងចូលព្រះវិហារនេះទេនៅក្នុងជីវិតនេះ ។ ប៉ុន្តែទោះបីពួកគាត់មិនចូល ខ្ញុំដឹងថាព្រះបានប្រទានពរដល់យើងក្នុងរបៀបជាច្រើនរួចទៅហើយ ។ ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទបង្ហាញយើងពីរបៀបដើម្បីអភិវឌ្ឍគ្រួសារយើង មិនថាស្ថានភាពគ្រួសារមើលទៅយ៉ាងណានោះទេ ។ ■

*ឥឡូវនេះអ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

# ការជ្រើសរើស
# ផ្លូវតូច និងចង្អៀត
# ជាជាង ផ្លូវធំទូលាយ



*មានផ្លូវពីរនៅពីមុខខ្ញុំ ហើយខ្ញុំបានដឹងថា មានតែវិធីមួយគត់
ដើម្បីដឹងថាត្រូវដើរផ្លូវណា ។*



**ដោយអែលឌើរ តាខាស្ស៊ី វ៉ាដា**
ក្នុងពួកចិតសិបនាក់

ខ្ញុំបានធំឡើងនៅទីក្រុងណាហ្កាណូ ប្រទេសជប៉ុន ជាមួយឪពុកម្ដាយខ្ញុំ ។ សាសនាជាផ្នែកមួយនៃអ្វីៗគ្រប់យ៉ាងដែលគ្រួសារខ្ញុំបានធ្វើ ។ ឪពុករបស់ខ្ញុំលុតជង្គង់នៅពីមុខអាសនាព្រះពុទ្ធជារៀងរាល់ព្រឹក និងយប់ ។ ខ្ញុំពុំបានគិតថាពុទ្ធសាសនាជាសាសនាមួយនោះទេ—វាជារបៀបនៃជីវិតរបស់យើង ។ វាងាយស្រួលជាងសម្រាប់ខ្ញុំដើម្បីបន្តនៅជាអ្នកកាន់សាសនាព្រះពុទ្ធអស់មួយជីវិតខ្ញុំ ប៉ុន្តែព្រះបានបង្ហាញដល់ខ្ញុំជាច្រើនដងថា របៀបដ៏ងាយស្រួល និងមានប្រជាប្រិយភាពមិនមែនតែងតែជារបៀបដែលល្អបំផុតនោះឡើយ ។



## សៀវភៅសិក្សា ឬសៀវភៅដ៏បរិសុទ្ធ ?

ពេលខ្ញុំនៅជាក្មេងប្រុសជំទង់ម្នាក់ ខ្ញុំមានការលំបាកជាខ្លាំងជាមួយនឹងអត្តសញ្ញាណរបស់ខ្ញុំ ។ ខ្ញុំឆ្ងល់ថាហេតុអ្វីខ្ញុំនៅលើផែនដីនេះ ហើយតើខ្ញុំត្រូវក្លាយជានរណា ។ ពេលខ្ញុំអាយុប្រហែល ១៣ ឆ្នាំ នាយកសាលារបស់ខ្ញុំបានឲ្យព្រះគម្ពីរសញ្ញាថ្មីដល់សិស្សគ្រប់គ្នាជាភាសាអង់គ្លេស និងភាសាជប៉ុននៅទន្ទឹមគ្នា ។ គាត់បាននិយាយថា « វាពុំមែនដើម្បីគោលបំណងខាងសាសនានោះទេ » ។ « វាជាការបកប្រែដ៏ល្អ អញ្ចឹងចូរប្រើវាដើម្បីសិក្សាភាសាអង់គ្លេសទៅ » ។ តែពេលដែលខ្ញុំបើកវាឡើង វាបានផ្ដល់នូវគម្ពីរយោងសម្រាប់ពេលអ្នកមានអារម្មណ៍ឯកោ ត្រូវការចម្លើយចំពោះសំណួររបស់អ្នក ឬពេលកំពុងជួបការលំបាក ។ ខ្ញុំអាចភ្ជាប់ទៅនឹងស្ថានភាពទាំងអស់នោះ !

ខ្ញុំបានអានអំពីព្រះយេស៊ូវគ្រីស្ទ ។ « អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក » ( ម៉ាថាយ ១១:២៨ ) « ផ្ទុកឈើឆ្កាង [ របស់អ្នក ] មកតាមខ្ញុំចុះ » ( ម៉ាថាយ ១៦:២៤ ) ។ ពាក្យទាំងនោះលាន់ឮរំពងក្នុងចិត្តខ្ញុំ សូម្បីតែខ្ញុំមិនបានយល់វាពេញលេញក៏ដោយ ។ ខ្ញុំឆ្ងល់ថានរណាជាព្រះយេស៊ូវគ្រីស្ទ ហើយថាតើវាមានន័យយ៉ាងណាដើម្បីមានទ្រង់ជាព្រះអង្គសង្គ្រោះមួយអង្គនោះ ។ ខ្ញុំឆ្ងល់ថាបើខ្ញុំជាមនុស្សតែម្នាក់គត់ដែលមានអារម្មណ៍ទាក់ទងបែបនោះទៅនឹងអ្វីដែលគ្រាន់តែជាសៀវភៅសិក្សានោះ ។

## រត់ចេញ ឬនៅ ហើយស្ដាប់ ?

ពីរបីឆ្នាំក្រោយមក ខ្ញុំបានជួបពួកអ្នកផ្សព្វផ្សាយសាសនាមួយចំនួនជាលើកដំបូង ។ ឪពុកម្ដាយខ្ញុំបានព្រមានខ្ញុំអំពីពួកគ្រីស្ទានវ័យក្មេងដែលដើរផ្សព្វផ្សាយនោះ ។ ពេលខ្ញុំកំពុងដើរមកផ្ទះ អ្នកផ្សព្វផ្សាយសាសនាអាមេរិកខ្ពស់ម្នាក់ដែលមានស្នាមញញឹមដ៏ស្រទន់បានបញ្ឈប់ខ្ញុំ ។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីឡើយ ។ ខ្ញុំមានការព្រួយបារម្ភថាគាត់នឹងនិយាយអំពីព្រះវិហាររបស់គាត់ ។ បើគាត់ធ្វើដូច្នោះ ខ្ញុំអាចនឹងរត់ទៅម្ខាងទៀត ! អ្វីដែលគាត់សួរគឺផ្លូវណាទៅការិយាល័យប្រៃសណីយ៍ ។ ខ្ញុំបានប្រាប់គាត់ ហើយបានដើរទៅផ្ទះ ។

កាលដែលខ្ញុំបានដើរចេញទៅ ខ្ញុំបានទទួលអារម្មណ៍អ្វីមួយ ។ ខ្ញុំបានគិតថា *បើសិនខ្ញុំឃើញពួកអ្នកផ្សព្វផ្សាយសាសនាម្ដងទៀត ខ្ញុំនឹងនិយាយទៅកាន់ពួកគេ* ។

មិនយូរប៉ុន្មានបន្ទាប់ពីនោះ ខ្ញុំបានជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនាមួយគូផ្សេងទៀត ។ ខ្ញុំភ្ញាក់ផ្អើលណាស់ដែលព្រះឮ ហើយឆ្លើយតបការអធិស្ឋានរបស់ក្មេងប្រុសម្នាក់ដូចជាខ្ញុំ រហូតដល់ខ្ញុំបានអានអំពី យ៉ូសែប ស្ម៊ីធ ។ ខ្ញុំបានអាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីថាឲ្យអធិស្ឋានជានិច្ច ប៉ុន្តែព្រះបានយាងមកឯបុរសម្នាក់ ? វាមានអារម្មណ៍ថាទូលំទូលាយផង ហើយត្រឹមត្រូវផង ។ ជំនួសឲ្យការរត់ចេញ ខ្ញុំបានធ្វើការណាត់មួយដើម្បីឲ្យពួកគេបង្រៀនខ្ញុំ ។



រចនារូបភាពដោយ គ្រីស្ទី អ៊ែន



### ធ្វើការដោះសារ ឬរកឃើញសេចក្ដីពិត ?

មួយខែក្នុងការជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនា ពួកគេបានអញ្ជើញខ្ញុំឲ្យទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំមិនចង់បដិសេធពួកគេទេ ប៉ុន្តែខ្ញុំមានការស្ទាក់ស្ទើរនឹងចាកចេញពីប្រពៃណីរបស់ឪពុកម្ដាយខ្ញុំ និងគ្រប់គ្នានៅជុំវិញខ្ញុំ ។ មានផ្លូវពីរនៅពីមុខខ្ញុំ ហើយខ្ញុំបានដឹងថា មានតែវិធីមួយគត់ដើម្បីដឹងថាត្រូវដើរផ្លូវណា ខ្ញុំត្រូវតែអធិស្ឋានដូចជាយ៉ូសែប ស្ម៊ីធ ។ ខ្ញុំបានសួរព្រះវរបិតាសួគ៌ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ថាបើអ្វីៗដែលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំពិតឬទេ ។

នោះគឺជាចំណុចចាប់ផ្ដើមរបស់ខ្ញុំ ។ តាំងពីនោះមកខ្ញុំបានដឹងដោយខ្លួនខ្ញុំថា ដំណឹងល្អដែលបានស្ដារឡើងវិញគឺពិត ។ គ្មាននរណាម្នាក់អាចដកយកការចេះដឹងនោះចេញពីខ្ញុំឡើយ ។ ខ្ញុំបានដឹងថាត្រូវដើរផ្លូវណា ហើយពុំមានអ្វីអាចផ្លាស់ប្ដូរវាបានឡើយ ។

ខ្ញុំមានសំណួរជាច្រើន ពេលខ្ញុំនៅក្មេង ។ ខ្ញុំបានរៀនថា ខ្ញុំជាបុត្ររបស់ព្រះ ទ្រង់ស្រឡាញ់ខ្ញុំ ទ្រង់មានផែនការមួយសម្រាប់ខ្ញុំ ហើយទ្រង់មានព្រះទ័យចង់ឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ។ ការចេះដឹងនេះបានផ្លាស់ប្ដូរទស្សនវិស័យទាំងមូលរបស់ខ្ញុំទៅលើជីវិត ។ ខ្ញុំបានរៀនថាខ្ញុំជានរណា ហើយថាអ្វីដែលខ្ញុំធ្វើគឺសំខាន់ ។

### ធ្វើដូចគេដូចឯង ឬធ្វើខុសពីគេ ?

ពីមុនដែលខ្ញុំបានដឹងថាខ្ញុំជាបុត្ររបស់ព្រះ ខ្ញុំបានចង់ធ្វើដូចជាគេឯងគ្រប់គ្នាអញ្ចឹង ។ ខ្ញុំខ្លាចក្នុងការធ្វើខុសពីគេ ។ ប៉ុន្តែបន្ទាប់ពីខ្ញុំបានដឹងថាខ្ញុំជាបុត្ររបស់ព្រះ ខ្ញុំបានដឹងថា ខ្ញុំអាចធ្វើខុសពីគេ ខ្ញុំអាចខុសប្លែកពីគេ ។

ការអធិស្ឋាន និងការដឹងថា ខ្ញុំជាបុត្រានៃព្រះផ្ដល់ភាពក្លាហានដល់ខ្ញុំដើម្បីពន្យល់ពីអារម្មណ៍របស់ខ្ញុំទៅកាន់ឪពុកម្ដាយខ្ញុំ ប៉ុន្តែពួកគាត់មិនជាយល់នោះទេ ។ ពួកគាត់គិតថាខ្ញុំជាកូនរឹងទទឹង ហើយថាខ្ញុំនៅក្មេងពេកដើម្បីធ្វើការសម្រេចចិត្តក្នុងការទទួលបុណ្យជ្រមុជទឹក ។ ពួកគាត់មានភាពអាម៉ាសដែលកូនប្រុសពួកគាត់ធ្វើតាមសាសនាចម្លែកនេះ ផ្ទុយពីប្រពៃណីរបស់ពួកគាត់ ។ ខ្ញុំបានដឹងថាខ្ញុំជានរណា និងពីអ្វីដែលខ្ញុំចង់បាន ប៉ុន្តែខ្ញុំក៏ចង់គោរពដល់ឪពុកម្ដាយរបស់ខ្ញុំផងដែរ ហើយបានសង្ឃឹមថាពួកគេនឹងគោរពដល់សាសនាខ្ញុំដែរ ។





## គោរពដល់ឪពុកម្ដាយខ្ញុំ ឬមិនអើពើនឹងកង្វល់របស់ពួកគាត់ ?

ខ្ញុំបានពន្យល់ពីស្ថានភាពរបស់ខ្ញុំទៅពួកអ្នកផ្សព្វផ្សាយសាសនាស៊ីស្ទើរ ។ ពួកគេបានមានគំនិតមួយ—ពួកគេអាចមកនិយាយជាមួយឪពុកម្ដាយខ្ញុំ ដើម្បីឲ្យពួកគាត់មានអារម្មណ៍ប្រសើរជាងអំពីសាសនានេះ ។ ខ្ញុំបានប្រាប់ពួកគេថា ខ្ញុំខ្លាចថាឪពុកម្ដាយខ្ញុំមិនចង់និយាយនឹងពួកគេទេ ។ បន្ទាប់មក ស៊ីស្ទើរម្នាក់បានផ្ដល់យោបល់ថាយើងធ្វើការតមអាហារជាមួយគ្នា ។

ពេលខ្ញុំមិនបានញ៉ាំអាហារពេលព្រឹក ម្ដាយខ្ញុំព្រួយបារម្ភ ។ គាត់បានសួរថា « ហេតុអ្វីកូនមិនញ៉ាំ ? » ខ្ញុំបានពន្យល់ថា ខ្ញុំកំពុងតមអាហារ ហើយវាបានធ្វើឲ្យគាត់កាន់តែខ្វល់ខ្វាយថែមទៀត ។

« ដំបូងកូនទៅសាសនាដែលគ្មាននរណាស្គាល់ ហើយឥឡូវកូនអត់ញ៉ាំអាហារ ។ ម៉ាក់ព្រួយបារម្ភណាស់ ។ ម៉ាក់តក់ស្លុត ! ម៉ាក់នឹងទូរសព្ទទៅពួកអ្នកផ្សព្វផ្សាយសាសនាទាំងនោះ » ។



គាត់*ពិតជាបាន*ទូរសព្ទទៅពួកស៊ីស្ទើរ ហើយមិនដឹងជាយ៉ាងណាពួកគេត្រូវបានអញ្ជើញឲ្យមកផ្ទះយើងសម្រាប់អាហារពេលល្ងាច !



យើងមានពេលដ៏អស្ចារ្យមួយ ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនឪពុកម្ដាយខ្ញុំនូវទំនុកតម្កើង « ខ្ញុំជាកូនរបស់ព្រះ » ( *ទំនុកតម្កើង* លេខ ១៨៨ ) ហើយយើងបានច្រៀងវាជាមួយគ្នា ។ ឪពុកខ្ញុំចូលចិត្តណាស់ ។ បន្ទាប់អាហារពេលល្ងាចជាមួយពួកស៊ីស្ទើរហើយ ទាំងឪពុក និងម្ដាយខ្ញុំ ពុំមាននរណាព្រួយបារម្ភពីខ្ញុំទៅព្រះវិហារទៀតឡើយ ។ ហើយខ្ញុំបានមារម្មណ៍ថា ខ្ញុំអាចគោរពដល់ពួកគាត់ដោយការរស់នៅតាមដំណឹងល្អ ដោយសារវាពិតជាបញ្ចូលនូវអ្វីៗគ្រប់យ៉ាងដែលពួកគាត់បានបង្រៀនខ្ញុំ ។ ខ្ញុំបានគិតថា ប្រសិនបើខ្ញុំស្រឡាញ់ពួកគាត់គ្រប់គ្រាន់ ហើយប្រព្រឹត្តិចំពោះពួកគាត់ដោយសប្បុរសគ្រប់គ្រាន់ នោះនៅទីបំផុតពួកគាត់នឹងយល់ ។ វាត្រូវការពេល ៣៥ ឆ្នាំបន្ទាប់ពីបុណ្យជ្រមុជទឹករបស់ខ្ញុំ ប៉ុន្តែម្ដាយខ្ញុំទើបតែបានទទួលបុណ្យជ្រមុជទឹក ហើយបានទៅព្រះវិហារបរិសុទ្ធកាលពីពីរបីឆ្នាំមុននេះប៉ុណ្ណោះ !

ការដឹងថាខ្ញុំជាបុត្ររបស់ព្រះ បានជះឥទ្ធិពលលើការសម្រេចចិត្តជាច្រើននៅក្នុងជីវិតរបស់ខ្ញុំ ។ ខ្ញុំក៏ដឹងដែរថា កាលដែលយើងធ្វើតាមព្រះវិញ្ញាណ ហើយធ្វើនូវអ្វីដែលព្រះវរបិតាសួគ៌សុំពីយើង សូម្បីតែនៅពេលវាហាក់ដូចជាពិបាកក្ដី ទ្រង់នឹងប្រទានពរដល់យើង ។ នោះតែងតែជាជម្រើសដ៏ល្អបំផុត ។ ■



# ការប្រើប្រាស់ពេលវេលារបស់អ្នកឱ្យបានល្អ

*ពេលអ្នកទុកព្រះជាទីមួយ នោះមានកន្លែងសម្រាប់អ្វីគ្រប់យ៉ាងផ្សេងទៀត ។*

**ដោយ ណាតាស្យា អាន់ឌើរសិន**
ទស្សនាវដ្ដីសាសនាចក្រ

**សម្ភារ**

- ☐ ក្រឡថ្លាមួយ
- ☐ ខ្សាច់ គ្រួសល្អិតៗ អង្ករ និងគ្រួស
- ☐ ដុំថ្មធំៗ ( ទំហំប្រហែលកូនបាល់ហ្គុលហ្វ៍ ឬដែលមានអង្កត់ផ្ចិតប្រហែល ៥ សង់ទីម៉ែត្រ )

**ការរៀបចំ ៖** វាល់គ្រឿងផ្សំទុកជាមុនដោយដាក់ដុំថ្មធំៗនៅក្នុងក្រឡជាមុន ។ ថែមខ្សាច់ ( ឬគ្រួសល្អិតៗ អង្ករ ឬគ្រួស ) ឲ្យល្មមដើម្បីបំពេញដល់មាត់ក្រឡ ។ អ្នកគួរតែក្រឡុកក្រឡនោះ ពេលអ្នកថែមខ្សាច់ ដើម្បីឲ្យវាបំពេញគ្រប់ចន្លោះ ។ ឥឡូវនេះចាក់ថ្ម និងខ្សាច់ទៅក្នុងប្រអប់ផ្សេងគ្នាមុននឹងអ្នកបង្រៀនមេរៀននេះ ។

**តើ**មានសកម្មភាពខុសៗគ្នាប៉ុន្មានដែលទាមទារនូវការយកចិត្តទុកដាក់របស់អ្នកជារៀងរាល់ថ្ងៃ ? យើងទាំងអស់គ្នាមានពេល ២៤ ម៉ោងដូចគ្នាដើម្បីប្រើ ប៉ុន្តែរបៀបដែលយើងជ្រើសរើសដើម្បីប្រើប្រាស់ពេលវេលានោះធ្វើឲ្យមានភាពខុសគ្នាយ៉ាងធំ !

ប្រធាន ដាល្លិន អេក អូក ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ ៖ « ចំនួននៃរឿងល្អៗដែលយើងអាចធ្វើមានច្រើនជាងពេលវេលាដែលយើងមានដើម្បីសម្រេចរឿងល្អៗទាំងនោះទៅទៀត ។ មានអ្វីៗជាច្រើនដែលប្រសើរជាងការគ្រាន់តែល្អ ហើយរឿងទាំងនេះគួរតែជារឿងដែលបញ្ជាឲ្យផ្ដោតយកចិត្តទុកដាក់ជាចម្បងនៅក្នុងជីវិតរបស់យើង ។ . . . យើងត្រូវលះបង់រឿងល្អៗខ្លះដើម្បីជ្រើសរើសអ្វីផ្សេងទៀតដែលល្អប្រសើរ ឬល្អបំផុត » ។[១]

នៅក្នុងសកម្មភាពនេះ បងប្អូននឹងបង្ហាញពីអ្វីដែលកើតឡើងពេលយើងធ្វើឲ្យកិច្ចការរបស់ព្រះអម្ចាស់ជាអាទិភាពទីមួយ ។

**១. បំពេញពេលវេលា**

មានសកម្មភាពល្អៗជាច្រើនដែលយើងអាចប្រើប្រាស់ពេលវេលារបស់យើងដើម្បីធ្វើវា ។ សូមដល់គ្រួសារបងប្អូនឲ្យចែកចាយការណ៍មួយចំនួនដែលពួកគេចំណាយពេលរបស់ពួកគេធ្វើវាជារៀងរាល់ថ្ងៃ ។

ពន្យល់ថាក្រឡគឺតំណាងឲ្យពេលវេលា ។ ថ្ម និងខ្សាច់តំណាងឲ្យការណ៍ផ្សេងៗដែលយើងអាចធ្វើជាមួយពេលវេលារបស់យើង ៖ ដុំថ្មធំៗតំណាងឲ្យការណ៍ទាំងឡាយដែល




រូបគំនូរដោយ ផើង ហាប៊ីន

ព្រះអម្ចាស់សុំឲ្យយើងដាក់អាទិភាព ដូចជាការសិក្សាព្រះគម្ពីរ ការបម្រើព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ និងការចូលរួមនៅព្រះវិហារ ខណៈដែលខ្សាច់តំណាងឲ្យសកម្មភាពល្អៗផ្សេងៗទៀត ដូចជាធ្វើកិច្ចការសាលា និងចំណាយពេលជាមួយមិត្តភក្តិ ។

### ២. ដាក់អាទិភាពទៅតាមលំដាប់

ចាក់ខ្សាច់ទាំងអស់ចូលទៅក្នុងក្រឡជាមុន បន្ទាប់មកបន្ថែមដុំថ្មធំៗនៅពីលើ ។ ពេលបងប្អូនចាក់ខ្សាច់ទាំងអស់ចូលមុន នោះពុំមានចន្លោះគ្រប់គ្រាន់សម្រាប់ដុំថ្មធំៗទាំងអស់នោះទេ—ដូចជាពេលយើងដាក់អាទិភាពទៅលើសកម្មភាពផ្សេងៗមុនការណ៍ទាំងឡាយដែលព្រះវរបិតាសួគ៌បានបញ្ជាយើងឲ្យធ្វើ យើងអាចនឹងអស់ពេលវេលាសម្រាប់ការណ៍ទាំងឡាយដែលសំខាន់បំផុត ។

### ៣. ចូលតាមកន្លែង

ព្រះយេស៊ូវគ្រីស្ទបានបញ្ជាថា « ចូរកុំស្វែងរករបស់ខាងលោកិយនេះ ប៉ុន្តែចូរស្វែងរកការស្ថាបនានគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន » ( Joseph Smith Translation Matthew 6:38 [ នៅក្នុង Matthew 6:33 លេខយោង *a* ] ) ។ ពិភាក្សាពីរបៀបដែលបងប្អូនអាចដាក់អាទិភាពពេលវេលារបស់បងប្អូនដោយការស្វែងរកនគរនៃព្រះ*ជាមុន*សិន ។

ចាក់ថ្ម និងខ្សាច់ចេញពីក្រឡ ហើយចាប់ផ្ដើមម្ដងទៀតជាមួយនឹងរបស់ដដែល ។ បងប្អូនក្មេងៗអាចនឹងចង់ជួយ ។ ឲ្យពួកគេដាក់ដុំថ្មធំៗនៅក្នុងក្រឡជាមុនសិន ។ ពេលបងប្អូនចាក់ខ្សាច់ចូលបន្ទាប់ពីនោះ ចូរមើលពីរបៀបដែលវាបំពេញទៅក្នុងចន្លោះនៅជុំវិញដុំថ្មធំៗរហូតទាល់តែខ្សាច់ទាំងអស់ចូលទៅក្នុង ។

សួរដល់គ្រួសារបងប្អូនថាពួកគេគិតថាការសន្យានេះមកពីប្រធាន រ័សុល អិម ណិលសុន អាចនឹងមានអត្ថន័យយ៉ាងណា ៖ « ពេលដែលបងប្អូនផ្ដល់ពេលវេលាមួយផ្នែករបស់បងប្អូនដោយសប្បុរសទៅព្រះអម្ចាស់ នោះទ្រង់នឹងគុណអ្វីដែលនៅសល់ » ។[២]

### ទុកព្រះអម្ចាស់ជាទីមួយ

ពេលយើងព្យាយាមធ្វើតាមព្រះហឫទ័យរបស់ព្រះ*ជាមុន* នោះទ្រង់ជួយយើងឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការណ៍ទាំងឡាយដែលចាំបាច់ និងលើកស្ទួយ ។ ដូច្នេះប្រសិនបើបងប្អូនមានការលំបាកដើម្បីរកពេលគ្រប់គ្រាន់ដើម្បីបញ្ចប់កិច្ចការសាលា អភិវឌ្ឍទេពកោសល្យរបស់បងប្អូន ឬបានការគេងដែលបងប្អូនត្រូវការ សូមសួរដល់ព្រះអម្ចាស់នូវអ្វីដែលបងប្អូនអាចធ្វើដើម្បីដាក់អាទិភាពពេលវេលារបស់បងប្អូនស្របទៅតាមផែនការរបស់ទ្រង់ ។ ដាក់គោលដៅជាមួយគ្នាជាក្រុមគ្រួសារ ដើម្បីដាក់កិច្ចការរបស់ព្រះអម្ចាស់—និងចំណងទាក់ទងរបស់បងប្អូនជាមួយទ្រង់—ជាមុនជារៀងរាល់ថ្ងៃ ។ ■




**កំណត់ចំណាំ**

១. ដាល្លិន អេក អូក « Good, Better, Best» *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ១០៤, ១០៧ ។
២. រ័សុល អិម ណិលសុន « Stand as True Millennials » *Liahona* ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ៥១ ។



# ការបំផុសឥតឈប់ឈរមួយ

ថ្ងៃមួយ ពេលកំពុងធ្វើកិច្ចការផ្សព្វផ្សាយសាសនានៅតាមផ្លូវដើហុយក្នុងប្រទេសកេនយ៉ា ដៃគូរបស់ខ្ញុំ និងខ្ញុំបាននិយាយទៅកាន់ស្ត្រីម្នាក់ ។ គាត់បានទទួលយកកូនសៀវភៅដែលយើងឲ្យគាត់ ប៉ុន្តែបានប្រាប់យើងថាកុំឲ្យត្រឡប់មកវិញ ។

ពីរបីថ្ងៃក្រោយមក យើងបាននៅលើផ្លូវដដែលនោះ ហើយយើងបានទទួលការបំផុសមួយឲ្យទៅធ្វើការតាមដានជាមួយគាត់ ។ ខ្ញុំបានសួរខ្លួនឯងថា « ហេតុអ្វីយើងត្រូវត្រឡប់ទៅវិញពេលដែលគាត់បានប្រាប់យើងថាកុំឲ្យត្រឡប់មកវិញនោះ ? » ប៉ុន្តែយើងបានធ្វើតាមការបំផុសនោះ ។

គាត់មានការភ្ញាក់ផ្អើលពេលយើងទៅដល់ទីនោះ ប៉ុន្តែបាននិយាយថា គាត់សប្បាយចិត្តដែលឃើញពួកយើង ។ យើងបានចាប់ផ្ដើមបង្រៀនមេរៀនមួយ ប៉ុន្តែមិនយូរប៉ុន្មានវាបានប្រែទៅជាការប្រកែកមួយ ។ ដៃគូរបស់ខ្ញុំ និងខ្ញុំបានបញ្ចប់មេរៀនជាមួយនឹងការអធិស្ឋានមួយ ហើយបានចាកចេញ ដោយយល់ស្របនឹងគ្នាភ្លាមថាមិនត្រឡប់មកវិញទេ ។ ប៉ុន្តែនៅថ្ងៃបន្ទាប់នោះ *ជាថ្មីម្ដងទៀត* យើងបានមានការបំផុសដ៏ខ្លាំងមួយឲ្យត្រឡប់ទៅវិញ ។ ខ្ញុំមិនចង់ត្រឡប់ទៅវិញទេ ប៉ុន្តែដៃគូរបស់ខ្ញុំបាននិយាយថា យើងគួរតែស្ដាប់តាមព្រះវិញ្ញាណ ។ ដូច្នេះខ្ញុំបានលេបអំនួតរបស់ខ្ញុំ ហើយយើងបានត្រឡប់ទៅវិញ ។ ពេលយើងទៅដល់ទីនោះ ខ្ញុំបានមានការតក់ស្លុត ។ ស្ត្រីនោះហាក់ដូចជាមនុស្សផ្សេងម្នាក់ ។ ផ្ទៃមុខគាត់បានផ្លាស់ប្ដូរ ហើយគាត់យល់ព្រមស្ដាប់នូវអ្វីដែលយើងនិយាយ ។ អំឡុងពេលនៃការជួបបន្ទាប់ទៀត គាត់បានសួរយើងថាពេលណាគាត់អាចទទួលបុណ្យជ្រមុជទឹកបាន ។

បួនសប្ដាហ៍បន្ទាប់មក គាត់បានទទួលបុណ្យជ្រមុជទឹកជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ បន្ទាប់ពីការបញ្ជាក់របស់គាត់ គាត់បានឱបយើង ហើយបានប្រាប់យើងថា គាត់មានអំណរគុណណាស់ដែលយើងបានត្រឡប់មកវិញ ។ ខ្ញុំបានរៀនថា យើងគប្បីតែងតែស្ដាប់តាម ហើយប្រព្រឹត្តិតាមការបំផុសគំនិតទាំងឡាយ ។ ព្រះវរបិតាសួគ៌ពិតជារៀបចំបុត្រាបុត្រីទ្រង់ឲ្យទទួលដំណឹងល្អ ហើយទ្រង់ប្រើប្រាស់យើងទាំងអស់គ្នាឲ្យស្វែងរកពួកគេតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ■

*លេអាហា អិម. ខេត្តក្វាហ្សូលូ-ណាថាល ប្រទេសអាហ្វ្រិកខាងត្បូង*

**តើខ្ញុំអាចធ្វើតាមការបំផុសគំនិតឲ្យបានកាន់តែប្រសើរយ៉ាងដូចម្ដេច ?**

១. **អធិស្ឋានទូលសូមការដឹកនាំ ។** ព្រះអម្ចាស់នឹងដឹកនាំយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល អាលម៉ា ៣៧:៣៧ ) ។

២. **មានចិត្តរាបសា ។** ភាពស្លូតបូតអញ្ជើញព្រះវិញ្ញាណ ( សូមមើល មរ៉ូណៃ ៨:២៦ ) ។

៣. **ចូរកុំស្ទាក់ស្ទើរឡើយ ។** មនុស្សខាងសាច់ឈាមល្បួងអ្នកឲ្យព្រងើយកន្តើយនឹងការបំផុសគំនិ ត ( សូមមើល ម៉ូសាយ ៣:១៩ ) ។ កុំសង្ស័យពេលគំនិតល្អចូលមក !

៤. **ប្រព្រឹត្តិភ្លាមៗ ។** តាំងចិត្តដើម្បីឆ្លើយតប*ភ្លាមៗ*ជានិច្ចដល់ការបំផុសគំនិតពីព្រះវិញ្ញាណ ( សូមមើល ថូម៉ាស អេស ម៉នសុន «The Spirit Giveth Life » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៥ ទំព័រ ៦៨–៧០ ) ។

រចនារូបភាពដោយ ជូលី ញ៉ូសំ

# មូលហេតុសម្រាប់វិន័យទាំងឡាយ

ខ្ញុំរំភើបចិត្តនឹងទៅសន្និសីទយុវវ័យ តែបន្ទាប់មកខ្ញុំបានដឹងថាមានវិន័យជាច្រើន—ឧទាហរណ៍ មិនឲ្យមានទូរសព្ទដៃ ហើយមិនឲ្យទៅក្រៅតែឯង ។ វាហាក់បីដូចជាមជ្ឈិវ័យចាំឃ្លាំមើលយើងឥតឈប់ ។ ប៉ុន្តែខ្ញុំបានមានពេលវេលាដ៏អស្ចារ្យមួយ ដោយបានបង្កើតមិត្តភក្តិជាច្រើន បានធ្វើគម្រោងការបម្រើមួយ ហើយបានរៀនអំពីដំណឹងល្អ ។

អំឡុងការប្រជុំថ្លែងទីបន្ទាល់នៅថ្ងៃចុងក្រោយនៃសន្និសីទយុវវ័យ ថ្នាក់ដឹកនាំម្នាក់បានប្រាប់យើងពីទំហំនៃសេចក្ដីស្រលាញ់ដែលគាត់មានចំពោះយើង ជាយុវវ័យនៃស្តេកនោះ ។

*បើបងស្រឡាញ់ពួកយើង ហេតុអ្វីយើងមានការដាក់កម្រិតច្រើនម្ល៉េះ ?* ខ្ញុំបានគិត ។ នៅគ្រាដដែលនោះ ដូចជាគាត់អាចមើលចិត្តខ្ញុំធ្លុះអញ្ចឹង គាត់បានឆ្លើយសំណួររបស់ខ្ញុំ ។

គាត់បាននិយាយថា ថ្នាក់ដឹកនាំបានបង្កើតវិន័យ មិនមែនដើម្បីធ្វើឲ្យយើងធុញទ្រាន់នោះទេ ប៉ុន្តែគឺដើម្បីសុវត្ថិភាពរបស់យើង ។ ពេលដែលគាត់បាននិយាយពាក្យនោះភ្លាម ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណភ្លាម ។ ខ្ញុំបានយល់ថា ព្រះវរបិតាសួគ៌ប្រទានបទបញ្ញត្តិទាំងឡាយដោយសារមូលហេតុដូចគ្នានោះ ។ បទបញ្ញត្តិទាំងឡាយមិនមែនដើម្បីធ្វើឲ្យយើងធុញទ្រាន់នោះទេ វាគឺដើម្បីជួយយើងឲ្យត្រឡប់ទៅកាន់ទ្រង់វិញដោយសុវត្ថិភាព ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨២:២–៩ ) ។

ព្រះវិញ្ញាណបរិសុទ្ធបានប៉ះចិត្តខ្ញុំ ហើយបានជួយខ្ញុំឲ្យដឹងថាការណ៍នេះពិត ។ ■

*ស៊ើច ភី អិល-ឌ័រ-ហ្វ្រេន ប្រទេសបារាំង*





# តើពេលណាខ្ញុំអាចចូលរួមសាសនាចក្របាន ?

ពេលខ្ញុំអាយុប្រហែលប្រាំឆ្នាំ ប៉ាខ្ញុំបានបាត់បង់សេចក្ដីជំនឿ ហើយបានសម្រេចចិត្តចាកចេញពីព្រះវិហារ ។ វាពិបាកណាស់ ជាពិសេសពេលខ្ញុំបានឈានចូលដល់អាយុប្រាំបីឆ្នាំ ។ ខ្ញុំរំភើបណាស់ដើម្បីទទួលបុណ្យជ្រមុជទឹក ប៉ុន្តែប៉ារបស់ខ្ញុំថាទេ ។ គាត់ចង់ឲ្យខ្ញុំរង់ចាំរហូតដល់ខ្ញុំធំសិន ដើម្បីខ្ញុំអាចដឹងដោយប្រាកដថាខ្ញុំចង់តាំងចិត្តដែរឬទេ ។ ដូច្នេះខ្ញុំបានមើលពេលដែលមិត្តភក្តិរបស់ខ្ញុំទទួលបុណ្យជ្រមុជទឹក ។

ខ្ញុំចាំបានពីការភាន់ច្រឡំ—បើសាសនាចក្រពិត ហេតុអ្វីខ្ញុំត្រូវបានបញ្ឈប់ពីការទទួលបុណ្យជ្រមុជទឹក ? ពេលជាយុវវ័យម្នាក់ វាពិបាកណាស់ដែលឃើញពួកយុវវ័យទៅព្រះវិហារបរិសុទ្ធដោយសារខ្ញុំចង់ទៅខ្លាំងមែនទែន ។ វាពិបាកដែលមិនបានរួមចំណែក ប៉ុន្តែខ្ញុំតែងតែបានដឹងថា ខ្ញុំនឹងមានឱកាស !

នៅក្នុងខែ ឧសភា ឆ្នាំ ២០១៩ នៅទីបំផុតខ្ញុំបានទទួលបុណ្យជ្រមុជទឹកពេលខ្ញុំមានអាយុ ១៦ ឆ្នាំ ។ ខ្ញុំបានចាំពីបទពិសោធន៍ជាច្រើនដែលខ្ញុំបានមានអារម្មណ៍ អំណរដ៏បរិសុទ្ធនៃដំណឹងល្អ និងការទទួលបានទីបន្ទាល់មួយ ។ វាជាបទពិសោធន៍ដ៏ពិសេសមួយ ហើយឆ្លងកាត់អស់ទាំងបញ្ហាដែលខ្ញុំបានមានដើម្បីបានមកដល់ថ្ងៃនេះ ខ្ញុំបានដឹងដោយអស់ពីចិត្តខ្ញុំថា ដំណឹងល្អគឺពិត ហើយវាតែងតែពិតជានិច្ច ។ ■

*ទ្រិនិធី ស៊ី រដ្ឋខូឡូរ៉ាដូ ស.រ.អា.*

# ទីបន្ទាល់ និង ការប្រែចិត្តជឿ

**ដោយអែលឌើរ ដាវីឌ អេ បែដណា**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

មេរៀនសំខាន់មួយអំពីទំនាក់ទំនងរវាងទីបន្ទាល់ និងការប្រែចិត្តជឿ ត្រូវបានបង្ហាញក្នុងការបម្រើជាអ្នកផ្សាយសាសនារបស់ពួកបុត្រានៃម៉ូសាយ ។

« មនុស្សជាច្រើនដែលត្រូវបាននាំមកឲ្យស្គាល់សេចក្តីពិតតាមរយៈការផ្សាយរបស់អាំម៉ូន និងបងប្អូនលោក ស្របតាមវិញ្ញាណនៃវិវរណៈ និងវិញ្ញាណនៃការព្យាករណ៍ និងព្រះចេស្តានៃព្រះ ដែលសម្តែងអព្ភូតហេតុនៅក្នុងពួកគេ—មែនហើយ . . . ដរាបណាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ គឺដរាបណាមានពួកលេមិនជាច្រើនបានជឿតាមការផ្សាយរបស់ពួកគេ ហើយបានប្រែចិត្តជឿដល់ព្រះអម្ចាស់ នោះពួកគេពុំបោះបង់ចោលសាសនាឡើយ ។

« ព្រោះពួកគេបានក្លាយទៅជាប្រជាជនមួយដ៏សុចរិត ពួកគេបានដាក់គ្រឿងសស្ត្រាវុធនៃការបះបោររបស់គេចុះ ដែលកុំឲ្យពួកគេប្រយុទ្ធនឹងព្រះ . . . ទៀតឡើយ ។ . . .

« ឥឡូវនេះពួកអ្នកទាំងនេះហើយដែលបានប្រែចិត្តជឿដល់ព្រះអម្ចាស់ » ( អាលម៉ា ២៣:៦–៨ ) ។

ជាតុចម្បងពីរដែលបានពណ៌នាក្នុងខទាំងនេះគឺ ៖ (១) *ការចេះដឹងអំពីសេចក្តីពិត*ដែលអាចត្រូវបានយល់ថា ជាទីបន្ទាល់មួយ និង (២) *បានប្រែចិត្តជឿចំពោះព្រះអម្ចាស់*ដែលខ្ញុំយល់ថា ជាការប្រែចិត្តជឿចំពោះព្រះអង្គសង្គ្រោះ និងដំណឹងល្អទ្រង់ ។ ហេតុនោះហើយការរួមផ្សំដ៏មានអំណាចនេះគឺទាំងទីបន្ទាល់ និងការប្រែចិត្តជឿដល់ព្រះអម្ចាស់បានបង្កើតនូវភាពរឹងប៉ឹង និងភាពខ្ជាប់ខ្ជួន ហើយផ្តល់នូវការការពារខាងវិញ្ញាណ ។

ទីបន្ទាល់ជាការចេះដឹងខាងវិញ្ញាណពីសេចក្តីពិតដែលទទួលបានតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ ការប្រែចិត្តជឿបន្តជាប់ជានិច្ចជាកក្តីភាពដ៏ខ្ជាប់ខ្ជួនដល់សេចក្តីពិតដែលបានបើកសម្តែងដែលយើងបានទទួល—ជាមួយនឹងដួងចិត្តដែលស្ម័គ្រ និងសម្រាប់ហេតុផលសុចរិត ។ ការដឹងថា ដំណឹងល្អជាការពិត វាសំខាន់ដើម្បីមានទីបន្ទាល់ ។ ការនៅពិតត្រង់ដ៏ខ្ជាប់ខ្ជួនចំពោះដំណឹងល្អ គឺជាការសំខាន់សម្រាប់ការផ្លាស់ប្រែចិត្តជឿ ។ យើងត្រូវដឹងថា ដំណឹងល្អគឺពិត ហើយពិតត្រង់ចំពោះដំណឹងល្អ ។

ការទុកចោលនូវ ‹ គ្រឿងសស្ត្រាវុធនៃការបះបោរ › ជាទីពេញចិត្ត ដូចជាភាពអាត្មានិយម ការឆ្មើងឆ្មៃ និង ការមិនគោរពប្រតិបត្តិ តម្រូវច្រើនជាងគ្រាន់តែការជឿ និង ការដឹង ។ ការជឿក៏ខ្លាំង ការបន្ទាបខ្លួន ការប្រែចិត្ត និង ការព្រមស្តាប់តាម ត្រូវមកមុនការទម្លាក់គ្រឿងសស្ត្រាវុធនៃការបះបោររបស់យើងចោល ។ តើអ្នក និងរូបខ្ញុំនៅតែជាម្ចាស់នៃគ្រឿងសស្ត្រាវុធ ដែលរារាំងមិនឲ្យយើងបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ដែលឬទេ ? បើដូច្នោះ នោះយើងត្រូវតែប្រែចិត្តឥឡូវនេះ ។

ខ្ញុំសន្យាថា ពេលយើងមានការចេះដឹងពីសេចក្តីពិត និងបានប្រែចិត្តជឿដល់ព្រះអម្ចាស់ នោះយើងនឹងនៅរឹងប៉ឹង និងខ្ជាប់ខ្ជួន និងមិនដែលធ្លាក់ឡើយ ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ ២០១២ ។*

រចនារូបភាពដោយ ហ្គេល អាមស្រង និង ខាធី ដុកគ្រីល

# អាមូលេក និង អាលម៉ា



ពួកលោកគឺជាដៃគូ
**អ្នកផ្សព្វផ្សាយសាសនាដ៏មានអានុភាព**
ដែលបានបង្រៀនដំណឹងល្អទៅដល់មនុស្សជាច្រើន ។



ព្រះប្រទានអំណាចដល់ពួកលោក ដូច្នេះពួកលោក
**មិនអាចត្រូវគេសម្លាប់**
ឬត្រូវគេដាក់គុកឡើយ ។



អាមូលេកបានប្រែចិត្តជឿបន្ទាប់ពីទេវតាមួយអង្គបានប្រាប់លោកឲ្យ
**ទទួលព្យាការីម្នាក់**
( អាលម៉ា ) ចូលទៅក្នុងផ្ទះលោក ។





អាលម៉ាបានប្រៀបធៀប
**សេចក្ដីជំនឿលើព្រះបន្ទូលនៃព្រះ**
ទៅនឹងការដាំគ្រាប់ពូជមួយដែលនឹងដុះលូតលាស់ឡើងកាលដែលយើងថែទាំវា ។



អាលម៉ាបានប្រែចិត្តជឿបន្ទាប់ពីទេវតាមួយអង្គបានប្រាប់លោកឲ្យ
**ឈប់បំផ្លាញ**
សាសនាចក្ររបស់ព្រះ ។

## ព្រួយបារម្ភពីអនាគត ?

*ដោយប្រឈមនឹងភាពមិនច្បាស់លាស់ យុវមជ្ឈិមវ័យចែកចាយពីអ្វីដែលពួកគេបានធ្វើដើម្បីទុកចិត្តលើព្រះ ហើយរៀបចំសម្រាប់ពេលអនាគត ។*

៤៤




យុវវ័យ

**គ្រួសាររបស់ខ្ញុំមិនមែនជាគ្រួសាររីករាយមួយទេ—រហូតដល់ពេលដែលខ្ញុំបានចូលព្រះវិហារ**

៥៤

មេរៀនដែលប្រើសម្ភារ

**ដុំថ្ម និងអាទិភាព**

៦០

ឪពុកម្ដាយ

**ជួយកូនៗឲ្យយល់ថារូបកាយរបស់យើងជាព្រះវិហារបរិសុទ្ធ**

៨៤


សាសនាចក្រនៃ
**ព្រះយេស៊ូវគ្រីស្ទ**
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02167 22258 3

# ប្រិយមិត្ត

ខែ កក្កដា ឆ្នាំ ២០២០

វគ្គរបស់កុមារនៅក្នុងទស្សនាវដ្ដី *លីអាហូណា* ដែលបោះពុម្ពដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



**អាលម៉ា**
បានក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏ឆ្នើមម្នាក់ !
ទំព័រ ៩២០–៩២៣

មកពីគណៈប្រធានទីមួយ



ដោយប្រធាន ដាល្លិន អេក អូក
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# ការធ្វើតាម ពួកអ្នកត្រួសត្រាយ



មានម្ដងនោះខ្ញុំបានដើរតាមផ្លូវមួយចំនួនដែលពួកអ្នកត្រួសត្រាយផ្លូវជំនាន់ដើមបានដើរទៅជ្រលងសលត៍លេក ។ ខ្ញុំមានអារម្មណ៍រាបទាបណាស់ដែលបានដើរនៅកន្លែងដែលពួកអ្នកត្រួសត្រាយផ្លូវបានដើរ ។ ប៉ុន្តែការដើរនៅកន្លែងដែលពួកគេដើរមិនសូវជាសំខាន់ដូចជាការរស់នៅដូចជាពួកគេបានរស់នៅនោះទេ ។

ពួកអ្នកត្រួសត្រាយផ្លូវបានបោះជំហានទៅមុខដោយសេចក្ដីជំនឿនៅក្នុងសាសនាថ្មីមួយ ដែនដីថ្មីមួយ និងរបៀបថ្មីក្នុងការធ្វើអ្វីៗទាំងឡាយ ។ ពួកគេបានទុកចិត្តលើព្រះ ។ យើងត្រូវការ**សេចក្ដីជំនឿ**ផងដែរ ។

ពួកគេបានធ្វើតាមអ្វីដែលថ្នាក់ដឹកនាំបានសូមឲ្យពួកគេធ្វើ ។ យើងត្រូវតែ**គោរពប្រតិបត្តិ**ផងដែរ ។

ពួកគេបានប្រើប្រាស់ទេពកោសល្យរបស់ពួកគេ ហើយបានធ្វើការរួមគ្នាដើម្បីស្ថាបនាក្រុងស៊ីយ៉ូន ។ យើងត្រូវ**សាមគ្គីគ្នា**ផងដែរ ។

ពួកគេពុំបានទុកនរណាម្នាក់ចោលឡើយ ។ ពួកគេបានធ្វើឲ្យប្រាកដថារួមបញ្ចូលពួកអ្នកដែលកំពុងមានការលំបាកតាមផ្លូវ ។ យើងត្រូវតែ**រាប់បញ្ចូល**ផងដែរ ។

យើងអាចគោរពដល់ពួកអ្នកត្រួសត្រាយផ្លូវដោយការធ្វើតាមគំរូរបស់ពួកគេ ។●

*កែសម្រួលមកពី « Following the Pioneers »* Ensign *ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៧២–៧៤ ។*

# ខ្ញុំអាចធ្វើជាអ្នកត្រួសត្រាយផ្លូវម្នាក់

នរណាក៏ដោយដែលដឹកនាំផ្លូវនៅក្នុងការជួយធ្វើជីវិតកាន់តែប្រសើរសម្រាប់គ្រួសារខ្លួនគឺជាអ្នកត្រួសត្រាយផ្លូវម្នាក់ ។ សូមស្វែងរកផ្លូវរបស់អ្នកដោយឆ្លងកាត់ផ្លូវដែលខ្វាត់ខ្វែងនេះ ។ អ្នកអាចជាអ្នកត្រួសត្រាយផ្លូវម្នាក់ ដោយឆ្លងកាត់ផ្លូវទាំងនេះ . . .




រចនារូបភាពដោយ អ៊ែដាម គូហ្វ៊ដ

# ជម្រើសរបស់លីឡា

## លីឡាចង់ជ្រើសរើសត្រូវ ។



**ដោយ ខប៉ូឡាញណា ម៉ារីន**
( ផ្អែកទៅលើដំណើររឿងពិត )

« *ព្រះបានប្រទានវិហារឲ្យខ្ញុំ* » ( សៀវភៅចម្រៀងកុមារ *ទំព័រ ៧៣* ) ។

« ដល់ពេលអានព្រះគម្ពីរហើយ ! » លីឡាបាននិយាយ ។ លីឡាចូលចិត្តអានឲ្យអានីកាជាប្អូនស្រីនាង និងស្វេថានជាប្អូនប្រុសនាងស្ដាប់ ។ មិនយូរទៀតទេលីឡានឹងទទួលបុណ្យជ្រមុជទឹក ! ដើម្បីត្រៀមខ្លួនជាស្រេច នាងចង់អានព្រះគម្ពីរជារៀងរាល់ថ្ងៃ ។

លីឡាបានបើកសៀវភៅរឿងព្រះគម្ពីរទៅទំព័រទីមួយ ។ អានីកា និងស្វេថានបានខិតមកជិតដើម្បីពួកគេអាចមើលឃើញរូបភាព ។

លីឡាបាននិយាយថា « ចូរស្ដាប់ដោយប្រុងប្រយ័ត្ន ព្រោះបងនឹងសួរសំណួរដល់ប្អូនៗបន្ទាប់ពីអានហើយ » ។ បន្ទាប់មកនាងបានចាប់ផ្ដើមអានជំពូកទីមួយ ។

លីឡាបានអានថា « មុនពេលយើងកើតមក យើងបានរស់នៅឯស្ថានសួគ៌ » ។ « យើងពុំទាន់មានរូបកាយនៅឡើយទេ ។ យើងគឺជាវិញ្ញាណ » ។

លីឡា អានីកា និងស្វេថាន បានមើលទៅរូបភាពដែលមានមនុស្សស្លៀកពាក់ពណ៌ស ។

« ត្រៀមសម្រាប់សំណួរទីមួយហើយឬនៅ ? » លីឡាបានងាកទៅអានីកា ។ « តើប្អូនបានមកពីណាមុនប្អូនកើតមក ? »

អានីកាបានទះដៃនាង ។ « ស្ថានសួគ៌ ! »

លីឡាបាននិយាយថា « ត្រឹមត្រូវហើយ » ។ « ហើយតើស្វេថានបានមកពីណាដែរ ? »

អានីកាបាននិយាយថា « គាត់បានមកពីស្ថានសួគ៌ផងដែរ » ។ ស្វេថានបានសើចកក្អឹក ហើយបានដាក់ដៃចូលមាត់គាត់ ។ លីឡា និងអានីកាបានសើច ។ ស្វេថានគឺជាក្មេងអាយុមួយឆ្នាំដែលគួរឲ្យស្រឡាញ់បំផុតនៅក្នុងប្រទេសអាហ្សង់ទីន !

លីឡាបាននិយាយថា « គ្រួសារយើងទាំងមូលបានមកពីស្ថានសួគ៌ » ។ « ព្រះយេស៊ូវផងដែរ ។ ទ្រង់បានយាងមកដើម្បីជួយយើង ដើម្បីយើងអាចរស់នៅជាមួយព្រះវរបិតាសួគ៌ម្ដងទៀត » ។ លីឡាបានចង្អុលទៅរូបភាពព្រះយេស៊ូវនៅក្នុងទំព័រនោះ ។

បន្ទាប់ពីនាងបានអានចប់ហើយ លីឡាបន្តគិតថាវាមានសភាពបែបណាដើម្បីរស់នៅជាមួយព្រះយេស៊ូវនៅក្នុងស្ថានសួគ៌នោះ ។ នាងចង់ក្លាយដូចជាទ្រង់ ។ នាងចង់ជ្រើសរើសត្រូវជានិច្ច !

នៅថ្ងៃបន្ទាប់នៅសាលារៀន លីឡាកូរពោះពេលនាងឈរក្នុងជួររង់ចាំអាហារពេលព្រឹក ។ នាងស្ទើរតែអាចភ្លក់រសជាតិនំអិមផាញ៉ាដាសបាន ពេលដែល Señora Ruiz បានដាក់វាក្នុងចាននាង ។ វាឈ្ងុយខ្លាំងណាស់ !

បន្ទាប់មក Señora Ruiz បានចាក់ទឹកដោះគោមួយកែវឲ្យលីឡា ។



លីឡាបានគិត *អូ* ។ ទឹកដោះគោមើលទៅមានពណ៌ក្រមៅជាងសព្វដង ។ ជួនកាលសាលានាងបានថែមកាហ្វេ ឬតែទៅក្នុងភេសជ្ជៈ ។

« តើមានកាហ្វេ ឬតែនៅក្នុងទឹកដោះគោទេថ្ងៃនេះ ? » លីឡាបានសួរ ។

Señora Ruiz បានគ្រវីដៃគាត់ ។ គាត់បាននិយាយថា « មានកាហ្វេបន្តិច » ។ « ក្មួយនឹងមិនអាចដឹងរស់ជាតិវាផង » ។

លីឡាបានគិតបន្តិច ។ នាងចងចាំថានាងចង់ក្លាយដូចជាព្រះយេស៊ូវ ហើយជ្រើសរើសត្រូវ ។ នាងបានដឹងថា ការផឹកកាហ្វេជាអ្វីដែលពួកព្យាការីបានប្រាប់ថាមិនឲ្យធ្វើ ។

លីឡាបាននិយាយថា « ទេ អរគុណហើយ ។ ខ្ញុំនឹងមិនញ៉ាំទឹកដោះគោទេថ្ងៃនេះ » ។ នាងបានញញឹមដាក់ Señora Ruiz ។ បន្ទាប់មកនាងបានអង្គុយចុះដើម្បីញ៉ាំ ។

នៅយប់នោះ លីឡាបានជួយ Papi លាងចាននៅក្នុងផ្ទះបាយ ។ នាងនៅតែគិតអំពីរឿងក្នុងព្រះគម្ពីរ ។ នាងក៏បានគិតអំពីទឹកដោះគោផងដែរ ។

« Papi ? »

« បាទ ! » Papi បានតប ។

« ហេតុអ្វីព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងមានរូបកាយ ? »

Papi បានគិតពេលគាត់លាងចានមួយទៀត ។ គាត់បាននិយាយថា « មែនហើយ ទ្រង់ប្រទានរូបកាយដល់យើង ដើម្បីយើងអាចក្លាយដូចជាទ្រង់ » ។ « រូបកាយរបស់កូនជាផ្ទះសម្រាប់វិញ្ញាណកូន ។ នោះជាអត្ថន័យរបស់វាពេលយើងនិយាយថា រូបកាយយើងជាព្រះវិហារបរិសុទ្ធ » ។

លីឡាបានងក់ក្បាល ។ នាងបានច្រៀងចម្រៀងមួយអំពីរឿងនោះនៅក្នុងថ្នាក់កុមារនាពេលខ្លះ ! « ដូច្នេះហើយបានជាព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យយើងថែរក្សារូបកាយរបស់យើង មែនទេ ? »

Papi បានតបថា « មែនហើយ » ។

លីឡាបាននិយាយថា « ថ្ងៃនេះនៅឯសាលា គេបានដាក់កាហ្វេនៅក្នុងទឹកដោះគោ ។ « ខ្ញុំអត់បានផឹកវាទេ ។ ខ្ញុំព្យាយាមដើម្បីថែទាំព្រះវិហារបរិសុទ្ធរបស់ខ្ញុំ » ។

Papi បាននិយាយថា « ប៉ាមានមោទនភាពចំពោះកូនណាស់ » ។ គាត់ជូតដៃគាត់នឹងកន្សែង ហើយបានឱបលីឡា ។

លីឡាបានឱប Papi យ៉ាងណែន ។ នាងសប្បាយចិត្តដែលបានថែរក្សារូបកាយដែលព្រះវរបិតាសួគ៌បានប្រទានដល់នាង ។ ●

*អ្នកនិពន្ធរស់នៅទីក្រុងកូរីនទេស ប្រទេសអាហ្សង់ទីន ។*

គ្រួសារនៅក្នុងរឿងនេះរស់នៅប្រទេសអាហ្សង់ទីន ។ សូមអានអត្ថបទបន្ទាប់ទៀតដើម្បីរៀនបន្ថែមអំពីប្រទេសនេះ ។



រចនារូបភាពដោយ អាលេស្សា ហ្គីរ៉ាសូលេ



# សួស្តីមកពីប្រទេសអាហ្សង់ទីន !








**ប្រទេសអាហ្សង់ទីន** គឺជាប្រទេសមួយនៅទ្វីបអាមេរិកខាងត្បូង ។ វាមានបណ្តោយប្រវែង ៣២១៩ គីឡូម៉ែត្រ ។ នៅភាគខាងជើង វាក្តៅខ្លាំងណាស់អំឡុងរដូវក្តៅ ។ នៅភាគខាងត្បូង មានផ្ទាំងទឹកកកពេញមួយឆ្នាំ !



*នំអិមផាញ៉ាដាស* ជាម្ហូបដ៏ល្បីនៅក្នុងប្រទេសអាហ្សង់ទីន ។ វាធ្វើឡើងពីម្សៅស្រោបសាច់គោ ពោត ឬផ្លែឈើ ។ឆ្ងាញ់ណាស់ !



ក្មេងឃ្វាលគោត្រូវគេហៅថា *gauchos* នៅក្នុងប្រទេសអាហ្សង់ទីន ។ ពួកគេចិញ្ចឹមគោក្របី និងសេះ ។

មានសត្វដ៏គួរឲ្យចាប់អារម្មណ៍ជាច្រើននៅក្នុងប្រទេសអាហ្សង់ទីន—ខ្លាដំបង សត្វត្មាត និងសត្វភេនឃ្វីន !





មនុស្សជាច្រើនទិញម្ហូបពីផ្សារខាងក្រៅ ។ ក្មេងប្រុសនេះកំពុងជួយឪពុកគាត់កាន់ *sandía* ឬឪឡឹក ។



អ៊ុស្វៃអេ ជាទីក្រុងមួយដែលនៅជិតបំផុតទៅនឹងប៉ូលខាងត្បូងនៃពិភពលោកនេះ ! មានវួដចំនួនបីនៅក្នុងទីក្រុងនោះ ។





ក្មេងស្រីនេះបានទៅព្រះវិហារបរិសុទ្ធខូដូបាអាហ្សង់ទីន នៅថ្ងៃដែលវាត្រូវបានឧទ្ទិសឆ្លង ។ មិនយូរទៀតទេប្រទេសអាហ្សង់ទីននឹងមានព្រះវិហារបរិសុទ្ធបី !



## សូមជួបជាមួយមិត្តភក្តិមួយចំនួនរបស់យើងមកពីប្រទេសអាហ្សង់ទីន !



ពេលប្រធាន រ័សុល អិម ណិលសុន បានបង្ហាញពីកម្មវិធីថ្មីអំពីគោលដៅសម្រាប់កុមារ និងយុវវ័យ ខ្ញុំបានដាក់គោលដៅដើម្បីរត់ ធ្វើជាមិត្តល្អម្នាក់ ហើយធ្វើឲ្យការអធិស្ឋានរបស់ខ្ញុំបានប្រសើរឡើង ។ ខ្ញុំបានចែកចាយទីបន្ទាល់របស់ខ្ញុំនៅក្នុងការប្រជុំសាក្រាម៉ង់ថា ខ្ញុំដឹងថា ប្រសិនបើខ្ញុំធ្វើតាមកម្មវិធីនេះ ព្រះវរបិតាសួគ៌នឹងជួយខ្ញុំ ។

**ហ្គុនហ្សាឡូ អិល. អាយុ ៧ ឆ្នាំ ទីក្រុងប៊ូណូស អ៊ែរ៉េស ប្រទេសអាហ្សង់ទីន**



ពេលយើងអានព្រះគម្ពីរ យើងរៀនអំពីព្រះយេស៊ូវគ្រីស្ទ និងថាទ្រង់ស្រឡាញ់យើងយ៉ាងណា ។ វាធ្វើឲ្យខ្ញុំសប្បាយរីករាយ ។ ខ្ញុំដឹងថាទ្រង់ស្រឡាញ់ខ្ញុំ ។

**អិមម៉ា អាយុ ៥ ឆ្នាំ ទីក្រុង ប៊ូណូស អ៊ែរ៉េស ប្រទេសអាហ្សង់ទីន**

**តើប្អូនមកពីប្រទេសអាហ្សង់ទីនឬ ? សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូនៗ ។**








# រទេះនំប៉័ងតូច

ដោយ ហ្គេល ពិនទី-ខូនៃលីស
( ផ្អែកទៅលើដំណើររឿងពិត )

« *កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ* » ( *ម៉ូសាយ ២:១៧* ) ។

សើមមីបានបើកភ្នែក ហើយស្វាប ។ គាត់អាចធុំក្លិនអ្វីមួយឈ្ងុយឆ្ងាញ់ ។

*អូ ប៉ាប៉ាកំពុងធ្វើនំប៉័ង !* សើមមីបានគិត ។

ប៉ាប៉ាដុតនំប៉័ងសម្រាប់គ្រួសារជារៀងរាល់ថ្ងៃសៅរ៍ ។ សើមមីចូលចិត្តមើលគាត់យកនំប៉័ងពណ៌ត្នោតដ៏ស្រួយចេញពីចង្ក្រានដុតនំ ។ ប៉ាប៉ាតែងតែឲ្យចំណិតដំបូងទៅសើមមី ។

សើមមីបានគិត *ប៉ុន្តែថ្ងៃនេះមិនមែនជាថ្ងៃសៅរ៍ទេ ។ ហេតុអ្វីប៉ាប៉ាដុតនំ ?*

សើមមីបានក្រោកចេញពីគ្រែ ហើយបានទៅផ្ទះបាយ ។ គាត់បានសួរប៉ាប៉ាថាកំពុងធ្វើអ្វី ។

« តើកូនចាំទេថាប៊ីស្សពរបស់យើងបានសូមឲ្យយើងធ្វើអ្វី ? » ប៉ាប៉ាបានសួរ ។

សើមមីបានងក់ក្បាល ។ « គាត់បានសូមឲ្យពួកយើងជួយដល់មនុស្ស ។ ហើយកូនបានជួយបងស្រីម៉ាទីនយកឥវ៉ាន់គាត់ទៅលើចាំទេ ? »



ប៉ាប៉ាបានតបថា « កូនធ្វើបានល្អណាស់ » ។ « ប៉ាបានអធិស្ឋានដើម្បីដឹងពីរបៀបដែលប៉ាអាចជួយ ។ ប៉ាបានមានគំនិតមួយ គឺដុតនំដើម្បីចែកចាយ » ។

សើមមីបានមើលតាមកញ្ចក់ចង្ក្រានដុតនំ ។ គាត់បានរាប់ថាមាននំប៉័ងប៉ុន្មាន ។

« មួយ . . . ពីរ . . . បី . . . បួន ។ តើប៉ាប៉ានឹងឲ្យនំប៉័ងដល់នរណាខ្លះ ? »

ប៉ាប៉ាបាននិយាយថា « នោះជាអ្វីដែលប៉ាត្រូវការជំនួយពីកូន » ។ « នំប៉័ងមួយគឺសម្រាប់ស៊ីស្ទើរម៉ាទីន ។ ហើយពីរសម្រាប់គ្រួសារមីលល័រ ។ តើយើងគួរឲ្យនំប៉័ងទីបួនដល់នរណា ? »

សើមមីបានគិតអំពីវា ។

« ចុះលោកលីវិញនោះ ? » សើមមីបានសួរ ។ លោកលីរស់នៅក្នុងអគារផ្ទះល្វែងរបស់ពួកគេដែរ ។ គាត់ពុំចេញទៅក្រៅញឹកញាប់ទេ ។ ភាគច្រើនគាត់គ្រាន់តែសម្លឹងមើលមនុស្សម្នាពីបង្អួចរបស់គាត់ ។

ប៉ាប៉ាបានតបថា « នោះជាយោបល់ល្អណាស់! »

បន្ទាប់ពីនំប៉័ងឆ្អិនហើយ សើមមីបានជួយប៉ាប៉ាខ្ចប់នំប៉័ង ។ បន្ទាប់មកគាត់បានទៅយករទេះរបស់គាត់ ។ ពួកគេបានដាក់នំប៉័ងនៅក្នុងរទេះ ។

« រទេះនំប៉័ងរួចរាល់ដើម្បីចេញដំណើរហើយ ! » សើមមីបាននិយាយ ។

ប៉ាប៉ាបានជួយសើមមីទាញរទេះ ។ ដួងចិត្តរបស់សើមមីមានអារម្មណ៍ល្អ និងកក់ក្ដៅ គឺដូចជានំប៉័ងដែលពួកគេបម្រុងនឹងចែកចាយអញ្ចឹង ។●

*អ្នកនិពន្ធរស់នៅរដ្ឋវើម៉ុន្ត ស.រ.អា. ។*

រូបគំនូរដោយ ចេស ហ៊ុប



# ខុសគ្នា តែជាមួយគ្នា

ដោយ បេថានី បាស្សូឡូម៉ូ
( ផ្អែកទៅលើដំណើររឿងពិត )

*« សូមបណ្តោយឲ្យមនុស្សទាំងអស់មានសិទ្ធិដូចគ្នា ចូរឲ្យគេថ្វាយបង្គំតាមរបៀបណា នៅទីណា ឬអ្វីក៏ដោយដែលគេប្រាថ្នា » ( មាត្រានៃសេចក្តីជំនឿ ១:១១ ) ។*

អែលលី និងគ្រួសារនាងនឹងទៅលេងបងប្អូនជីដូនមួយរបស់ពួកគេដែលរស់នៅឆ្ងាយ ។ អែលលីរំភើបខ្លាំងណាស់ ! នាងពុំបានជួបបងប្អូនជីដូនមួយរបស់នាងជាយូរមកហើយ ។

មុនពេលធ្វើដំណើរ ប៉ាម៉ាក់របស់អែលលីបាននិយាយថា ពួកគាត់ចង់និយាយអំពីអ្វីមួយ ។

« ពេលយើងជួបជុំគ្នាជាមួយគ្រួសារ យើងតែងតែអធិស្ឋាននៅពេលញ៉ាំអាហារ ។ ហើយពេលខ្លះយើងនិយាយអំពីព្រះវិហារ មែនទេ ? » ប៉ាបានសួរ ។

« ត្រូវហើយ ! » អែលលីបានតប ។

ម៉ាក់បាននិយាយថា « មែនហើយ អ្វីៗនឹងខុសគ្នាបន្តិចក្នុងការជួបជុំនេះ » ។ « មីង និងពូរបស់កូនមិនទៅព្រះវិហារទៀតទេ ។ ហើយពួកគេមិនចូលចិត្តទេពេលមនុស្សនិយាយអំពីវា » ។

អែលលីបានជ្រួញចិញ្ចើម ។ « ហេតុអ្វី ? »

ប៉ាបាននិយាយថា « យើងពុំដឹងរាល់ហេតុផលនោះទេ » ។ « ប៉ុន្តែពួកគេស្រឡាញ់យើងខ្លាំងណាស់ ។ ប៉ាគិតថាពួកគេមិនចង់ប្រកែកនឹងយើង ឬធ្វើ ឲ្យប៉ះពាល់អារម្មណ៍យើង ទេ ។ ដូច្នេះពួកគេបានសូមយើងមិនឲ្យនិយាយអំពីរឿងព្រះវិហារជាមួយពួកគេទេ » ។

អែលលីបានងក់ក្បាល ។

ម៉ាក់បាននិយាយថា « យើងនៅតែអាចអានព្រះគម្ពីររបស់យើង ហើយអធិស្ឋានពេលយើងនៅទីនោះ ។ ប៉ុន្តែយើងនឹងធ្វើវាដោយខ្លួនយើង » ។



« ពួកយើងខ្លះនឹងទៅហាងរបស់បងជីដូនមួយក្មួយនៅថ្ងៃនេះ ។ ក្មួយចង់ទៅទេ ? » មីងបានសួរអែលលី ។

« ហាងធ្វើសក់ ? » អែលលីបានសួរ ។

« មែនហើយ ! ក្មួយ និងបងស្រីក្មួយអាចធ្វើសក់បានបើក្មួយចង់ » ។

អែលលីបានញញឹម ហើយងក់ក្បាល ។ ស្តាប់ទៅសប្បាយណាស់ !

បន្ទាប់ពីអាហារពេលព្រឹក ពួកគេបានជិះឡានក្រុងទៅហាងធ្វើសក់ ។ អែលលីចូលចិត្តមើលបងជីដូនមួយនាងធ្វើការ ។ ដៃរបស់គាត់អូសទៅមកៗ ពេលគាត់សិត និងក្រងសក់ ។ បន្ទាប់ពីគ្រប់គ្នាបានធ្វើសក់ហើយ ពួកគេបានលេងធ្វើជា អ្នកបង្ហាញម៉ូតនៅមុខកញ្ចក់ហាង ហើយសើចកក្អឹកនឹងម៉ូតសក់ថ្មីរបស់ពួកគេ ។

នៅថ្ងៃបន្ទាប់ មានភ្លៀងធ្លាក់យ៉ាងខ្លាំង ។ ដូច្នេះ គ្រប់គ្នាបានសម្រេចចិត្តនៅផ្ទះ ហើយលេងល្បែងនានា ។ អែលលី និងប្អូនជីដូនមួយរបស់នាងម្នាក់នៅក្រុមជាមួយគ្នា ហើយលេងទល់នឹងក្មេងប្រុសដែលធំជាងពួកគេ ។ ពួកគេលគ្នាទៅវិញទៅមកលេងសើចនឹងគ្នាកាលដែលពួកគេប្រកួតល្បែងនោះ ។

« យើងឈ្នះហើយ ! » អែលលីបានស្រែកពេលដែលនាងបានរំកិលដុំល្បែងនោះទៅដល់ទីបញ្ចប់បន្ទះល្បែង ។ ពួកគេបានលើកដៃទះអបអរគ្នាទៅវិញទៅមក—សូម្បីតែបងជីដូនមួយដែលធំជាងបានធ្វើពុតជាខឹងដោយសារចាញ់ ។

« ចុះពេលយើងញ៉ាំអាហារនោះ ? » បងស្រីរបស់អែលលីបានសួរ ។

ម៉ាក់បាននិយាយថា « ចាំមើលសិន » ។ « បើពួកគេមិនអធិស្ឋានមុនយើងញ៉ាំអាហារទេ យើងអាចអធិស្ឋានក្នុងចិត្តយើងម្នាក់ៗ » ។

អែលលីបាននិយាយថា « យល់ព្រម » ។ « កូនអាចធ្វើវាបាន ! »

នៅថ្ងៃបន្ទាប់ គ្រួសាររបស់អែលលីទាំងអស់គ្នាចូលក្នុងឡាន ។ ពួកគេបានបើកឡានរហូតដល់យប់ជ្រៅ ។ នៅទីបំផុត ពេលពួកគេបានទៅដល់ផ្ទះបងប្អូនជីដូនមួយរបស់ពួកគេ មីង និងពូរបស់អែលលីបានជួយពួកគេយកកាបូបរបស់ពួកគេចេញពីឡាន ។ បន្ទាប់មកគ្រប់គ្នាបានចូលគេង ។

ពេលព្រឹកឡើង អែលលីបានអធិស្ឋានមុននឹងទៅផ្ទះបាយដើម្បីញ៉ាំអាហារពេលព្រឹក ។ នាងមានអារម្មណ៍ភ័យបន្តិចក្នុងការជួបគ្រួសារនាង ។ ប៉ុន្តែបន្ទាប់មកមីងរបស់នាងបានអង្គុយចុះក្បែរនាងដោយស្នាមញញឹមដ៏កក់ក្ដៅ ។

ពីរបីថ្ងៃក្រោយមក វាដល់ពេលត្រឡប់ទៅផ្ទះវិញហើយ ។ ពេលអែលលីបានឡើងទៅខាងក្រោយឡានរបស់គ្រួសារនាង នាងបានឮគ្រួសារនាងនិយាយលាគ្នា ។

« យើងប្រាកដជានឹកពួកឯង ! »

« ត្រឡប់មកវិញឆាប់ៗណា ! »

« ពួកយើងស្រឡាញ់ពួកឯងខ្លាំងណាស់ ! »

អែលលីបានញញឹម ហើយគ្រវីដៃលាពេលដែលឡានបានបើកចេញទៅ ។ នាងសប្បាយណាស់ ។ សូម្បីតែពួកគេជឿរឿងខុសគ្នាមែន តែពួកគេនៅតែអាចជាគ្រួសារដ៏រីករាយ ។●

*អ្នកនិពន្ធរស់នៅរដ្ឋចចចារ ស.រ.អា. ។*

*កាត់ចេញ ហើយបិតការ កិប ឬចងទំព័រទាំងអស់នេះជាមួយគ្នាដើម្បីធ្វើជាសៀវភៅមួយ !*




# សេចក្តីជំនឿដែលលូតលាស់របស់ខ្ញុំ

នាមៈ

១



នៅក្នុងព្រះគម្ពីរមរមន អាលម៉ាបានមានប្រសាសន៍
ថា សេចក្តីជំនឿគឺដូចជាគ្រាប់ពូជមួយ ។

៤



ខ្ញុំជួយឲ្យសេចក្តីជំនឿរបស់ខ្ញុំលើព្រះយេស៊ូវលូតលាស់
ដោយការអធិស្ឋាន និងមានចិត្តល្អចំពោះអ្នកដទៃទៀត ។

៥



កាលដែលដើមឈើមួយដុះឡើង វាអាច
ផ្តល់ជាផ្លែដ៏ផ្អែមដល់យើង ។

២



ខ្ញុំអាចដាំគ្រាប់ពូជនៃសេចក្ដីជំនឿរបស់ខ្ញុំ ដោយការ
ស្ដាប់ដល់អ្វីដែលព្យាការី និងព្រះគម្ពីរបង្រៀន ។

៣



គ្រាប់ពូជមួយត្រូវការទឹក និងពន្លឺថ្ងៃដើម្បី
ជួយឲ្យវាលូតលាស់ ។

៦



កាលដែលសេចក្ដីជំនឿរបស់ខ្ញុំលូតលាស់ឡើង វានឹង
នាំមកនូវពរជ័យដ៏ផ្អែមល្ហែមចូលក្នុងជីវិតខ្ញុំ ។

៧



ខ្ញុំនឹងបន្តជួយឲ្យសេចក្ដីជំនឿរបស់ខ្ញុំលូតលាស់រឹងមាំ ។
ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទស្រឡាញ់ខ្ញុំ !

រចនារូបភាពដោយ ប៉ាទ្រីកសៀ ដេអឺស



ដោយ ស៊ីស្ទើរ
គ្រីស្ទីណា បី ហ្វ្រានកូ
ទីប្រឹក្សាទីពីរក្នុងគណៈប្រធាន
អង្គការបឋមសិក្សាទូទៅ

# គ្រឿង ផ្សំសម្ងាត់






ព្រះវរបិតាមានព្រះទ័យចង់ឲ្យយើងបម្រើអ្នកដទៃ ។ គ្រូថ្នាក់កុមាររបស់ខ្ញុំជាគំរូដ៏អស្ចារ្យនៃការបម្រើ ។ ពេលយើងមកថ្នាក់កុមារ ស៊ីស្ទើរអែនថូនីតជីតែងតែយកនំសូកូឡាមក ។ ខ្ញុំស្អប់នំសូកូឡាណាស់ ។ គ្រប់គ្នាផ្សេងទៀតចូលចិត្តវា ។ ប៉ុន្តែខ្ញុំមិនដែលញ៉ាំវាទេ ។

ថ្ងៃមួយគាត់បានសួរខ្ញុំថា « ហេតុអ្វីប្អូនមិនភ្លក់នំនោះបន្តិចទៅ ? នំនេះធ្វើពីគ្រឿងផ្សំពិសេសមួយ ។

ខ្ញុំបានយល់ព្រមសាកល្បងវា ។ ហើយទាយមើលថាយ៉ាងម៉េចដែរ ? ខ្ញុំចូលចិត្តវា !

ច្រើនឆ្នាំក្រោយមក ម៉ាក់ខ្ញុំបានប្រាប់ខ្ញុំពីគ្រឿងផ្សំសម្ងាត់របស់ស៊ីស្ទើរអែនថូនីតជី ។ ម៉ាក់ខ្ញុំបាននិយាយថា « ស៊ីស្ទើរអែនថូនីតជីមិនមានប្រាក់ច្រើនទេ » ។ « រៀងរាល់សប្ដាហ៍ គាត់ត្រូវតែជ្រើសរើសរវាងការបង់សម្រាប់ឡានក្រុងដើម្បីទៅថ្នាក់កុមារ ឬទិញគ្រឿងផ្សំដើម្បីធ្វើនំសូកូឡាសម្រាប់ថ្នាក់កូន ។ គាត់តែងតែជ្រើសរើសធ្វើនំសូកូឡា ។ ដូច្នេះជំនួសឲ្យការជិះឡានក្រុង គាត់បានដើរអស់ចម្ងាយជាងប្រាំមួយគីឡូម៉ែត្រទាំងទៅទាំងមក ទោះមានអាកាសធាតុបែបណាក្ដី » ។

គ្រឿងផ្សំសម្ងាត់របស់ស៊ីស្ទើរអែនថូនីតជីគឺសេចក្ដីស្រឡាញ់ដែលគាត់មានចំពោះអ្នកដទៃ ។●

*កែសម្រួលមកពី « The Joy of Unselfish Service » Liahona ខែ វិច្ឆិកា ឆ្នាំ ២០១៨ ទំព័រ ៥៥–៥៧ ។*



រចនារូបភាពដោយ ហេកទ័រ បទ្បាស្កា



រចនារូបភាពដោយ មិដ មីលល័រ

# ខ្ញុំអាចធ្វើតាមព្រះយេស៊ូវគ្រីស្ទតាមរបៀបដ៏តូច និងសាមញ្ញ ។

( សូមមើល អាលម៉ា ៣៧:៦ ) ។

# ការហៅបម្រើបេសកកម្មដ៏ភ្ញាក់ផ្អើល



ដោយ លូស៊ី ស្ទីវ៉ែនសុន
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )



អែដវិន ដាម៉ារ៉ាជូ បានញញឹមកាលដែលគាត់បានដើរចេញពីព្រលានយន្តហោះ ហើយដើរចូលក្នុងពន្លឺព្រះអាទិត្យ ។ គាត់អាចឃើញដើមត្នោតជាជួរតាមផ្លូវ និងធុំក្លិនគ្រឿងទេសពីផ្សារនៅជិតនោះ ។ គាត់ និងភរិយាគាត់ អែលស៊ី បានត្រឡប់មកប្រទេសឥណ្ឌាវិញ ! ពួកគាត់បានរស់នៅក្នុងប្រទេសសាម័រ ប៉ុន្តែឥឡូវនេះពួកគាត់បានមកស្រុកកំណើតម្ដងទៀត ។

ទោះជាយ៉ាងណា អែឌវិន និងអែលស៊ី ពុំមែនមកទីនេះដើម្បីគ្រាន់តែមកលេងនោះទេ ។ ពួកគាត់ត្រូវបានហៅឲ្យបម្រើជាអ្នកផ្សព្វផ្សាយសាសនានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ អែដវិនមានអារម្មណ៍ភ័យបន្តិច ។ ប៉ុន្តែគាត់ដឹងថា ព្រះវរបិតាសួគ៌នឹងជួយពួកគាត់ ។ ព្រះវរបិតាសួគ៌បានជួយពួកគេជាច្រើនរួចមកហើយ ។

អែដវិន និងភរិយាគាត់ អែលស៊ី បានកើតនៅប្រទេសឥណ្ឌា ។ ប៉ុន្តែអែដវិនដំបូងឡើយបានឮពីសាសនាចក្រពេលកំពុងទៅរៀននៅសហរដ្ឋ ។ គាត់បានទៅព្រះវិហារនៅទីនោះម្ដង ។ គាត់បានទាំងអានព្រះគម្ពីរមរមនទៀតផង ។ ប៉ុន្តែពេលគាត់ត្រឡប់មកប្រទេសឥណ្ឌាវិញ គាត់បានភ្លេចពីព្រះវិហារ ។

ប៉ុន្មានឆ្នាំក្រោយមក អែដវិន និងអែលស៊ី បានមានអារម្មណ៍ថាពួកគាត់គួរតែប្ដូរទៅនៅប្រទេសសាម័រ ។ អែដវិនជាអ្នកវិទ្យាសាស្ត្រផ្នែកសត្វល្អិត ហើយគាត់បានទទួលការងារមួយនៅលើកោះនោះដោយធ្វើការស្រាវជ្រាវ ។ គឺនៅទីនោះហើយដែលអែដវិន និងអែលស៊ីបានជួបពួកអ្នកផ្សព្វផ្សាយសាសនា ។ ពេលអែដវិនបានអានព្រះគម្ពីរមរមនម្ដងទៀត គាត់បានទទួលអារម្មណ៍ដ៏ពិសេសមួយ ។ អែលស៊ីបានអានព្រះគម្ពីរមរមនផងដែរ ។ ពួកគាត់បានជ្រើសរើសដើម្បីទទួលពិធីបុណ្យជ្រមុជទឹក រួមទាំងកូនប្រុស និងកូនស្រីពួកគាត់ផង ។

បន្ទាប់ពីចូលព្រះវិហារហើយ អ្វីដែលអែដវិនចង់ធ្វើបំផុតគឺដើម្បីឲ្យគ្រួសារគាត់ដែលនៅប្រទេសឥណ្ឌាបានរៀនអំពីដំណឹងល្អ ។ បញ្ហានោះគឺថា ពុំមានអ្នកផ្សព្វផ្សាយសាសានានៅក្នុងប្រទេសឥណ្ឌាដើម្បីបង្រៀនពួកគេទេ ! អែដវិន និងអែលស៊ីបានសរសេរលិខិតទៅការិយាល័យកណ្ដាលរបស់សាសនាចក្រស្នើសូមឲ្យពួកលោកបញ្ជូនពួកអ្នកផ្សព្វផ្សាយសាសនាទៅប្រទេសឥណ្ឌា ។

អ្វីដែលកើតឡើងបន្ទាប់ទៀតគឺជាការភ្ញាក់ផ្អើលដ៏ធំ ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ ឃឹមបឹល បានហៅ*ពួកគាត់*ឲ្យទៅបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅក្នុងប្រទេសឥណ្ឌា !

ហើយឥឡូវនេះ ពួកគាត់បាននៅទីនេះ ។

កន្លែងដែលពួកគាត់បានឈប់មុនគេគឺផ្ទះបងប្រុសរបស់អែដវិន ។ ឪពុកម្ដាយ និងបងប្អូនរបស់អែដវិនបាននៅទីនោះផងដែរ ។ អែដវិន និងអែលស៊ីបានចាប់ផ្ដើមបង្រៀនពួកគេភ្លាម ។ គ្រួសាររបស់ពួកគាត់សប្បាយចិត្តដែលបានរៀនដំណឹងល្អ ។

ពីរបីសប្ដាហ៍ក្រោយមក អែដវិន និងគ្រួសារគាត់បានប្រមូលគ្នាជុំវិញអាងហែលទឹកនៅក្នុងទីធ្លាផ្ទះរបស់បងប្រុសគាត់ ។ អាងទឹកនោះត្រូវបានសម្អាតលាបពណ៌ និងបំពេញទឹកស្អាតពេញ ។ គ្រប់គ្នាស្លៀកពាក់ពណ៌ស ។ ស្ត្រីៗបានស្លៀកសារីបក់រំភើយដែលធ្លាក់ចុះពីស្មារបស់ពួកគេ ។ បុរសៗបានពាក់អាវឥណ្ឌារលុងៗ និងស្លៀកខោ ។

អែដវិនបានឈរនៅក្នុងអាងទឹកជាមួយឪពុកគាត់ ។ អែដវិនបាននិយាយថា « ដោយមានសិទ្ធិអំណាចដែលបានប្រទានដល់ខ្ញុំពីព្រះយេស៊ូវគ្រីស្ទ នោះខ្ញុំធ្វើបុណ្យជ្រមុជទឹកឲ្យអ្នក ដោយនូវព្រះនាមព្រះវរបិតា និងព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ » ។

អែដវិនបានទទួលអារម្មណ៍រីករាយពេលគាត់បានធ្វើបុណ្យជ្រមុជទឹកឲ្យឪពុកគាត់ ។ អែដវិនកាន់តែរីករាយខ្លាំងទៀតពេលគាត់បានធ្វើបុណ្យជ្រមុជទឹកឲ្យម្ដាយគាត់ ។ នៅចុងបញ្ចប់នៃថ្ងៃនោះ អែដវិនបានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្ស ១៨ នាក់ !

ថ្ងៃបន្ទាប់ទៀត អែដវិន និងអែលស៊ីបានជិះរត់ភ្លើងអស់ប្រាំមួយម៉ោង ។ ពួកគាត់បានទៅជួបសមាជិកគ្រួសារបន្ថែមទៀត ហើយបានបង្រៀនអំពីដំណឹងល្អ ។ អែដវិនបានធ្វើបុណ្យជ្រមុជទឹកដល់សាច់ញាតិបួននាក់បន្ថែមទៀតនៅស្ទឹងក្បែរនោះ ។

នៅទីបំផុត អែដវិន និងអែលស៊ីបានជិះរត់ភ្លើងចំនួន ១៦ ម៉ោង ដើម្បីទៅជួបឪពុកម្ដាយរបស់អែលស៊ី ។ ឪពុករបស់អែលស៊ីជាថ្នាក់ដឹកនាំម្នាក់នៅព្រះវិហារមួយផ្សេងទៀត ។ គាត់ពុំបានទទួលបុណ្យជ្រមុជទឹកទេ ប៉ុន្តែបានគិតថាព្រះគម្ពីរមរមនជាព្រះគម្ពីរដ៏ល្អមួយ ។ គាត់បានជួយបកប្រែព្រះគម្ពីរមរមនទៅជាភាសាថេគូលូ ជាភាសាមួយក្នុងចំណោមភាសាទាំងឡាយដែលនិយាយនៅក្នុងប្រទេសឥណ្ឌា ។

នៅពេលដែលអែដវិន និងអែលស៊ីបានបញ្ចប់បេសកកម្មរបស់ពួកគាត់ នោះមានសមាជិកគ្រប់គ្រាន់ដើម្បីចាប់ផ្ដើមសាខាដំបូងបំផុតមួយរបស់សាសនាចក្រនៅប្រទេសឥណ្ឌា ! អែដវិន និងអែលស៊ី សប្បាយចិត្តពេលពួកគាត់ត្រឡប់ទៅប្រទេសសាម័រវិញ ។ ពួកគាត់មានអំណរគុណដែលព្រះវរបិតាសួគ៌បានបញ្ជូនពួកគាត់ទៅបេសកកម្មមួយ ! ●



អែដវិន និងអែលស៊ី ដាម៉ារ៉ាជូ បានបម្រើបេសកកម្មរបស់ពួកគាត់នៅប្រទេសឥណ្ឌាក្នុងឆ្នាំ ១៩៧៨ ។ ឥឡូវនេះព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតមួយនឹងត្រូវបានសាងសង់ឡើងនៅទីនោះ !

ខ្ញុំមិនដែលបានធ្វើអ្វីដែលពិតជាអាក្រក់នោះទេ ។
តើខ្ញុំនៅតែត្រូវការការប្រែចិត្តទេ ?
—អ្នកមិនច្បាស់លាស់នៅក្នុងទីក្រុងយូឌិន

## ជូនចំពោះអ្នកមិនច្បាស់លាស់

មនុស្សគ្រប់គ្នាត្រូវការការប្រែចិត្ត ដោយសារគ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ ! ការប្រែចិត្តអាចជាការសាមញ្ញដូចជាការអធិស្ឋានទៅព្រះវរបិតាសួគ៌អំពីថាតើអ្នកមានសុខទុក្ខយ៉ាងណានៅថ្ងៃនេះ ហើយទូលប្រាប់ទ្រង់ថាតើអ្នកចង់ធ្វើឲ្យថ្ងៃស្អែកបានប្រសើរឡើងយ៉ាងដូចម្ដេច ។ យើងទូលសូមការអភ័យទោសពីទ្រង់ ពេលយើងធ្វើអ្វីមួយខុស ហើយទ្រង់អត់ទោសដល់យើង ។ មនុស្សខ្លះគិតថាការប្រែចិត្តជារឿងគួរឲ្យភ័យខ្លាច ។ ប៉ុន្តែវាជារឿងដ៏រីករាយមួយ ! ការប្រែចិត្តគឺជាអំណោយដែលព្រះយេស៊ូវគ្រីស្ទប្រទានដល់យើង ដើម្បីយើងអាចរៀន លូតលាស់ ផ្លាស់ប្ដូរ ហើយក្លាយកាន់តែដូចទ្រង់ ។ ប្រធានណិលសុនមានប្រសាសន៍ថា យើងគួរតែប្រែចិត្តជារៀងរាល់ថ្ងៃ ។ ពេលបងប្អូនធ្វើដូច្នោះ បងប្អូននឹងមានអារម្មណ៍នៃភាពសុខសាន្ត និងអំណាចកាន់តែខ្លាំងនៅក្នុងជីវិតបងប្អូន ។

ដោយក្ដីស្រឡាញ់

ទស្សនាវដ្ដី *ប្រិយមិត្ត*

**សាកល្បងវា !**

ដូចជាស្លាបព្រាបានយកម្រេចចេញនៅក្នុងសកម្មភាពនេះ ការប្រែចិត្តអាចធ្វើឲ្យយើងស្អាតស្អំពីជម្រើសខុសឆ្គងដែលយើងបានធ្វើជារៀងរាល់ថ្ងៃ—ទោះតូច ឬធំ ។ ដោយសារព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ យើងទាំងអស់គ្នាមានឱកាសដើម្បីប្រែចិត្ត ។

**បងប្អូននឹងត្រូវការនូវ ៖**

អំបិល
ម្រេចខ្មៅ
ស្លាបព្រាផ្លាស្ទិច
កន្សែង



១. ចាក់អំបិលខ្លះចូលក្នុងចានមួយ ។ ការណ៍នេះតំណាងឲ្យរបៀបដែលយើងបរិសុទ្ធ ហើយស្អាតស្អំមុននឹងយើងធ្វើអំពើបាប ។

២. ចាក់ម្រេចចូលពីលើអំបិល ។ ការណ៍នេះតំណាងឲ្យជម្រើសខុសឆ្គងដែលយើងបានធ្វើ ។

៣. ឥឡូវនេះ យកស្លាបព្រាផ្លាស្ទិច ហើយត្រដុសវានឹងកន្សែង ។



៤. រំកិលស្លាបព្រាយឺតៗនៅខាងលើអំបិល និងម្រេច ។ ម្រេចនឹងតោងជាប់នឹងស្លាបព្រា ! វាដូចជាការអភ័យទោសដែរនៅពេលយើងប្រែចិត្ត ។





រចនារូបភាពដោយ ជូអិល ឆាល

# រូបផ្គុំតូច និងងាយ

ដូចជាលីអាហូណាដែលបានដឹកនាំគ្រួសាររបស់លីហៃដែរ កិច្ចការសាមញ្ញៗអាចជួយយើងឲ្យដោះស្រាយបញ្ហាធំៗបាន ( សូមមើល អាលម៉ា ៣៧:៦, ៣៨–៤៤ ) ។

តើប្អូនៗអាចរកមើលបំណែកនីមួយៗទាំងនេះនៅខាងក្រោមនៅក្នុងរូបផ្គុំនេះបានដែរឬទេ ?

















តើរបៀបតូច និងសាមញ្ញអ្វីខ្លះដែលប្អូនៗអាចធ្វើតាមព្រះយេស៊ូវបាន ?

# អាលម៉ាជាកូនប្រែចិត្ត

ដោយ ហេលី យេនស៊ី
ទស្សនាវដ្ដីសាសនាចក្រ



អាលម៉ាជាកូនប្រុសរបស់ព្យាការី ។ គាត់ត្រូវបានដាក់ឈ្មោះតាមឪពុកគាត់ ប៉ុន្តែគាត់ពុំបានជឿលើអ្វីដែលឪពុករបស់គាត់បានបង្រៀននោះទេ ។ គាត់បានប្រាប់ប្រជាជនថាសាសនាចក្រមិនពិតទេ ។



ថ្ងៃមួយមានទេវតាមួយអង្គបានបង្ហាញព្រះកាយឲ្យអាលម៉ាឃើញ ។
ទេវតាបានប្រាប់អាលម៉ាឲ្យប្រែចិត្ត ។



អាលម៉ាហាក់ដូចជាដេកលក់អស់បីថ្ងៃ ។ គាត់បានគិតអំពីជម្រើសដ៏អាក្រក់របស់គាត់ ។



បន្ទាប់មកអាលម៉ាបានអធិស្ឋានសូមការអត់ទោស ។ ហើយគាត់ត្រូវបានអត់ទោសឲ្យ ! គាត់បានទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ ។ អាលម៉ាបានភ្ញាក់ឡើង ហើយបានបង្រៀនដល់មនុស្សដទៃទៀតអំពីរបៀបដែលព្រះយេស៊ូវបានសង្គ្រោះគាត់ ។




ខ្ញុំអាចប្រែចិត្តបាន ពេលខ្ញុំធ្វើជម្រើសខុសឆ្គង ។
ព្រះយេស៊ូវនឹងតែងតែគង់នៅទីនោះសម្រាប់ខ្ញុំ ។●

*អ្នកអាចអានអំពីរឿងនេះនៅក្នុង ម៉ូសាយ ២៧ ។*

# អាលម៉ាបានប្រែចិត្ត ហើយបានធ្វើតាមព្រះយេស៊ូវ



ពេលប្អូនជ្រើសរើសជម្រើសមួយខុស តើប្អូនគួរធ្វើយ៉ាងណា ?

រចនារូបភាពដោយ អាប៊ីល ស្តុត

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ជូនចំពោះមាតាបិតា

ជួនកាលយើងមិនយល់ស្របនឹងអ្នកដទៃទៀតទេ ។ ប៉ុន្តែយើងនៅតែអាចស្រឡាញ់ពួកគេ ។ យើងក៏អាចតោងឲ្យជាប់នឹងអ្វីដែលយើងដឹងថាត្រឹមត្រូវ ។ សូមអានរឿងនេះនៅទំព័រ ខ១០ ជាមួយកូនៗរបស់លោកអ្នក ហើយជជែកគ្នាអំពីសំណួរទាំងនេះ ៖

តើគ្រួសាររបស់អែលលីបានបង្ហាញសេចក្តីស្រឡាញ់ដូចម្តេច ?

តើគ្រួសាររបស់អែលលីរក្សាសេចក្តីជំនឿរបស់ពួកគេយ៉ាងដូចម្តេច ?

តើគ្រួសាររបស់យើងអាចបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សដទៃទៀត សូម្បីតែពេលយើងមិនយល់ស្របគ្នាយ៉ាងដូចម្តេច ?

យើងទាំងអស់គ្នាមានលក្ខណៈខុសៗគ្នា ប៉ុន្តែមនុស្សគ្រប់គ្នាជាបុត្ររបស់ព្រះ ។

សូមចែកចាយសេចក្តីស្រឡាញ់

ទស្សនាវដ្តី *ប្រិយមិត្ត*

**របៀបដើម្បីផ្ញើរបគំនូរ ឬបទពិសោធន៍នានារបស់កូនលោកអ្នកមកកាន់ទស្សនាវដ្តី *លីអាហូណា***

សូមចូលទៅគេហទំព័រ liahona.ChurchofJesusChrist.orgហើយចុចលើ « Submit an Article or Feedback » ។ ឬអ៊ីម៉ែលវាមកកាន់យើងតាម liahona@ChurchofJesusChrist.org ដោយដាក់ឈ្មោះ អាយុកូនរបស់បងប្អូន ទីក្រុងដែលរស់នៅ ព្រមទាំងសេចក្តីថ្លែងការណ៍អនុញ្ញាតនេះថា ៖ « ខ្ញុំ [ សរសេរឈ្មោះរបស់បងប្អូន ] ផ្តល់ការអនុញ្ញាតឲ្យ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ប្រើប្រាស់ការដាក់បញ្ជូនរបស់កូនខ្ញុំនៅក្នុងទស្សនាវដ្តីសាសនាចក្រ នៅលើគេហទំព័រសាសនាចក្រ និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ព្រមទាំងអាចមាននៅក្នុងរបាយការណ៍របស់សាសនាចក្រ ផលិតផលបោះពុម្ព វីដេអូ ការបោះពុម្ពផ្សាយ និងសម្ភារបំពាក់បំប៉ននានា » ។ ពួកយើងទន្ទឹងរង់ចាំឮពីបងប្អូន !



សូមស្វែងរករូបលីអាហូណាដែលលាក់នៅខាងក្នុង !

មាតិកា


ខ២ មកពីគណៈប្រធានទីមួយ ៖ ធ្វើតាមពួកអ្នកត្រួសត្រាយផ្លូវ
ខ៤ ជម្រើសរបស់លីឡា
ខ៦ សួស្តីមកពីប្រទេសអាហ្សង់ទីន !
ខ៨ រទេះនំប៉័ងតូច
ខ១០ ខុសគ្នាតែជាមួយគ្នា
ខ១២ សេចក្តីជំនឿដែលលូតលាស់របស់ខ្ញុំ
ខ១៤ មិត្តទៅកាន់មិត្ត ៖ គ្រឿងផ្សំសម្ងាត់
ខ១៥ គំនិតឆ្លាតវៃ
ខ១៦ គំរូល្អហាន ៖ ការហៅបម្រើបេសកកម្មដ៏ភ្ញាក់ផ្អើល
ខ១៨ តើអ្នកគិតពីអ្វី ?
ខ១៩ គ្រឿងកម្សាន្ត ៖ រូបផ្គុំតូច និងងាយ
ខ២០ រឿងក្នុងព្រះគម្ពីរ ៖ អាលម៉ាជាកូនប្រែចិត្ត
ខ២៣ ទំព័រផាត់ពណ៌ ៖ អាលម៉ាបានប្រែចិត្ត ហើយបានធ្វើតាមព្រះយេស៊ូវ


នៅលើក្របទស្សនាវដ្តី *ប្រិយមិត្ត*
រចនារូបភាពដោយ រ៉េបេកា សច ជេនសិន

© 2020 BY INTELLECTUAL RESERVE, INC. ALL RIGHTS RESERVED.

CAMBODIAN
4 02167 22258 3